មជ្ឈមណ្ឌលឯកសារកម្ពុជា

PTI0079

# សម្ភាសន៍ជាមួយឈ្មោះ ស៊ឹម នី ភេទប្រុស អាយុ៥៨ឆ្នាំ
# រស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់
# មុខងារសម័យខ្មែរក្រហមៈ អន្តរាគមន៍នៅក្នុងពិសេស
# មុខងារបច្ចុប្បន្នៈ ធ្វើចំការ
# សម្ភាសន៍ដោយៈ ឡុង ដានី
# សម្ភាសន៍ថ្ងៃទី២២ ខែ ខុសភា ឆ្នាំ២០១១
# សរុបទំព័រៈ ៧១

០៣:០៨:៣១

ដានីៈ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអីដែរ?

នីៈ ខ្ញុំឈ្មោះ ស៊ឹម នី ។

ដានីៈ ពូមានអាយុប៉ុន្មានដែរ?

នីៈ អាយុ៥៨ឆ្នាំ

ដានីៈ សព្វថ្ងៃពូរស់នៅក្នុងភូមិឃុំស្រុកអីដែរ?

នីៈ បច្ចុប្បន្នមែន?

ដានីៈ បាទ!

នីៈ បច្ចុប្បន្ននេះគឺជានៅក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

ដានីៈ ចុះមីងគាត់ឈ្មោះអីដែរ?

នីៈ ឈ្មោះម៉ែន សាង ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

នីៈ អាយុប្រហាក់ប្រហែលគ្នាហ្នឹង ។

ដានីៈ អាយុ៥៨ដូចគ្នា?

នីៈ បាទ!

ដានីៈ ចុះពូមានកូនចៅទាំងអស់ប៉ុន្មាន?

នីៈ មានកូន៣នាក់ ។

ដានីៈ ប្រុសប៉ុន្មាន ហើយស្រីប៉ុន្មាន?

នីៈ ប្រុសទាំង៣នាក់ ។

ដានីៈ ហើយសព្វថ្ងៃពូប្រកបមុខរបររកស៊ីអីដែរ?

នីៈ ចំពោះបច្ចុប្បន្នគឺធ្វើចំការ ។

ដានីៈ ធ្វើចំការហ្នឹងមានចំការអីខ្លះទៅ?

នីៈ មានចំការសណ្តែកបាយ ចំការល្ង ហើយនឹងចំការស្រូវ ។

ដានីៈ ហើយពូស្រុកកំណើតកើតជានៅភូមិឃុំស្រុកណាដែរ?

នីៈ នៅភូមិខ្សាច់លុប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ។

ដានីៈ ចុះឪពុកពូគាត់ឈ្មោះអីដែរ?

នីៈ គាត់ឈ្មោះ ហ៊ីង រស់ ។

ដានីៈ សព្វថ្ងៃគាត់រស់ឬក៏ស្លាប់ហើយ?

នីៈ គាត់ស្លាប់បាត់ហើយ ។

ដានីៈ គាត់ចែកឋានតាំងពីពេលណា?

នីៈ តាំងពីប៉ុន្មានហើយ មកទល់នឹងពេលហ្នឹងប៉ុន្មានហើយ គាត់ចែកឋាន១៣ឆ្នាំហើយ ។

ដានីៈ ចុះម្តាយលោកពូ?

នីៈ ម្តាយគាត់ស្លាប់ទៅ៣ឆ្នាំហើយ ។

ដានីៈ គាត់ឈ្មោះអីដែរ?

នីៈ គាត់ឈ្មោះ អ៊ុយ នៅ ។

ដានីៈ ចុះលោកពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

នីៈ មានបងប្អូនបង្កើត៧នាក់ ។

ដានីៈ ស្រីប៉ុន្មាន ហើយប្រុសប៉ុន្មានទៅ?

នីៈ ប្រុស៤នាក់ ហើយស្រី៣នាក់ ។

ដានីៈ ពូកូនទីប៉ុន្មាន?

នីៈ កូនទី១ ។

ដានីៈ ចុះកាលពីក្មេងៗពូមានបានរៀនសូត្រអីទេ?

នីៈ កាលពីសង្គមរាស្រ្តនិយមរៀនដែរ ដល់ថ្នាក់ទី៨ ។

ដានីៈ ទី៨ចាស់?

នីៈ បាទ!

ដានីៈ ហើយពូរៀននៅសាលាណាដែរ?

នីៈ រៀននៅសាលាក្រាំងស្វែង ។

ដានីៈ ពូឈប់រៀនឆ្នាំណា?

នី៖ ឈប់រៀននៅឆ្នាំ១៩៦៤ ។

ដានី៖ មូលហេតុអីបានជាពូរៀនបានត្រឹមថ្នាក់ទី៨ហើយឈប់ ។

នី៖ មូលហេតុមកពីឪពុកម្ដាយទីទាល់ក្រពេក ។

ដានី៖ ដល់ពេលអញ្ចឹងទៅ លោកពូឈប់រៀនហើយមកធ្វើអីវិញ?

នី៖ មកធ្វើការងារក្នុងបន្ទុកគ្រួសារ ។

ដានី៖ ការងារកាលហ្នឹងយើងធ្វើអីខ្លះទៅ?

នី៖ ការងារកាលហ្នឹងគឺខែវស្សាយើងធ្វើស្រែផង ធ្វើចំការផងនៅតំបន់នោះ ហើយចំពោះខែប្រាំងអាជីវកម្មសំខាន់សម្រាប់កសិករនៅកន្លែងនោះគឺធ្វើត្នោត ។

ដានី៖ ឡើងត្នោតឡើងអីទៅ?

នី៖ បាទ!

ដានី៖ ហើយពូចេះឡើងត្នោតដែរ?

នី៖ ចេះ ។

ដានី៖ ពូនៅជួយធ្វើស្រែធ្វើចំការ ឡើងត្នោត ហើយជួយធ្វើការងារឪពុកម្ដាយហ្នឹងពេលណាទៅ?

នី៖ ខ្ញុំជួយធ្វើការឪពុកម្ដាយនៅក្នុងបន្ទុកគ្រួសារហ្នឹងគឺចាប់ពីអាយុ១៤ឆ្នាំមកអាយុ១៨ឆ្នាំ អាយុ១៨ឆ្នាំក្រោយពីថ្ងៃ១៨ មីនា រដ្ឋប្រហារឆ្នាំ៧០ហើយរំលងបាន២ឆ្នាំ មកទល់ដល់ថ្ងៃ១០ ខែ០២ ឆ្នាំ៧២ ខ្ញុំចេញពីផ្ទះហើយមកធ្វើកងទ័ព ។

ដានី៖ កាលហ្នឹងថ្ងៃ១០ ខែ០២ ឆ្នាំ៧២ ពូចេញមកធ្វើកងទ័ព កាលហ្នឹងពូស្ម័គ្រចិត្តមកធ្វើឬក៏ការជ្រើសរើស?

នី៖ ស្ម័គ្រចិត្ត ។

ដានី៖ កាលហ្នឹងមូលហេតុអីបានជាពូស្ម័គ្រចិត្តមកធ្វើកងទ័ព?

នី៖ មូលហេតុកាលនោះគឺថា នៅពីក្រោយទៅគឺថារដ្ឋអំណាចគេកៀបសង្កត់ឲ្យធ្វើពលកម្ម ដល់ពេលពលកម្មវារឹតរ៉ឹនទៅវាហាក់បីដូចជាលក្ខណៈមួយជំរុញដែរ ជំរុញយុវជនឲ្យមកមុខ បើអញ្ចឹងវាវិធីដើម្បីឲ្យបានកើនខាងជួរកងទ័ព ទាល់តែកៀបការងារពលកម្មខាងក្រោយ ម្លោះហើយដល់មានការស្មុគស្មាញអញ្ចឹងទៅ ក៏ត្រូវបង្ខំចិត្តខ្លះហើយស្ម័គ្រចិត្តខ្លះមក ។

ដានី៖ ចុះកាលស្ម័គ្រចិត្តមកធ្វើកងទ័ពហ្នឹង ពូស្ម័គ្រចិត្តមកតែម្នាក់ឯងឬមួយក៏មានដូចថាមិត្តឬក៏អ្នកជិតខាងមកជាមួយ?

នី៖ មានមិត្តមកជាមួយគ្នា ។

ដានី៖ មានប៉ុន្មាននាក់ដែរកាលហ្នឹង?

នី៖ មកជាមួយខ្ញុំមានមិត្តភ័ក្រ្តជិតស្និទនៅក្នុងភូមិជាមួយគ្នាហ្នឹងគឺមានគ្នា៤រូប ។

ដានី៖ សព្វថ្ងៃគាត់មកនៅហ្នឹងដែរ?

នី៖ គាត់ស្លាប់អស់ហើយ ។

ដានី៖ ស្លាប់អស់ហើយ?

នី៖ បាទ! ស្លាប់តាំងពីសង្រ្គាម៥ឆ្នាំម្លេះ ចេញជំនាន់ហ្នឹងគ្នា៤នាក់គឺនៅសល់តែខ្ញុំម្នាក់ឯងទេ ។

ដានី៖ សល់តែលោកពូម្នាក់ទេ ហើយ៣នាក់ទៀតគាត់ស្លាប់ហើយ?

នី៖ បាទ!

ដានី៖ អ្នកនៅភូមិជាមួយគ្នាហ្នឹង?

នី៖ បាទ!

ដានី៖ ចុះកាលហ្នឹងពេលដែលយើងចូលកងទ័ពហើយ ហើយយើងចូលកងទ័ពខាងរំដោះមែន?

នី៖ បាទ! ចូលខាងកងទ័ពរំដោះ ។

ដានី៖ អញ្ចឹងយើងចូលទៅនៅណាទៅដំបូង?

នី៖ ដំបូងដូរកងទ័ពហ្នឹងគេហៅថារណៈសេរូរួបរួមជាតិណា រណៈសេរូរំដោះជាតិណា៎ មុនដំបូងចូលទៅនៅកងទ័ពស្រុក កងទ័ពស្រុកបាទី តែកាលជំនាន់ហ្នឹងគេហៅជាលេខវិញណា៎ ដែលគេហៅថាស្រុក៥៦ ហើយខេត្តគេប្រែទៅជាតំបន់វិញ ។

ដានី៖ តំបន់ប៉ុន្មានទៅ?

នី៖ តំបន់៣៣ ហើយនៅបម្រើនៅក្នុងកងទ័ពស្រុកហ្នឹងរយៈពេល១រដូវប្រាំង រួចហើយមកកងទ័ពតំបន់ កងទ័ពខេត្ត ។

ដានី៖ តំបន់៣៣នៅកន្លែងណាទៅ?

នី៖ តំបន់៣៣ហ្នឹង គឺវ័ណ្ឌសីមា ស្មើនឹងវ័ណ្ឌសីមាស្រុកដែរ មកខាងជើងវាស្មើនឹងបឹងទន្លេបាទីវាចែកគ្នាជាមួយកណ្តាលស្ទឹង ព្រោះស្រុកកណ្តាលស្ទឹងវានៅក្នុងខេត្តកណ្តាល ឯពីត្រឹមបឹងទន្លេបាទីហ្នឹងទៅត្បូងទៅគឺវានៅក្នុងវ័ណ្ឌតាកែវ ហើយតំបន់៣៣ហ្នឹងក៏អញ្ចឹងដែរ ប៉ុន្តែគ្រាន់ការបែងចែកតំបន់ឬខេត្តកាលជំនាន់ហ្នឹង គឺគេបែងចែកជាបណ្តោយ ផ្ទៃទទឹងគឺជើងត្បូងហើយផ្ទៃបណ្តោយគឺមានលិចកើត ព្រោះគេបែងចែកអញ្ចឹងដើម្បីឲ្យមាន ព្រោះយើងពីដើមស្រុកខ្លះដូចថាប៉ែកខាងលិចៗភាគច្រើនគឺខ្វត់ខ្វាយ សេដ្ឋកិច្ចអត់មានរីកចំរើនទេ ម្លោះហើយគេបែងចែកពាក់កណ្តាលឲ្យឆ្លងកាត់ផ្លូវជាតិ២ផង ហើយនឹងឆ្លងកាត់ផ្លូវជាតិលេខ៣

ផង ឯខ័ណ្ឌឬស្រុកពីដើមគឺវាចែកគ្នាក្នុងផ្លូវជាតិលេខ៣ ហើយឥលូវនេះបានបង្វិលមកដូចខ័ណ្ឌខេត្តពីដើមវិញ ។

ដានី: អញ្ចឹងកាលនោះនៅក្នុងតំបន់៣៣ របស់ភូមិភាគ?

នី: របស់ភូមិភាគនារតី ។

ដានី: អញ្ចឹងពូនៅខាងកងទ័ពស្រុកបាទីហ្នឹងបានរយៈពេលតែ១រដូវប្រាំងទេ?

នី: បាទ!

ដានី: ហើយផ្លាស់មកខាងកងទ័ពតំបន់?

នី: បាទ! គេហៅកងទ័ពតំបន់ខាងខេត្ត ។

ដានី: តំបន់នៅណាទៅកាលហ្នឹង?

នី: កងទ័ពតំបន់ការធ្វើសកម្មភាពគឺមានតាំងពីផ្លូវជាតិលេខ៣ ដល់ផ្លូវជាតិលេខ៤ ហើយនឹងផ្លូវជាតិលេខ២ ។

ដានី: ហើយមន្ទីរតំបន់៣៣ហ្នឹង នៅកន្លែងណាទៅ?

នី: មន្ទីរតំបន់៣៣គឺនៅតាមដងស្ទឹងកាត់ផ្លុក ។

ដានី: កាលហ្នឹងនៅខាងហ្នឹងវិញ?

នី: បាទ! ព្រោះខាងហ្នឹងវានៅជាប់នឹងព្រៃ ហើយជាតំបន់ដាច់ស្រយ៉ាល ។

ដានី: ហើយចុះពេលដែលលោកពូមកខាងកងទ័ពតំបន់ហ្នឹង កងទ័ពហ្នឹងគេរៀបចំជារចនាសម្ព័ន្ធយ៉ាងម៉េចហើយ ជាកងពលឬក៏វរៈសេនា?

នី: ជាវរៈសេនាធំហើយ អត់កងពលទេ មានតែវរៈសេនាតូច ហើយនឹងវរៈសេនាធំ ។

ដានី: ចុះកាលហ្នឹងប្រធានវរៈសេនាធំពីណាគេ?

នី: ប្រធានវរៈសេនាធំរបស់អង្គភាពខ្ញុំហ្នឹងឈ្មោះ បូ តែមិនស្គាល់ត្រកូលគាត់ទេ ស្គាល់តែឈ្មោះសមីខ្លួន ។

ដានី: ឈ្មោះ បូ កាលដែលជិនាន់៣ឆ្នាំគាត់ទៅខាងកងទ័ពដើងទឹកហ្នឹងមែន?

នី: មិនមែន បូ ហ្នឹងទេហ្នឹង បូ នោះគឺស្លាប់បាត់ហើយ បូ ហ្នឹងកំណើតកើតជានៅកំពង់ស្ពឺយើងទេ ឯ បូ ដែលទៅខាងដើងទឹកហ្នឹងគាត់នៅខាងកំពត ។

ដានី: ចុះកាលហ្នឹងគណៈតំបន់៣៣ពីណាគេ?

នី: គណៈតំបន់៣៣លើកទី១ឈ្មោះ ឌុច ។

ដានី: ឌុច ហ្នឹងមិនមែន ឌុច ខាងគុលាការគេកាត់ទោសនេះទេ?

នី៖ ឌុច ដែលខាងតុលាការកាត់ទោសហ្នឹង ខ្ញុំមិនដែលបានជួបរូបពិតទេ ប៉ុន្តែ ឌុច ខ គណៈតំបន់៣៣ពីមុននោះគឺគាត់ទាបហើយស ។

ដានី៖ ព្រោះឈ្មោះ ឌុច ដូចគ្នាស្មានតែ ឌុច នោះ ។ អញ្ចឹងគណៈតំបន់ដំបូងគេឈ្មោះ តាឌុច ហ្នឹង?

នី៖ បាទ!

ដានី៖ ហើយពេលដែលលោកពូទៅធ្វើកងទ័ពនៅតំបន់៣៣ហ្នឹង គាត់ដដែលឬក៏មានផ្លាស់ប្តូរគណៈតំបន់ទៀត?

នី៖ ក្រោយពេលហ្នឹងខ្ញុំនៅក្នុងអង្គភាពហ្នឹងបានរយៈពេលតែ២ឆ្នាំទេ ហើយខ្ញុំឡើងមកអង្គភាពភូមិភាគ ដល់ពេលឡើងមកអង្គភាពភូមិភាគមកយើងត្រូវការធ្វើសកម្មភាពជងផ្លូវជាតិលេខ ៥-៤-៣-២ មានសកម្មភាពប៉ុណ្ណឹងផ្លូវជាតិ ។

ដានី៖ អញ្ចឹងពូនៅក្នុងតំបន់បានរយៈពេល២ឆ្នាំ ហើយឆ្នាំណាបានពូឡើងអង្គភាពភូមិភាគ?

នី៖ ឆ្នាំប៉ុន្មានទេ វៃទ្រង់ទ្រាយភូមិភាគតាកែវហើយឡើងមកភូមិភាគ តែភ្លេចថ្ងៃខែអស់ហើយ ដូចជាឆ្នាំ៧៤ ។

ដានី៖ តែដឹងតែឆ្នាំ៧៤?

នី៖ បាទ! ដើមឆ្នាំ៧៤ហ្នឹងហ្នង ។

ដានី៖ អាហ្នឹងកងទ័ពរបស់ពូវរៈសេនាធំហ្នឹង ប្រមូលកម្លាំងឲ្យទៅជាភូមិភាគទាំងអស់?

នី៖ ដល់ពេលឡើងពីតំបន់ ហើយទោះបីជាឡើងពីស្រុកមកក៏ដោយ ឡើងជាវរៈសេនាតូចៗមក ប៉ុន្តែបើសិនជាវរៈសេនាតូចក្នុងតំបន់វៃផ្លូវជាតិលេខ៤ ឧទាហរណ៍ថាក្នុងរដូវប្រាំងត្រូវការខូចខាតអស់ប៉ុន្មាន ជាពិការ ជាស្លាប់ ដូចថាអស់១០០នាក់ អាហ្នឹងត្រូវការដកវិញហើយដកពីស្រុកឡើងមកបគ្រប់វិញស្មើរនឹងអនុសេនាធំ ហើយមកបគ្រប់ក្នុងវរៈសេនាតូចហ្នឹងវិញ ប៉ុន្តែបើសិនជាត្រូវការពង្រីកជាថ្មី ពង្រីកឲ្យច្រើនតែម្តងគឺត្រូវឡើងមកទាំងវរៈ ។

ដានី៖ ឡើងមកទាំងវរៈហ្នង?

នី៖ បាទ! មកទាំងមេ មកទាំងកើយទាំងអស់ ។

ដានី៖ អញ្ចឹងកាលឡើងទៅភូមិភាគហ្នឹង ឡើងទៅទាំងអស់ ទាំងមេទាំងកើយ?

នី៖ បាទ! ទាំងអស់ហ្នង បើឡើងពីតំបន់មកភាគហ្នឹងបានឡើងមកទាំងអស់ហ្នង មកទាំងផ្ទាំង ឧទាហរណ៍ថា វរៈសេនាធំ១៣នាក់ ហើយខ្ញុំឡើងពីតំបន់មកចូលក្នុងអង្គភាពភូមិភាគ កាលនោះអង្គភាពភូមិភាគដែលចូលទើបកកើតឡើងខ្ញុំចូលក្នុងកងពលទី២ ប្រចាំភូមិភាគនារតីវរៈសេនាធំ១៣ ដល់ពេលត្រូវការពង្រីកកងពលថែមទៀត បង្កើតកងពលថែមទៀតភូមិ

ភាគត្រូវការបែកកម្លាំងមកផ្លូវជាតិលេខ៥ ផ្លូវជាតិលេខ៤មកពីខាងជើងចំហៀងផ្លូវ បើអញ្ចឹងគេបញ្ចូលអង្គភាពខ្ញុំហ្នឹងវរៈសេនាធំ១៣ហ្នឹង មករៀបចំកងពលទី៤ ដើម្បីឲ្យបានមួយវរៈសេនាធំហ្នឹងវាជាមនុស្សចាស់ មនុស្សដែលឆ្លងកាត់ហើយ ឆ្លងកាត់សង្គ្រាមច្បាំងហើយ បើអញ្ចឹងកម្លាំងក្រៅពីនោះពីវរៈសេនាធំទៀត អាហ្នឹងជាកម្លាំងថ្មីទៀត ជាកម្លាំងឡើងពីស្រុកមកថ្មី អញ្ចឹងយកមកហើយបូកបញ្ចូលគ្នា បង្កើតជាមួយកងពលមួយថ្មីទៀត ។

ដានី: បានមួយកងពលតូចទៀត?

នី: បាទ!

ដានី: អញ្ចឹងកាលពូឡើងទៅដំបូងហ្នឹង ឡើងទៅកងពលទី២ទេ?

នី: បាទ! កងពលទី២ ហើយវរៈសេនាធំ១៣ ។

ដានី: កងពលទី២ហ្នឹងរបស់ភូមិភាគនារតីមែន?

នី: របស់ភូមិភាគនារតី ។

ដានី: មិនមែនរបស់ភូមិភាគបូព៌ាទេ,

នី: មិនមែនទេ ។

ដានី: អញ្ចឹងដល់ពេលកងពលទី២ អ្នកណាគេប្រធានកងពលទី២ហ្នឹង?

នី: ប្រធានកងពលទី២ឈ្មោះ សម ប៊ិត ។

ដានី: សម ប៊ិត ហ្នឹងប្រធានកងពលទី២?

នី: បាទ! ប្រធានកងពលទី២តាំងពីអើយ តាំងពីកកើតកងពលហ្នឹងម្ល៉េះ ។

ដានី: ចុះឈ្មោះ ទាញ ។

នី: អត់ដែលឮទេ ។

ដានី: ចុះពូមានដែលស្គាល់ តាសាន នៅប្រម៉ោយទេ ។

នី: អ៎! តាសាន ហ្នឹងស្គាល់ គាត់ខាងភូមិភាគបូព៌ា ។

ដានី: អញ្ចឹងកាលហ្នឹងប្រធានកងពលទី២ហ្នឹង តាប៊ិត គាត់ធ្វើប្រធានកងពល?

នី: បាទ! គាត់ធ្វើប្រធានកងពល ។

ដានី: គណៈកងពលមាន៣នាក់?

នី: បាទ! មាន៣នាក់ ។

ដានី: ហើយគាត់ធ្វើប្រធាន?

នី: ហ្នឹងអើយ ។

ដានី: ខាងនយោបាយ?

នីៈ បាទ!

ដានីៈ ចុះខាងយោធា?

នីៈ យោធាហ្នឹងគាត់ឈ្មោះអីទេ ប៉ុន្តែគាត់ស្លាប់បាត់ហើយ ឈ្មោះ វ៉ែន ។

ដានីៈ ឈ្មោះ វ៉ែន កូនប្រសារ តាម៉ុក ហ្នឹង?

នីៈ បាទ! គាត់ខាងយោធា ។

ដានីៈ ដំបូងខាងកងពលទី២?

នីៈ បាទ!

ដានីៈ ហើយលោកពូនៅខាងកងពលទី២ហ្នឹងបានរយៈពេលប៉ុន្មាន បានគេបំបែកឲ្យចេញឲ្យទៅនៅកងពលទី៤?

នីៈ គេបំបែកពីកងពលទី២ឲ្យទៅនៅកងពលទី៤ហ្នឹងគឺមួយ១រដូវប្រាំង ។

ដានីៈ អញ្ចឹងក្នុងភូមិភាគនារតីហ្នឹងមាន៤កងពល?

នីៈ រួមគ្នា ឧទាហរណ៍ថាកងពលទី១ ហើយកងពលទី១ហ្នឹងគឺនៅប្រចាំតាមផ្លូវជាតិលេខ៥ ហើយកងពលលេខ២គឺប្រចាំនៅផ្លូវជាតិលេខ២ហើយនឹងផ្លូវជាតិលេខ៣ ឯចំពោះកងពលទី៣ហើយនឹងទី៤ហ្នឹងគឺអមផ្លូវជាតិលេខ៤ ហើយចែកកម្លាំងជា២ទៀត ហើយមកផ្លូវជាតិលេខ៥ផង មូលហេតុអីបានជាមានការផ្លាស់ប្តូរប្រឡូកប្រឡំគ្នាអញ្ចឹង ព្រោះហៅថារវាងមេៗនោះគឺចង់យកថ្វីដៃរៀងខ្លួន របៀបថាចង់យកមុខមាត់រៀងខ្លួន វ៉ៃយកទៅរាបហើយចាប់ដៃគ្នា បើសិនជាទាហានបុកបាក់ខាងណា កងពលណា វរៈសេនាតូចណា អាហ្នឹងរូចហើយដកទៅវិញ យកទៅរៀនសូត្រពិសោធន៍ យកទៅពិសោធន៍ខាងអន្តភាពដែលមិនបាក់ ។

ដានីៈ ដើម្បីយើងប្រកួតប្រជែងគ្នា?

នីៈ បាទ!

ដានីៈ អញ្ចឹងកងពលទី១អ្នកណាគេប្រធានកងពល?

នីៈ ប្រធានកងពលទី១ឈ្មោះស្អីទេ ដល់វាបានវ៉ៃចូលគ្នារយៈពេលខ្លីពេក តែមួយរដូវប្រាំងវ៉ៃចុងបញ្ចប់ហើយមកភ្នំពេញ ដល់ពេលហ្នឹងកងពលគ្រប់ភូមិភាគគឺទៅរៀន ។

ដានីៈ អញ្ចឹងកងពលទី២ហើយនឹងកងពលទី៣ហ្នឹង ពូមានស្គាល់ទេ ។

នីៈ ប្រធានកងពលទី២ហើយនឹងទី៣ខ្ញុំស្គាល់ ព្រោះប្រធានកងពលទី២ហើយនឹងប្រធានកងពលទី៣ហ្នឹងចេញមកជាមួយគ្នាទេ គឺ មាស មុត បច្ចុប្បន្ននេះ ឧត្តមសេនីយកែវ ទី ហ្នឹងចុះមកកាន់កងពលទី៣ ចេញដកហូតចេញពីកងពលទី២មក ។

ដានី៖ ចេញពីកងពលទី២មក?

នី៖ បាទ! បំបែកមេចេញពីហ្នឹងមក ។

ដានី៖ ចុះដឹបូងនៅជាមួយ?

នី៖ នៅជាមួយ តាសម ប៊ិត ។

ដានី៖ ហើយមាន តាវ៉ែន អីហ្នឹង?

នី៖ បាទ!

ដានី៖ ហើយតាវ៉ែន ហើយនឹងតាម៉ុត ហ្នឹងគាត់នៅជាមួយគ្នា?

នី៖ បាទ!

ដានី៖ មាស មិត, សម ប៊ិត ហើយវ៉ែន ហ្នឹងនៅជាមួយគ្នា?

នី៖ នៅជាមួយគ្នា ។

ដានី៖ ដល់ពេលក្រោយមកគេបង្កើតកងពលថ្មីមួយទៀត គេដក តាមិត ឲ្យមកធ្វើប្រធាននៅកងពលទី៣?

នី៖ បាទ!

ដានី៖ ហើយ តាវ៉ែន នៅកងពលទី២ដដែល?

នី៖ នៅដដែល ។

ដានី៖ ចុះដល់ពេលកងពលទី៤របស់ពូដែលទើបតែបង្កើតថ្មីនេះ?

នី៖ កងពលទី៤ហ្នឹងឈ្មោះស្អីទេ របៀបថាកាលជំនាន់នោះច្រើនតែពាក់ព័ន្ធទិន្នាការនយោបាយរបៀបចោទគ្នា តែខ្ញុំមិនស្គាល់ទេណា៎ ហើយដូចជា តាម៉េង អីហ្នឹងគេចាប់គាត់យកទៅធ្វើឃាតអស់ហើយ ។

ដានី៖ ប៉ុន្តែកាលជំនាន់នោះគាត់ធ្វើប្រធានកងពល?

នី៖ ប្រធានកងពលហ្នឹង របៀបថាគាត់ធ្វើប្រធានរងៗ ហើយចេះតែរួមៗគ្នាណា៎ ហើយបើរួមមកហ្នុងគឺចេញមកពី សម ប៊ិត ចេញពីមាស មុត មកទេ ។

ដានី៖ អញ្ចឹងកងពលទី៤ហ្នឹងគឺនៅក្រោមកងពលទី២ ហើយនឹងកងពលទី៣ទេ?

នី៖ បាទ! ហើយកាលចាត់ចែងមកពីជំនាន់ហ្នឹង តាម៉ុក គាត់មិនគណៈភូមិភាគ គឺចាត់ចែងរៀបរយមកគាត់ទទួលការចាត់ចែងណែនាំពី តាម៉ុក មក ។

ដានី៖ កាលហ្នឹងពូមានឋានៈអីដែរ?

នី៖ ខ្ញុំកាលនោះខ្ញុំមានឋានៈជាមេក្រុម ។

ដានី៖ កាលពេលចេញមកកងពលទី៤?

នី៖ បាទ! តាមពិតទៅខ្ញុំជាមេក្រុមមករហូត តាំងពីខ្ញុំនៅកងទ័ពស្រុកនោះ ។

ដានី៖ អញ្ជឹងអត់មានឡើងតួនាទីអីទេ?

នី៖ អត់ទេ មនុស្សដែលគ្មានខ្សែគ្មានរយៈ ទោះបីជាឆ្លងកាត់យ៉ាងម៉េចក៏ដោយ ត្រឹមតែគេសរសើរតែប៉ុណ្ណឹងឯង ។

ដានី៖ អញ្ជឹងកាលជំនាន់ហ្នឹងអញ្ជឹងដែរ?

នី៖ បាទ!

ដានី៖ អញ្ជឹងទាល់តែយើងស្គាល់មេស្គាល់អីបានយើងឆាប់បានឡើង?

នី៖ ហ្នឹងអើយ បើសិនជាមានការឆ្លងកាត់ល្អមៗ ឧទាហរណ៍ថាជំនាន់នោះដូចជាប្អូនធ្លាប់ដឹងពុទ្ធិះហើយ ឧទាហរណ៍ថាមនុស្សណា មេកំពូលដូចជា សម ប៊ិត ប៉ុក់មាស មុតដើមកំណើតនៅឯណា នៅក្នុងកំពត ស្រុកឈូក បើអញ្ជឹងមនុស្សដែលមកពីហ្នឹងដែរ អាហ្នឹងបានឆាប់ឡើងធំ ។

ដានី៖ អញ្ជឹងពូមកពីខាងបាទីអញ្ជឹង អត់មានមេណាដែលមកពីខាងបាទីទេ?

នី៖ ដូចថាខ្ញុំនៅខាងបាទីអញ្ជឹង ហើយនៅខាងតំបន់៣៣ ហើយស្ថិតនៅក្នុងសភាពដែលគេតាមដានអាហ្នឹងអត់មានទៅណារួចទេ ។

ដានី៖ អញ្ជឹងបើយើងមកពីស្រុកកំណើតជាមួយគ្នាពងស្គាល់ៗ ដូចថាសាច់ញាតិពូជសំបូរអីអាហ្នឹងដំឡើងធំហ្មង?

នី៖ បាទ!

ដានី៖ អញ្ជឹងពេលដែលពូនៅកងពលទី៤ហ្នឹង ពេលហ្នឹងយើងវ៉ៃនៅខាងផ្លូវជាតិលេខ៥?

នី៖ ផ្លូវជាតិលេខ៥ ហើយនឹងផ្លូវជាតិលេខ៤ ។

ដានី៖ តែពីរហ្នឹងទេ?

នី៖ បាទ! ដល់ពេលរួចត្រូវការបើកសមរភូមិធំហ្មង អាហ្នឹងបានគេប្រមូលគ្នា ឧទាហរណ៍ថាវ៉ៃផ្លូវជាតិលេខ៤ក៏ដោយ ប៉ុន្តែគ្រាន់ថាបើវ៉ៃផ្លូវជាតិលេខ៤ក៏ដោយ ដូចថារួមគ្នាវ៉ៃផ្លូវជាតិលេខ៤ហើយចាប់វ៉ៃពីណា ឧទាហរណ៍ថាចាប់វ៉ៃពីត្រពាំងក្រឡឹងមកទល់គ្នាកំពង់សិលា បើអញ្ជឹងខាងជើងគឺនៅតែខាងជើងផ្លូវទេ ហើយខាងត្បូងគឺនៅតែខាងត្បូងទេ ។

ដានី៖ អញ្ជឹងគេមានមុខព្រួញរបស់គេច្បាស់ៗមែនទេ?

នី៖ ច្បាស់ៗ ។

ដានី៖ ឧបមាថាកងពលទី៤នៅខាងជើងផ្លូវគឺនៅតែខាងជើងហ្នឹងទេ?

នី៖ ខាងជើងហ្នឹងឧទាហរណ៍ថាកំណត់នៅខាងជើងប៉ុន្មាន រយៈពេល១រដូវប្រាំង ចប់១រដូវប្រាំងហ្នឹងបានត្រូវមានផែនការណ៍ផ្សេងទៀត ត្រូវឆ្លងប្ដូរមួយក៏ត្រូវវិលមកផ្លូវជាតិលេខ៥វិញ ។

ដានី៖ ចុះកាលហ្នឹងយើងរបៀបវៃអីយ៉ាងម៉េចទៅ ដូចថារដូវប្រាំងយុទ្ធសាស្ត្រយើងត្រូវវៃយ៉ាងម៉េច ហើយពេលរដូវវស្សាយើងត្រូវវៃយ៉ាងម៉េចដែរ?

នី៖ សកម្មភាពពេលនោះគឺនៅក្នុងរដូវប្រាំង រដូវប្រាំងជាទូទៅគឺត្រូវបើកសមរភូមិជាទ្រង់ទ្រាយធំ ត្រូវការវៃផ្ដាច់ផ្លូវ កាត់ស្ពាន វៃហ៊ុំព័ទ្ធ ទីតាំងណាដែលត្រូវវៃគឺវៃហ៊ុំព័ទ្ធ វៃហ្នឹងគឺវៃយកសេដ្ឋកិច្ចតែម្ដង អ្នកវៃហ៊ុំព័ទ្ធហ្នឹងគឺវៃទៅ ហើយអ្នកកាត់ផ្លូវគឺកាត់ ការពារក្បួនដឹកជញ្ជូន អ្នកវៃហ៊ុំព័ទ្ធគឺវៃរំកិលចូលការពារឆ័ត្រយោង ។

ដានី៖ ការពារក្រែងលោគេប្រើយន្តហោះអី?

នី៖ បាទ! យន្តហោះមកទម្លាក់ បើយើងនៅជិតហើយអាហ្នឹងបាញ់ កុំឲ្យធ្លាក់ត្រូវចំនុច ។

ដានី៖ កាលហ្នឹងអ្នកដែលបញ្ជារួមហ្នឹងគឺ តាម៉ុក?

នី៖ បាទ! តាម៉ុក គាត់អ្នកបញ្ជារួមហ្នឹង ។

ដានី៖ កាលហ្នឹងពូ ពេលដែលសង្គ្រាម៥ឆ្នាំហ្នឹងពូមានត្រូវរបួសទេ?

នី៖ មានត្រូវដែរ ត្រូវពីរកន្លែង ត្រូវភ្លៅ ហើយត្រូវកន្លែងនេះ គ្រាប់នៅរហូតដល់បច្ចុប្បន្ន ។

ដានី៖ គ្រាប់នៅរហូតដល់ឥលូវហ្នឹង?

នី៖ បាទ!

ដានី៖ ហើយម៉េច យើងយកចេញអត់បាន?

នី៖ គ្រាប់វានៅជាប់ហ្នឹងក្រដាស ដូចថាក្រដាសបាំងចូលទៅក្នុងស្លួត ដល់ពេលអញ្ចឹងពេទ្យគេអត់ហ៊ានវះ ហើយបើវះទៅគឺវាដាច់ក្រដាសហ្នឹងហើយ ហើយបើដាច់ក្រដាសហ្នឹងគឺវាមានបញ្ហា អញ្ចឹងបើទុកទៅវាអត់អីគេចាក់ថ្នាំឲ្យ ដល់ពេលគេចាក់ថ្នាំឲ្យរយៈពេល២ឆ្នាំក៏ដូចជាធម្មតាទៅ ប៉ុន្តែបើយើងធ្វើការអីប៉ះពាចំហ្នឹងវានៅឈឺអួលអញ្ចឹងដែរ មិនមែនអំបែងទេអានេះគ្រាប់ណា៎ បើអំបែងនៅមិនបានទេ ។

ដានី៖ អាហ្នឹងពេលសង្គ្រាម៧០ដល់៧៥ហ្នឹង?

នី៖ បាទ!

ដានី៖ ពូត្រូវគ្រាប់ខាងទាហានលន់ នល់មែន?

នី៖ ខាងទាហាន លន់ នល់ ។

ដានី៖ អញ្ចឹងដូចថាអ្នកដែលទៅធ្វើកងទ័ពហ្នឹង ដូចថាកម្រជៀសផុត ដូចថាអត់ត្រូវរបួស?

នីៈ កម្រណាស់ ខ្លះដល់ថ្នាក់រកកន្លែងរាប់មិនឃើញផង ចុះបើវាច្រើនពេក ឧទាហរណ៍ថាវៃសមរភូមិហ្នឹងមួយត្រូវ៨-១០កន្លែង ដេកពេទ្យអញ្ចឹងជាទៅ ហើយទៅវៃទៀតត្រូវ៨-១០កន្លែងទៀត ។

ដានីៈ ហើយពូដូចថាយើងទៅសមរភូមិមួយៗ ហើយយើងត្រូវរបួសអញ្ចឹងដល់ពេលយើងចូលទៅក្រោយយើងមានអារម្មណ៍ថាខ្លាច យើងមានអារម្មណ៍ថាម៉េចដែរអាហ្នឹង?

នីៈ អត់មានខ្លាចទេ ។

ដានីៈ អត់មានខ្លាចទេ?

នីៈ បាទ! អត់មានខ្លាចទេ ដូចមិននឹកឃើញរឿងខ្លាច ។

ដានីៈ ម៉េចអញ្ចឹង?

នីៈ មិនដឹងជាយ៉ាងម៉េច ដូចនៅតែធម្មតា ហើយវារបៀបដូចថាមានតែចិត្តមួយគឺហៅថាវាឈឺចាប់លើសមុនទៀត ។

ដានីៈ អីងដែលគេធ្វើឲ្យយើងត្រូវរបួសហ្នឹងមែន?

នីៈ បាទ! អញ្ចឹងបានពាក្យចាស់ថា "ឆ្អឹងស្រែក ស្បែកហៅ" ។

ដានីៈ ចុះអាហ្នឹងដូចថាមកពីមនោគមន៍វិជ្ជា ឬក៏ដោយសារខាងពួកទាហានលន់ នល់ ធ្វើអំពើអីមួយដែលអាក្រក់យ៉ាងម៉េចបានធ្វើឲ្យយើងពេលទៅសមរភូមិ ដូចថាសមរភូមិវាគ្រោះថ្នាក់ណាស់ ហើយយើងនៅតែចង់ទៅ ហើយយើងក្លាហានហើយយើងអត់ខ្លាចទេ អាហ្នឹងមកពីមូលហេតុអី?

នីៈ មូលហេតុវាមាន ឧទាហរណ៍ថាភូមិនេះវាស្ថិតនៅក្នុងសភាពប្រទាញប្រទង់ ពេលប្រទាញប្រទង់អញ្ចឹង ទាហានដែលមកដល់ហើយឆ្លងកាត់អញ្ចឹងហើយ មកប៉ះក្រមុំវាចាប់ក្រមុំជ្រូកចាប់ជ្រូក គោចាប់គោ ហើយបាញ់គោស៊ី និយាយថារបស់ណាដែលត្រូវយកគឺយកទាំងអស់ មិនប្រកាន់ ម្ល៉ោះហើយមានស្រូវមានអង្ករអីបន្តិចបន្តួច ឧទាហរណ៍ថាមាន់អីវាដេញបាញ់ដេញចាប់ពេញតែភូមិអញ្ចឹងទៅ រួចដល់ពេលចេញទៅវិញវាធ្វើការឃប់អញ្ចឹងមកប្រជាជនទាំងប្រុសទាំងស្រីប្រាប់រាយការណ៍អញ្ចឹងទៅ ហើយដុតផ្ទះ បើសិនជាថាភូមិហ្នឹងមក របៀបថាកម្លាំងខាងខ្មែរក្រហមមកហ្នឹង ហើយវាមកហ្នឹងដែរ ដល់ពេលប៉ះគ្នាវៃគ្នាទៅ ហើយវៃគ្នាតែមួយប្រាវគឺភូមិមួយច្បាស់ជាដុតអាលឹងហើយ ហើយត្រូវចាប់អាឃីងអាយោងទៀតក្នុងភូមិហ្នឹង ដល់ពេលអញ្ចឹងទៅវាចេះតែបង្កើតការឈឺចាប់ ។

ដានី: អាហ្នឹងធ្វើឲ្យយើងកាន់តែមានចិត្តអង់អាចក្លាហានៗ តែមួយទៀតដូចជាមេៗ ឋានៈវរៈសេនាធំ កងពលអីដូចថាគាត់នៅជាប់សមរភូមិ ឬក៏គាត់មានគ្រោះថ្នាក់ដូចយើងដែរ ឬក៏អត់មានទេ?

នី: អានេះហៅថាតាមតួនាទី ឬក៏កម្មសិទ្ធ វាមានពេល មានពេលយ៉ាងម៉េច ឧទាហរណ៍ប្រធានអនុសេនាធំនៅនឹងខ្សែត្រៀម ក្រោយខ្សែត្រៀមបន្តិចប្រហែលជា១០០ម៉ែត្រ ឬក៏៥០-៦០ម៉ែត្រតាមភូមិសាស្ត្រ ហ្នឹងឧទាហរណ៍ថាក្នុងមួយអនុសេនាធំជំនាន់នោះគេឲ្យកាំភ្លើងម៉ាក៦០ហ្នឹងមួយដើមសម្រាប់មួយអនុសេនាធំហ្នឹង អាហ្នឹងប្រធានអនុសេនាធំហ្នឹងគឺនៅហ្នឹងហើយ ហើយចំពោះមួយវរៈសេនាតូច វរៈសេនាតូចគេនៅហ្នឹងហើយ គេចែកឲ្យកាំភ្លើងច្បាំង៨០ បើអញ្ចឹងវរៈសេនាតូចហ្នឹងនៅតាំងតេអូនៅកន្លែងកាំភ្លើងហ្នឹងហើយ ។

ដានី: ចំងាយពីសមរភូមិចូលមកតាំងតេអូហ្នឹងប៉ុន្មានទៅ?

នី: ប្រហែល៥០០ម៉ែត្រទៅមួយគីឡូដីតាមភូមិសាស្ត្រអនុគ្រោះ ហើយចំពោះប្រធានកងពលនឹងមេបញ្ជាការកងពល កាំភ្លើងជំនាន់នោះ គឺបន្តបន្ទាប់មកគឺត្រូវមានកាំភ្លើង ដូចថាកាំភ្លើង១០៥មីលីម៉ែត្រ១ដើមអញ្ចឹងគឺតំណាងឲ្យមួយកងពលហើយ ដូចនេះបញ្ជាការកងពលឬក៏អីៗសេដ្ឋកិច្ចកងពលហ្នឹងគឺនៅត្រឹមកន្លែងកងពលហ្នឹងហើយ ។ ទាល់តែពេលវៃ ហើយពេលផ្ទុះអាវុធប្រធានអនុសេនាធំគឺមកវៃបុកជាមួយគ្នា បញ្ជាការវរៈសេនាតូចគឺមកដល់ខ្សែត្រៀមកាំភ្លើង៦០របស់អនុសេនាធំហ្នឹងមក វៃមកតាមលំដាប់ថ្នាក់អញ្ចឹង ។

ដានី: វរៈសេនាធំ?

នី: បាទ! វរៈសេនាធំហ្នឹងមកដល់កន្លែងកាំភ្លើង៨០ហ្នឹងមក ហើយបើសិនជាឧទាហរណ៍ថាទាហានលន់ នល់ មានការវៃខ្លាំង ប៉ុន្តែដោយមេទេ ដោយបញ្ជាការខ្លះ បញ្ជាការខ្លះគឺកាន់កាំភ្លើងវៃជាមួយយុទ្ធជនដូចគ្នា តែមេបញ្ជាការខ្លះអត់ទេ នៅស្រែកខាងក្រោយហ្នឹងទេ ។

ដានី: នៅស្រែកខាងក្រោយហ្នឹង?

នី: បាទ!

ដានី: ចុះមេដែលវៃខ្លាំង បើតាមពូចាំមានមេណាខ្លះ?

នី: មេដែលវៃខ្លាំង ឧទាហរណ៍ដូច បូ ដែលគាត់ទៅនៅកំពង់សោមហ្នឹង ហ្នឹងវរៈសេនាតូច បូហ្នឹងមួយ ហើយបន្ទាប់មកវរៈសេនាតូចគឺមានឈ្មោះ សេង ។

ដានី: សេង ដែលនៅខាងជើងទឹកដែរហ្នឹងមែន?

នី: ហ្នឹងហើយ ។ សេង ដែលត្រូវជាបង វ៉ែន បង្កើតហ្នឹង អាហ្នឹងសុទ្ធតែត្រូវឡើងវៃជាមួយមហាជនហើយ ។

ដានី: ហើយចុះដូច គាមុត គាប៊ិត អី គាត់ដែលឡើងវិទេ?

នី: គាត់មកត្រឹមកាំភ្លើង៨០ អាហ្នឹងបើសិនជាសភាពការប្រចុចញ្ចុចខ្លាំង។

ដានី: តែបើតាមធម្មតាគាត់នៅខាងក្រោយទេ?

នី: ហ្នឹងហើយ។

ដានី: ពូតែសម្ងំបញ្ជាពីក្រោយទេ?

នី: បាទ! បញ្ជាតាមតេអូ។

ដានី: អញ្ចឹងពូមានតួនាទីត្រឹមតែប្រធានក្រុមហ្នឹងរហូតដល់បែក៧៥ ដល់ពេលវិចូលភ្នំពេញឆ្នាំ ៧៥?

នី: ក្រោយពីបែកមកភូមិឆ្នាំ៧៥ អាហ្នឹងគេដកខ្ញុំចេញពីភូមិថ្នល់ដើងហើយឲ្យមកនៅអន្តរាគមន៍ នៅកងពិសេសម្រាប់ចូលធ្វើសកម្មភាពពេលយប់ ចូលទៅធ្វើសកម្មភាពដល់ចោមចៅ ដល់ ទួលគោក ចូលទៅធ្វើសកម្មភាពយប់។

ដានី: ចុះកងអន្តរាគមន៍ហ្នឹងយ៉ាងម៉េចទៅ ហើយមានគ្នាប៉ុន្មាននាក់?

នី: កងអន្តរាគមន៍ហ្នឹងមានគ្នាមួយវរៈសេនាតូច កាលពីឆ្នាំ៧៥វិមកភូមិភ្នំពេញហ្នឹងណា៎ ហើយស្មើរហ្នឹង៣០០នាក់។

ដានី: ៣០០នាក់?

នី: បាទ! សម្រាប់ចូលធ្វើសកម្មភាពពេលយប់។

ដានី: អាហ្នឹងគេហាត់អីយ៉ាងម៉េចទៅ ដើម្បីឲ្យយើង?

នី: ហាត់។

ដានី: ហាត់យ៉ាងម៉េចខ្លះទៅដើម្បីឲ្យយើងយល់ពីសកម្មភាព?

នី: ហាត់ដើរ ឧទាហរណ៍ថាដើរធម្មតាដោយអត់មានឧបទ្ទហេតុ ក្រោយមានឧបទ្ទហេតុកើត ឡើងហើយត្រូវឲ្យផ្លាស់ប្តូរ ហើយជួបនឹងឧបស័គ្គ ត្រូវប្រើសមត្ថិភាពដែលបានឆ្លងកាត់ ដែលបានសិក្សា។

ដានី: អញ្ចឹងដែលមានគ្នា៣០០នាក់ហ្នឹង យើងមានហាត់រៀនច្រើន ឬគ្រាន់តែហាត់រៀនទ្រឹស្តីគេ ប្រាប់ចុះឡើងដែលថាយើងធ្លាប់មានបទពិសោធន៍ក្នុងការវិហើយ ហើយយើងហាត់រៀន ហ្នុងឬក៏យើងមានហាត់អី..?

នី: បាទ! ហាត់ មានដូចជា ហាត់ដើរក្នុងរដូវប្រាំង ដើរក្នុងរដូវវស្សាដែលមានទឹក ដើរក្នុងរដូវ ប្រាំងដែលស្ងួត ឬក៏មានច្រាំងស្ងួត ហើយដើររបៀបម៉េចអីយ៉ាងម៉េច។

ដានី: ហ្នឹងពីណាគេជាអ្នកបង្ហាត់?

នី៖ បង្ហាត់ហ្នឹងគ្រូគេជំនាញៗកាលពីជំនាន់ហ្នឹង ច្រើនតែគ្រូមកពីហាណូយ ។

ដានី៖ ខ្មែរយើងមកពីហាណូយមែន?

នី៖ បាទ!

ដានី៖ គេអ្នកបង្ហាត់?

នី៖ ខ្មែរមកពីហាណូយហ្នឹងគឺហាត់តាំងពីបាញ់កាំភ្លើង ។

ដានី៖ អញ្ចឹងក្នុងកងអនុរាគមន៍ក្នុងមួយវរៈសេនាតូចហ្នឹងក្រោមឲ្យកងពលទាំងអស់ឬក៏មានវរៈសេនាធំអីដែរ?

នី៖ បាទ! វរៈសេនាតូចហ្នឹងគឺនៅក្រោមការគ្រប់គ្រងរបស់កងពល ។

ដានី៖ បញ្ជាការកងពលអ្នកបញ្ជា អត់មាននៅក្រោម?

នី៖ បញ្ជាការកងពលគ្រប់គ្រងនយោបាយអីហ្នឹងនៅបញ្ជាពីកងពលធំមកហ្នុង ។

ដានី៖ ចុះពេលដែលយើងចូលធ្វើសកម្មភាពពេលយប់ ពេលចូលដល់ចោមចៅ ចូលដល់ទីក្រុងភ្នំពេញអីហ្នឹង យើងមានកាំភ្លើងមកជាមួយទេ?

នី៖ មានមួយគ្រប់ គ្រាប់បាញ់ធម្មតាហ្នឹងអត់សូវមានទេ យកមកតិចទេ យកតែគ្រាប់បែកហើយគ្រាប់បែកហ្នឹងដាក់ទៅជាប់ជាមួយខ្លួនហ្នឹងច្រើនណាស់ ហើយដាក់កន្ត្រកហើយស្រាប់ម្នាក់ៗ ។

ដានី៖ យើងដាច់ខាតហ្នុង ឧបមាថាយើងធ្វើសកម្មភាពហ្នឹង បើសិនជាខាងគេចាប់បានត្រូវតែធ្វើយ៉ាងម៉េច ដូចថាត្រូវតែធ្វើអត្តឃាតឬក៏យ៉ាងម៉េច អាហ្នឹងតាមគោលនយោបាយគេបង្រៀនយើង?

នី៖ អាហ្នឹងយើងដោះស្រាយដោយ និយាយទៅការដែលកើតមានចំពោះមុខ ដោះស្រាយតាមសមត្ថភាពរបស់ខ្លួន ឧទាហរណ៍ថាត្រូវធ្វើឃាតដោយខ្លួនឯង ឬធ្វើឃាតដោយមិនទាន់អីហ្នឹងយើងត្រូវទទួលទារុណកម្មតាមច្បាប់រៀងខ្លួន ។

ដានី៖ អញ្ចឹង?

នី៖ បាទ! ម៉ាជំនាន់ហ្នឹង កាលឆ្នាំ៧៥ហ្នឹងមួយវរៈសេនាតូចកងអនុរាគមន៍ហ្នឹង គេចាប់បានមែនតិចណា៎ ទាហាន លន់ នល់ ចាប់បានច្រើនដែរតើ ចាប់ហើយញាត់គុកព្រៃស រួចដល់ពេលរំដោះថ្ងៃ១៧ហ្នឹងក៏បានទៅដោះចេញមក ។

ដានី៖ តែ លន់ នល់គេអត់មានសម្លាប់មានអីដែរ គ្រាន់តែ?

នី៖ អត់ទេ គ្រាន់តែឆក់ខ្សែភ្លើងហើយនឹងសួរចម្លើយ ។

ដានី៖ អញ្ចឹង លន់ នល់ ចាប់បានច្រើនដែរអញ្ចឹង?

នីៈ ចាប់បានច្រើន អត់មានសម្ងាប់ទេ ។

ដានីៈ អញ្ចឹងដល់ពេលពួមកខាងកងអន្តរាគមន៍ហ្នឹងអត់មាននេះ យើងធ្វើការដែរយប់ទេ អត់មានធ្វើការពេលថ្ងៃទេ?

នីៈ បាទ! ធ្វើការតែយប់ទេ ថ្ងៃសម្រាក ។

ដានីៈ ហើយយើងចូលទៅធ្វើម៉េចដើម្បីយើងយកការណ៍?

នីៈ គេឲ្យចូលទៅរបៀបថាយកការណ៍អញ្ចឹងក៏បានដែរ ចូលទៅហ្នឹងចូលទៅស៊ើប ឧទាហរណ៍ថាតាមកំណាត់ផ្លូវលំនេះ ពីនោះមកនេះតាមការប៉ាន់ប្រមាណមានប្រហែលប៉ុន្មាន មានប្រហែលប៉ុន្មានគីឡូដី បើអញ្ចឹងទីតាំងរបស់ទាហានហ្នឹងគឺវាវាយគ្នានៅគំលាតប៉ុន្មានៗ បើសិនជាទៅឃើញទីតាំងតាំភ្លើងធំ ហើយអូសកម្លាំងទៅវ៉ៃ បើអញ្ចឹងត្រូវកម្លាំងតាមច្រកណាបាន ការធ្វើដំណើរស៊ើបយប់ៗហ្នឹងគឺអញ្ចឹងឯង ព្រោះភ្នំពេញគម្រោងការចូលទៅហ្នឹងបើសិនជាវ៉ៃហ៊ុំព័ទ្ធធ្វើមិនបែក ត្រូវរៀបចំកម្លាំងអន្តរាគមន៍ហ្នឹងចូលទៅវ៉ៃផ្តាច់រីក ។

ដានីៈ អ៎! វ៉ៃពីក្នុងចេញវិញ?

នីៈ ចា៎! វ៉ៃបំបែកទីបញ្ជាការ ដល់ពេលអញ្ចឹងទៅក៏ទទួលលើកជ័យទង់សហ្នឹងបានមុន ព្រោះវាដល់ខែ៤ហើយ អាហ្នឹងវាជិតដល់រដូវធ្លាក់ភ្លៀងហើយ ដល់រដូវធ្លាក់ភ្លៀងវាលំបាកការចល័ត ជាកម្លាំងទ័ពក៏ដោយ ជាស្បៀងក៏ដោយគឺវាលំបាកគ្រប់មុខ ដល់អញ្ចឹងធ្វើមិនឲ្យឆ្លងផុតរដូវរាំងស្ងួតទេ ត្រូវបញ្ចប់ក្នុងឆ្នាំហ្នឹង ។

ដានីៈ អញ្ចឹងភាគច្រើនខែវស្សាអីហ្នឹងគេអត់វ៉ៃទេ?

នីៈ គេអត់វ៉ៃទេ ទោះបីជាវ៉ៃតាមដងផ្លូវជាតិក៏ដោយ គឺច្រើនតែធ្វើសកម្មភាព ឧទាហរណ៍ថាឡើងទៅធ្វើការអញ្ចឹងទៅ ទៅដល់ទៅឃើញទាហានយាមអីអញ្ចឹងទៅ បាញ់នាយអាយរំខានអញ្ចឹងទៅហើយគេដកវិញហើយ ហើយកម្លាំងផ្លាស់ប្តូរគ្នា ឧទាហរណ៍ថាព្រឹកនេះខ្ញុំចេញដំណើរទៅធ្វើការអញ្ចឹង ទៅវ៉ៃឈ្លប ទៅបាញ់ធ្វើសកម្មភាពអញ្ចឹងហើយដកមកវិញ ឯកម្លាំងដែលនៅតាមក្រុមតាមអនុសេនាតូចនៅខាងក្រោយគឺរៀន រៀនបច្ចេកទេសសម្រាប់ត្រៀមដល់រដូវប្រាំង ។

ដានីៈ កាលហ្នឹងពូចូលកងអន្តរាគមន៍ហ្នឹងខែប៉ុន្មាន ហើយឆ្នាំណាទៅ?

នីៈ កងអន្តរាគមន៍ហ្នឹង ថ្ងៃ១ ខែ១ ឆ្នាំ៧៥ចាប់ផ្តើមផ្ទុះអាវុធ ផ្ទុះអាវុធហ្នឹងអត់ទាន់បានរៀបនៅឡើយទេកម្លាំងហ្នឹង វ៉ៃចូលមួយព្រឹកសិន វ៉ៃហ្នឹងរបៀបដូចគៀងចកអញ្ចឹង ចូលទៅអាចូលចំមុខព្រួញវាចូលទៅ តែអាខាងៗនោះចូលមិនបាន ចុះបើឧទាហរណ៍ថាមុខសញ្ញាខ្ញុំចូលតាមច្រកជិនាងជិទាវម៉ៅ ហើយសំដៅមកកំបូល ហើយមកបោមចោ ដល់ពេលសំដៅ

មកអញ្ចឹងមុខសញ្ញាខុសពីហ្នឹងគឺទាហានព័ទ្ធសងខាង ដល់ពេលព័ទ្ធសងខាងអញ្ចឹងដាច់ស្បៀង អាហ្នឹងផ្តល់ផ្គត់ផ្គង់ស្បៀងយកទៅមិនបាន អញ្ចឹងដកមកវិញហើយបានចាប់ផ្តើមរៀប តែមិនចាំថ្ងៃខែទេ ដល់ពេលអញ្ចឹងបានបង្កើតជាកម្លាំងអន្តរាគមន៍ហ្នឹងជ្រើសរើសកម្លាំងតាមវរៈសេនាតូច តាមអនុសេនាធំ អ្នកដែលមានថ្វីដៃយកមកបញ្ចូលជាកងអន្តរាគមន៍ ហើយដាក់លេខជាកង៥៥០ វរៈសេនាតូច៥៥០ ។

ដានី៖ ពីណាគេប្រធានវរៈសេនាតូច?

នី៖ ប្រធានវរៈសេនាតូចហ្នឹងឈ្មោះអីទេ តែគាត់ស្លាប់បាត់ហើយ ឈ្មោះ ធាន ៗ ធាន ហ្នឹងគាត់នៅខាងកំពត ។

ដានី៖ គាត់មានស្នាដៃដែរ?

នី៖ បាទ! គាត់អតីតវរៈសេនាតូច មេបញ្ជាការវរៈសេនាតូច រឿងរ៉ៃគឺខ្លាំងណាស់ គ្រាន់ថារថក្រោះទាហានមក រឿងកាំភ្លើងកាលជំនាន់នោះគឺបាញ់ប្រឆាំងជាមួយរថក្រោះទាហានលន់ នល់ គឺប្រើតែដីការ៨២បាញ់ ដីការ៨២ហ្នឹងបាញ់ជាមួយខ្ញុំនៅជិតជំទាវម៉ៅ កាលហ្នឹងបាញ់គ្រាប់មាន៨គ្រាប់ ហើយបាញ់អស់៧គ្រាប់ បាញ់មិនត្រូវទាហាន បាញ់មិនត្រូវរថក្រោះ ចុះបើលីបាញ់ មែនដូចយើងឥលូវនេះទេ ដល់ពេលអញ្ចឹងជជែកគ្នាមួយពីរៗខ្ញុំថាអត់ទេបងអស់គ្រាប់ហើយ ហើយរថក្រោះទាហានវាជាន់ផ្តាច់សែវៀនយើងហ្នុង ជាន់ត្រង់សេ អាណារត់រួចក៏រួចអាណារត់មិនរួចគឺមិនរួច ហើយអាណារត់មិនរួចគឺនៅជាន់ជាប់ ដល់ពេលអញ្ចឹងថា អេ៎ នៅមួយគ្រាប់មិនកើតទេ ហើយលើកដាក់លើដើងដុកៗ ចាប់កែវតម្រង់ហើយបាញ់តែមួយគ្រាប់ហ្នឹងឆេះ ។

ដានី៖ គាត់អ្នកបាញ់?

នី៖ បាទ! ធាន ហ្នឹងគាត់អ្នកបាញ់ហ្នុង ដល់ពេលបាញ់ឆេះហ្នឹងក៏ទាហានហ្នឹងបាក់ទៅវិញទៅរួចហើយបានដកហូតគាត់ហ្នឹងមកឲ្យកាន់វរៈសេនាតូច៥៥០ ។

ដានី៖ កាលហ្នឹងពូមានតួនាទីអីដែរ?

នី៖ ខ្ញុំមកដល់ហ្នឹងមានតួនាទីជាប្រធានពួកវិញ ។

ដានី៖ តូចវិញអញ្ចឹង?

នី៖ តូច ។

ដានី៖ កាលមុនយើងក្រុម ដល់ពេលមកពួកមានគ្នាតែ៣នាក់?

នី៖ បាទ!

ដានី៖ ម៉េចអញ្ចឹង?

នី៖ តាមកម្លាំង ព្រោះកម្លាំងពីអន្តភាពពីកងនាៗមក ជ្រើសរើសមនុស្សគេសុទ្ធតែមានតួនាទីស្រាប់មកដែរ ។

ដានី៖ អញ្ចឹងពួចូលទៅក្នុងទីក្រុងភ្នំពេញច្រើនដងដែរ?

នី៖ ចូលហ្នឹង បើនិយាយទៅថាវាខានយប់តិចណាស់ ដោយឡែកថាយើងអត់ស្រួលខ្លួនផងឧទាហរណ៍ថាគ្រុនឈឺអីនាយអាយ អាហ្នឹងអត់ចូលទេ អាហ្នឹងសម្រាកហើយ ។

ដានី៖ ហើយពូអត់ដែលមានខាងលន់ នល់ អីចាប់បានទេ?

នី៖ អត់ដែលទេ ។

ដានី៖ គេអត់ដឹងហ្នង?

នី៖ គេដឹងច្រើនដងដែរហ្នឹង តែយើងចេះតែរួចខ្លួនរហូត ដើរទៅទាត់មីងក្លេម័រគេ ទាត់អាគ្រាប់ធ្លាក់បែកភ្លើងគេឆេះភ្លឺរត់ ។

ដានី៖ ទាត់មីនក្លេម័រហ្នឹងអត់ផ្ទុះទៀត?

នី៖ ផ្ទាត់ផ្ទុះ ចុះទាហានគេសុទ្ធតែដាក់ផាយ វាដាក់ថ្មគេអូអា២៥ ប៉ុន្តែវាទាក់អញ្ចេះ ខ្សែវាដាក់ពីរួមគ្នាអញ្ចឹង មិនទាក់អាខាងមុខវា តាមមើលទាហានហ្នឹងវាអាចដាក់ប្រឡាំ វាដាក់បែខ្លងមីនមួយខ្សែ ដល់ពេលអញ្ចឹងយើងទាក់ទៅ ។

ដានី៖ អត់ត្រូវយើង?

នី៖ បាទ! ខុសត្រូវគ្នាប្រហែល២ម៉ែត្រ ព្រាកអានិតមុខឈឹង ថាត្រូវគ្នាសល់ហើយមើលទៅហើយប្រាំងដាក់តាមវាលស្រែ ប្រាំងហុយជាប់ពេញខ្លួនពេញក្បាលទាំងអស់ ។

ដានី៖ ផ្ទុះហ្នង?

នី៖ ផ្ទុះបែកភ្លើងព្រាក ចុះរឿងមីនរឿងគ្រាប់អីតែមកជិតអញ្ចឹងវាអត់ព្ទសូវរំពងអីដូចយើងរឿងគ្រាប់ធ្លាក់ព្ទខ្លាំងនៅឆ្ងាយពីយើងទេ តែបើមកជិតអត់សូវព្ទទេ របៀបដូចស្រម៉ែម៉េចមិនដឹង ។

ដានី៖ ហើយអត់មានត្រូវអីដែរ?

នី៖ អត់ ។

ដានី៖ ចុះអ្នកដែលគេចាប់បានហ្នឹងចាប់បានច្រើនទេ នៅក្នុងវរៈសេនាតូចរបស់ពូនៅក្នុងកងអន្តរាគមន៍?

នី៖ វរៈសេនាតូចហ្នឹងចាប់បានគ្នាប៉ុន្មាននាក់ទេ ប្រហែលជា៨នាក់ ។

ដានី៖ ចាប់ហើយគេយកទៅដាក់នៅព្រៃស?

នី៖ បាទ! គេយកទៅដាក់នៅព្រៃស ។

ដានី៖ អញ្ចឹងដល់ពេលវ៉ៃចូលភ្នំពេញឆ្នាំ៧៩ហ្នឹង ពេលដែលពួចូលហ្នឹងចូលតាមមុខព្រួញពោធិ៍ចិនតុង?

នី៖ បាទ! តាមពោធិ៍ចិនតុងខាងជើងផ្លូវ ។

ដានី៖ ខាងជើងផ្លូវ?

នី៖ ខាងជើងផ្លូវលេខ៤ ។

ដានី៖ ចុះខាងត្បូងផ្លូវ?

នី៖ ខាងត្បូងផ្លូវកងពលទី២ ។

ដានី៖ ចុះកងពលខាងភូមិភាគពិសេស?

នី៖ ភូមិភាគពិសេសចូលតាមខាងត្បូង និយាយទៅគឺថាខាងកើតផ្លូវលេខ២ចាប់ពីវត្តស្ទឹងទេ គេចែកគ្នាហ្នឹងភូមិភាគពិសេស ត្រឹមពីចំហៀងផ្លូវជាតិលេខ២មកលិចគឺភូមិភាគនារតី មកផ្លូវជាតិលេខ៤ខាងជើងផ្លូវលេខ៤ទៀតអាហ្នឹងភូមិភាគនារតី ព្រោះភូមិភាគហ្នឹងមានកងទ័ពច្រើនជាងគេ ។

ដានី៖ ភូមិភាគនារតីមានកងទ័ពច្រើនជាងគេ?

នី៖ បាទ!

ដានី៖ ចុះដល់ពេលយើងចូលដល់ទីក្រុងភ្នំពេញហើយយ៉ាងម៉េចពេលហ្នឹង?

នី៖ ចូលដល់ទីក្រុងភ្នំពេញអត់មានអីទេ ចូលដល់ទីក្រុងភ្នំពេញបើគិតទៅចូលបានតែមួយថ្ងៃ ចូលនៅហ្នឹងគឺមានតែភូមិភាគពិសេសទេ ឯភូមិភាគនារតីអត់មានទេ ចូលទៅមួយព្រឹកបានតែមួយថ្ងៃទេ ឈ្នះពីម៉ោង៨ ។

ដានី៖ ៨ព្រឹក?

នី៖ បាទ! ម៉ោង៨ប៉ុន្មាននាទីទេ រួចហើយចូលមួយព្រឹក ហើយខ្ញុំចូលទៅដល់ពោធិ៍ចិនតុងពួកនារសោកងពលតាមទៅហៅមកវិញអស់ ដល់ពេលតាមទៅហៅទៅមកសម្រាកនៅនឹងកំបូលអត់ឲ្យសម្រាកនៅចោមចៅទេព្រោះចោមចៅសុទ្ធតែគ្រឿងចក្រធ្ងន់ សុទ្ធតែអាគ្រាក់ សុទ្ធតែអីធ្ងន់ ហើយពួកមិត្តទៅសម្រាកហ្នឹងក្រែងលោដោះខ្មៅខ្ទីអស់ ដល់ពេលអញ្ចឹងក៏ឲ្យមកសម្រាកនៅកំបូល ហើយកំបូលអត់មានអីទេ មានតែទាហាន មានតែខ្លាំងខោអាវ ខ្លាំងសម្ភារៈទាហានហ្នឹងគ្រប់មុខ តាំងកន្ត្ធទឹក ស្បែកជើង អាវភ្លៀវមានមួយចប់នៅកំបូលហើយឲ្យមកសម្រាកនៅកំបូល សម្រាកនៅកំបូលដូចជា៣យប់បើមិន៣យប់គឺ៤យប់ រួចឲ្យចេញដំណើរមកកំពង់សោម មកដោយដើរហ្មង់ព្រោះអត់មានឡាន ។

ដានី៖ ដើរមកហ្មង?

នី៖ ដើរ ។

ដានី៖ ចុះពូអ្នកដែលជាប់នៅព្រៃសហ្នឹង យើងចូលទៅដោះនៅពេលហ្នឹងឬក៏?

នី៖ ចូលទៅដោះនៅពេលហ្នឹង?

ដានី៖ ៨នាកលក្រុមរបស់ពូហ្នឹងមែន?

នី៖ មិនមែន៨នាក់សម្រាប់មួយកងពលហ្នឹងទេ មិនមែនមួយវរៈសេនាតូចហ្នឹងទេណា៎ ប៉ុន្តែកងពលផ្សេងៗច្រើនទៀត ។

ដានី៖ ច្រើនទៀត?

នី៖ រាប់រយណា៎ បើជាទូទៅគឺរាប់រយ គេយកទៅញាត់ហ្នឹងទាំងអស់ហ្នឹង ។

ដានី៖ ដល់ពេលដោះមកយ៉ាងម៉េចទៅ គេបញ្ចូលក្នុងអង្គភាពយើងវិញ?

នី៖ ដល់ពេលមកវិញគេយកមកបញ្ចូលក្នុងអង្គភាពយើងវិញ ខ្លះវាទៅជាអាឡេអាឡឺទៅក៏មានដែរ ព្រោះឆក់ខ្សែភ្លើងឆក់អី ដល់ពេលអញ្ចឹងវាទៅជាអាឡេអាឡឺវង្វេងវង្វាន់អស់ទៅលែងសូវដឹងអីក៏គេបញ្ជូនឲ្យទៅនៅមន្ទីរពិការ ហើយអង្គភាពពិការមិនមានតាមកងពលឧទាហរណ៍ថាកងពលទី២ត្រូវមានមួយកន្លែងទៅ កន្លែងណានៅតាមដងផ្លូវជាតិលេខ៣នៅត្រាមខ្នា ហើយក៏គេបញ្ជូនឲ្យទៅនៅត្រាមខ្នាអញ្ចឹងទៅ ។

ដានី៖ អញ្ចឹងពូនៅបានមួយថ្ងៃយើងត្រូវដើរថ្មើរជើងមកកំពង់សោមហ្នង?

នី៖ ចេញមកកំពង់សោម ហើយមកដល់បន្ទាយដោះកញ្ចោមិនទាន់បែកវើបន្ទាយដោះកញ្ចោហ្នឹង៣យប់៣ថ្ងៃទៀត វើដោះកញ្ចោ៣យប់៣ថ្ងៃហើយ វើមិនបែក គ្រាន់វារបៀបថាវាបាញ់គ្នាវានៅក្នុងហ្នឹង ទាហានហើយនឹងទាហានបាញ់គ្នាណា៎ ។

ដានី៖ ម៉េចអញ្ចឹង?

នី៖ រឿងពីខាងក្រៅវើហ៊ុំព័ទ្ធហើយចចារ ដល់ពេលអញ្ចឹងមួយប៉ែកវាចង់ចចារ ហើយមួយប៉ែកទៀតវាអត់ ដល់ពេលអញ្ចឹងវាបាញ់គ្នាវា ដល់ពេលបាញ់គ្នាវាអញ្ចឹងដកកម្លាំងចេញហើយរៀបចំដំណើរទៅកំពង់សោម ។

ដានី៖ កាលហ្នឹងបន្ទាយដោះកញ្ចោហ្នឹងខាងទាហានលន់ នល់ ពីណាគេមេនៅហ្នឹង?

នី៖ បើនិយាយពីមេហ្នង បញ្ជានៅហ្នឹងហ្នងគឺ ចាន់ រាំងសី ។

ដានី៖ នៅដោះកញ្ចោ?

នី៖ បាទ! អាហ្នឹងបែកក្រោយ ។

ដានី៖ កងពលឬក៏ស្អីគេនៅហ្នឹង?

នី៖ គេថាវរៈសេនាធំ ។

ដានីៈ អញ្ចឹងក្រុមដែលពូដកទៅវិញហ្នឹង កងពលទី៤ហ្នឹងឬក៏យ៉ាងម៉េច?

នីៈ កងពលទីដកទៅដល់ទៅ ដល់ពេលវ៉ៃភ្នំពេញហ្នឹង៥៥០ហ្នឹងមកវិញគេឲ្យមកនៅកងពលទី៣វិញ ។

ដានីៈ អ៎! គេឲ្យពូមកនៅកងពលទី៣វិញ?

នីៈ បាទ! ព្រោះកងពលទី៣ហ្នឹងត្រូវមានមុខសញ្ញាមកកាន់កាប់នៅកំពង់សោម ។

ដានីៈ អញ្ចឹងពេលណាដែលពូដកចេញពីវរៈ៥៥០មកចូលនៅក្នុង?

នីៈ ចប់ភ្នំពេញហ្នឹង ។

ដានីៈ ចប់សមរភូមិភ្នំពេញហ្នឹង?

នីៈ បាទ!

ដានីៈ ហើយពេលដែលចប់ហ្នឹងវរៈ៥៥០ហ្នឹងរំលាយចោល?

នីៈ បាទ! រំលាយចោល វរៈ៥៥០ហ្នឹងអញ្ចេះ ពេលដែលនេះហើយគេឲ្យទៅតាមកងពលទី៣ កម្លាំងមួយវរៈសេនាតូចហ្នឹង ទៅដល់មានមុខសញ្ញា៥៥០ហ្នឹងគឺត្រូវទៅឈរជើងនៅក្នុងឃ្លាំងក្បាលផែសមុទ្រកន្លែងកប៉ាល់ចេញចូលហ្នឹង ហើយទៅនៅហ្នឹង ទៅដល់កង៥៥០ហ្នឹង គេផ្លាស់វិញហើយ គេប្តូរគេវិញ គេឲ្យធ្វើជាកងនាវាចរណ៍ ។

ដានីៈ ធ្វើកងនាវាចរណ៍?

នីៈ បាទ!

ដានីៈ ចុះពេលដែលដំបូង ពេលដែលវ៉ៃចូលទីក្រុងភ្នំពេញហ្នឹង កងវរៈ៥៥០ហ្នឹងនៅក្នុងកងពលណា នៅក្នុងកងពលទី៤ឬក៏កងពលទី៣?

នីៈ ត្រូវការបញ្ចូលរួម ព្រោះកម្លាំងវាចម្រុះគ្នា ។

ដានីៈ រួមទាំងកងពលទី៤?

នីៈ បាទ! ដល់ពេលចប់សមរភូមិហើយ កងពលលេខ៥គេឲ្យមកខាងផ្លូវជាតិលេខ៥ គេប្រគល់ឲ្យមកខាងពាយ័ព្យនឹងបច្ចឹម ឯចំពោះកងពលទី៣នោះគឺផ្លូវជាតិលេខ២ ផ្លូវជាតិលេខ៣ ផ្លូវជាតិលេខ៤គឺមានកងពលទី២ នៅក្រោមឪវាទរបស់ តាម៉ុក ឯចំពោះកងពលទី៣នេះគឺដកចេញពីភូមិភាគដាច់ប្រគល់ឲ្យទៅឈរជើង ពួកខាងកំពង់សោមដោយការគ្រប់គ្រងពីមជ្ឈិមបក្ស ។

ដានីៈ គ្រប់គ្រងពីមជ្ឈិមបក្ស?

នីៈ បាទ!

ដានីៈ តែកងពលទី៣ហ្នឹង តាមុត ធ្វើប្រធាន?

នីៈ	តាមុត គាត់អ្នកធ្វើប្រធាន ដល់ពេលទៅដល់នោះរៀបជានាវាចរណ៍សម្រាប់វរៈសេនាតូច ៥៥០ហ្នឹង រៀបអញ្ចឹងទៅរួចបានចាប់ផ្តើមបង្កើតកងជើងទឹក ដល់ពេលបង្កើតកងជើងទឹកអញ្ចឹងដកមនុស្សមួយចំនួន អាហ្នឹងខ្ញុំនិយាយរំលងហើយ កាលពីមុនដំបូងចេញពីភ្នំពេញទៅ ទៅដល់កំពង់សោម ដល់កំពង់សោមចាប់ផ្តើមដកកម្លាំង៥៥០ហ្នឹងទៅវ៉ៃកោះត្រល់ ចូលទៅវ៉ៃមុនដំបូងចូលទៅវ៉ៃកោះពោ៉វ៉ៃ ហើយនឹងកោះតាំង វ៉ៃកោះពោ៉វ៉ៃហ្នឹងមុន ហើយបាញ់ខ្ទម្ភកាគចក្រធ្លាក់អស់៤គ្រឿង វ៉ៃហ្នឹងហើយរួចដកពីហ្នឹងឲ្យកម្លាំងមួយចំនួននៅការពារហ្នឹង នៅកោះពោ៉វ៉ៃដែលមានវ៉ៃប្រេងហ្នឹង ដែលមានអណ្តូងប្រេងហ្នឹង ទៅវ៉ៃពួកវៀតគី អស់ពីហ្នឹងទៅរួចក៏ដកកម្លាំងមួយចំនួនមកវ៉ៃកោះត្រល់ គម្រោងការការថាវ៉ៃរំដោះយកកោះត្រល់ហ្នឹង ដល់ពេលទៅកោះត្រល់វាបែកការ ហើយកម្លាំងទាំងប៉ុន្មានគេចាប់អស់ រត់រួចមួយចំនួន ហើយខ្ញុំហ្នឹងក៏បានរត់រួចដែរ ដោយបានដូងទុំ២ផ្លែយកមក ។

ដានីៈ	អញ្ចឹង?

នីៈ	ចុះបើទៅដល់ហ្នឹងឲ្យទៅវ៉ៃធ្វើម៉េច បើស្បៀងអត់មាន ហើយដើរតែកាប់ដូងទុំបុសដុសៗកាប់យកការពីងហ្នឹង ។

ដានីៈ	អញ្ចឹងពេលដែលដើរពីភ្នំពេញទៅដល់កំពង់សោមហ្នឹង វរៈរបស់ពូ៥៥០ហ្នឹងគេឲ្យតែមួយវរៈទេទៅវ៉ៃនៅកោះពោ៉វ៉ៃ ហើយនឹងកោះកោះត្រល់?

នីៈ	គេយកកម្លាំងមួយវរៈហ្នឹង ហើយគេជ្រើសរើសកម្លាំងតាមវរៈសេនាតូចទៀតដើម្បីបន្ថែមកម្លាំង ព្រោះត្រូវការបន្ថែមកម្លាំងទៀត ព្រោះមកភ្នំពេញហ្នឹងអស់មួយផ្នែកហើយ បើអញ្ចឹងគ្រាន់តែយកកម្លាំងហ្នឹងទៅ ឧទាហរណ៍ថាវ៉ៃបើកផ្លូវឈាម នោះគេយកកម្លាំងហ្នឹងយកទៅដាក់មុខព្រួញសម្រាប់វ៉ៃ ។

ដានីៈ	បើតាមកម្លាំងវ៉ៃនៅតាមកោះហ្នឹងប៉ុន្មានទៅ?

នីៈ	កម្លាំងវ៉ៃតាមកោះប្រហែល៣០០នាក់ ។

ដានីៈ	ពីណាគេជាអ្នកបញ្ជាឲ្យទៅវ៉ៃ?

នីៈ	បញ្ជាឲ្យទៅវ៉ៃមាន មុត អ្នកបញ្ជា ហើយមាន បូ ហ្នឹងឯងប្រធានវរៈសេនាតូចអ្នកដឹកនាំវ៉ៃ

ដានីៈ	អ្នកដឹកនាំវ៉ៃទៅខាង?

នីៈ	ទៅកោះ ។

ដានីៈ	ដំបូងវ៉ៃនៅកោះណា?

នីៈ	វ៉ៃនៅកោះពោ៉វ៉ៃ ។

ដានីៈ	នៅកោះពោ៉វ៉ៃ ហើយថាបាញ់ធ្លាក់យន្តហោះ?

នី៖ ឧត្តមភាគបក្ររបស់អាមេរិចហ្នឹងមកជួយគាំទ្រទាហានដែលនៅឈរជើងការពារអណ្តូងរ៉ែ ។

ដានី៖ ទាហានរបស់ពីណាគេ?

នី៖ ទាហានយួនខាងត្បូង ។

ដានី៖ របស់ធៀវគីហ្នឹង?

នី៖ បាទ!

ដានី៖ យើងបាញ់ផ្លាក់៤?

នី៖ បាញ់ផ្លាក់៤ ។

ដានី៖ អញ្ចឹងយើងគ្រប់គ្រងនៅកោះពោរ៉ាវ៉ៃហ្នឹង?

នី៖ បាទ! ព្រោះកោះពោរ៉ាវ៉ៃហ្នឹងវាកៀកនឹងខ្សែស្រប ខ្សែស្របផ្ទៃទឹករបស់ផ្លូវអន្តរជាតិ វាជិតខ្សែស្របហ្នឹង ។

ដានី៖ អញ្ចឹងកាលហ្នឹងកម្លាំងរបស់ពូទៅវ៉ៃដែរកាលហ្នឹង?

នី៖ ទៅ ។

ដានី៖ ហើយពូមានបានចូលរួមទៅវ៉ៃនៅហ្នឹងដែរ?

នី៖ ខ្ញុំនៅកំពង់ផែ ។

ដានី៖ ពូនៅកំពង់ផែ?

នី៖ កម្លាំងនៅការពារកំពង់ផែហ្នឹង គ្នា១៦នាក់ ហើយកាលហ្នឹងការមិនទុកចិត្តវានៅតែមិនទុកចិត្ត កាលហ្នឹងអត់ហ៊ានទុកកម្លាំងតិចពេកទេ ដោយមានកម្លាំង៥៥០មួយចំនួនតូច ហើយនឹងមានកម្លាំងតាមវរៈសេនាធំនោះមកជួយសហការណ៍មួយចំនួនទៀត ពីព្រោះកម្លាំងវានៅច្របូលច្របល់ ចុះអតីតកម្មករចាស់គឺនៅលុបពេញណែនទាំងអស់ ដល់ពេលអញ្ចឹងយើងមិនទុកចិត្តខ្លាចក្រែងលោមានកម្លាំងណាចង់ធ្វើបាប ផ្តាច់ដៃទៅវាចប់បាត់ទៅហើយ ។

ដានី៖ អញ្ចឹងទុកឲ្យនៅការពារ?

នី៖ បាទ!

ដានី៖ អញ្ចឹងពូអត់មានបានទៅកោះទេ?

នី៖ កោះត្រល់បានខ្ញុំបានទៅ ។

ដានី៖ ពូកន្លែងនៅកោះត្រល់ហ្នឹងយ៉ាងម៉េច?

នី៖ កោះត្រល់ទៅកាណូត ពេលទៅដល់គេប៉ាន់មើលថាផ្លូវ គេលាដែនទីលាអីមើលគេវាស់អីហើយផ្លូវនៅ២គីឡូទៀតដល់ច្រាំង អញ្ចឹងឲ្យយើងចុះហ្នឹងហើយ ។

ដានី៖ ឲ្យយើងចុះហែលទឹក?

នី៖ បាទ! ឲ្យយើងចុះហែលទឹក ។

ដានី៖ យើងមានអីសម្រាប់ហែលទឹកទេ?

នី៖ មានពងខ្លះ ហើយមានកន្ទុងខ្លះ ។

ដានី៖ ហើយហែលស្ពាយកាំភ្លើងកាំភ្លើងស្ពាយអីទៅ?

នី៖ បាទ! កាំភ្លើងមួយកាំប៉េ ។

ដានី៖ ហើយកាំភ្លើងពេលដែលត្រូវទឹកហ្នឹងបាញ់ទៅអត់អីទេ?

នី៖ អត់អីទេ ឲ្យតែបានចេញផុត ។

ដានី៖ តែគ្រាប់ហ្នឹងពេលត្រូវទឹកអត់មានអីទេ?

នី៖ អត់អីទេ ។

ដានី៖ ចុះអ្នកដែលកាន់កាំភ្លើងធំៗ ដូចបេអា៦០-៨០អីហ្នឹងម៉េចទៅ?

នី៖ អត់មានទេ យកទៅត្រឹមតែបេ៤០ ។

ដានី៖ អញ្ចឹង២គីឡូទៀតទៅដោះកោះតាន់គេឲ្យយើងចុះពីកាណូតហែល?

នី៖ បាទ!

ដានី៖ ហើយកាលនោះកោះតាន់ហ្នឹងយ៉ាងម៉េច បានជាយើងទៅវ៉ៃនៅកោះតាន់?

នី៖ កោះតាន់ហើយនឹងកោះពោរ៉ាវ៉ៃហ្នឹងវានៅជិតគ្នា នៅជិតគ្នាអញ្ចឹងបើសិនជាវ៉ៃតែកោះមួយហើយកោះមួយទៀតមិនវ៉ៃនៅមិនបាន ហើយម្យ៉ាងទៀតនៅកោះតាន់ហ្នឹងកោះខ្មែរយើងដែរ បើអញ្ចឹងទាល់តែយកទាំងអស់បានៗ បានគេថាលក្ខណៈបោសសម្អាត ។

ដានី៖ ចុះនៅលើកោះតាន់ហ្នឹង ពួវ៉ៃជាមួយអ្នកណាគេ?

នី៖ នៅលើកោះតាន់ហ្នឹងវ៉ៃជាមួយទាហានវៀតគី ។

ដានី៖ ចុះពួកលហ្នឹងពូអត់មានដឹងថាគេចាប់កប៉ាល់អាមេរិចកាំងទេ?

នី៖ ចាប់កប៉ាល់ម៉ាយីកេស ។

ដានី៖ កាលហ្នឹងពូមានបានចូលរួមពេលដែលគេចាប់កប៉ាល់ម៉ាយីកេសទេ?

នី៖ ឃើញ ហើយយកទៅដល់កំពង់ផែយើងហ្នុង ។

ដានី៖ ប៉ុន្តែម៉ាយីកេសហ្នឹង ចាប់ពីកោះណាមក?

នី៖ ចាប់ពីកោះអី កប៉ាល់ម៉ាយីកេសហ្នឹងគឺរត់ពីផ្លូវអន្តរជាតិ ប៉ុន្តែដោយឡែកអតីតទាហានហ្នឹងទាហានខ្មែរក្រហមយើងហ្នឹង វាអត់ធ្លាប់បានឆ្លងកាត់រៀន អត់បានសិក្សារឿងដែនទឹករបៀបម៉េច ហើយដែនទីគោករបៀបម៉េច ទ័ណ្ឌសីមារវាងប្រទេសត្រឹមម៉ាន ហើយផ្លូវ

អន្ទរជាតិសម្រាប់ឆ្លងកាត់ហ្នឹងចំនុចណាៗវាអត់ដឹង ម្ហោះហើយពេលដែលទៅឈរជើងនៅកោះពោ៉វៃហ្នឹងក៏ឃើញកប៉ាល់ហ្នឹងវាមកសន្ទឹងហ្នឹងក៏ទៅក្អង់ ។

ដានី: អញ្ចឹងយើងវៃកាន់កាប់ហើយបានទៅចាប់កប៉ាល់ហ្នឹងក្រោយ?

នី: បាទ!

ដានី: វៃកោះតាន់ ហើយវៃកោះពោ៉វៃហ្នឹងអស់បាន?

នី: វៃហើយអស់ ។

ដានី: ពេលណាដែលចាប់កប៉ាល់ម៉ាយ៉ាកេសហ្នឹងបាន ប្រហែលជាបែកភ្នំពេញបានរយៈពេលប៉ុន្មានទៅ?

នី: បានយូដែរ ប្រហែលជាជិតមួយខែ ដូចជា២០ថ្ងៃ ។

ដានី: បាន២០ថ្ងៃដែរ?

នី: បាទ!

ដានី: ពេលដែលបែកភ្នំពេញហើយយើងមានផែនការភ្លាមៗដើម្បីទៅវ៉ៃយកកោះពីរហ្នឹង គឺកោះពោ៉វៃហើយនឹងកោះតាន់ហ្នឹងហ្មង?

នី: អត់ទាន់ដឹងនៅឡើយទេ ចេញពីភ្នំពេញទៅ ដឹងតែទីតាំងនៅដោះកញ្ចោធំមួយទេដែលមិនទាន់បែល អាហ្នឹងទីតាំងសម្រាប់ទាហាន លន់ នល់ ហើយនឹងគេប្រាប់ថាកំពង់សោមក៏មិនទាន់រៀបរយដែរនៅកំពង់ផែហ្នឹង ដល់រួចហើយគ្រាន់តែធ្វើដំណើរទៅដល់កំពង់សីលា ក៏គេតេអូប្រាប់ថាអស់ហើយ ដកកម្លាំងអស់ហើយ មកដល់វាលរេញមកដល់អីអស់ហើយ អញ្ចឹងក៏ថាវាអស់ហើយ ដល់ពេលទៅដល់កំពង់សោមហ្នឹងបានមានសារប្រាប់ថា និយាយទៅចាប់ទាហាននៅកំពង់សោមហ្នឹងបានគេប្រាប់ ។

ដានី: ចាប់ទាហានលន់ នល់?

នី: បាទ!

ដានី: វាប្រាប់ថាម៉េច?

នី: វាប្រាប់ថានៅកោះតាន់ ហើយនឹងកោះពោ៉វៃនៅ តែមិនមែនជាទាហានលន់ នល់ ទេគឺដោយទាហានធៀវគី ដល់ពេលអញ្ចឹងក៏រៀបចំកម្លាំងទៅវៃ ។

ដានី: វៃហើយយើងគ្រប់គ្រងបានទាំងពីរកោះហ្នឹងទៅ?

នី: បាទ! គ្រប់គ្រងកោះហ្នឹងបានហើយ បានឃើញកប៉ាល់មាយ៉ាកេសហ្នឹងលាបថ្នាំពណ៌ខ្មៅ ។

ដានី: ធំទេ?

នី: កប៉ាល់ហ្នឹងបើនិយាយពីរឿងផ្ទុកទំនិញបាន៥០០០តោន ។

ដានីៈ កប៉ាល់ហ្នឹងតាមពិតគេបើកនៅតាមផ្លូវអន្តរជាតិទេ?

នីៈ បើកនៅផ្លូវអន្តរជាតិ ។

ដានីៈ មែនគេមកចូលទឹកដីយើងទេ?

នីៈ អត់ទេ គេរត់នៅលើផ្លូវអន្តរជាតិ ។

ដានីៈ ហើយពេលគេរត់ហ្នឹង ទាហានពីកោះណាដែលទៅភ្ជួង់ចាប់?

នីៈ ពីកោះពោវ៉ៃ ។

ដានីៈ ហើយយើងយកអីទៅចាប់ បើកប៉ាល់ហ្នឹងធំយ៉ាងហ្នឹង?

នីៈ នាវាប៉េសេអេសហ្នឹងរបស់ទាហានលន់ នល់ ហ្នឹង កាលហ្នឹងអត់ទាន់មាននាវាចិនឧបត្ថម្ភឲ្យណា យកអាកប៉ាល់គ្រៀមដូចរបស់អាមេរិចកាំងហ្នឹង ។

ដានីៈ តូចៗហ្នឹង?

នីៈ បាទ! យកទៅ២គ្រឿង ។

ដានីៈ ហើយទៅដល់យើងធ្វើម៉េច យើងចាប់វាធ្វើម៉េចបើកប៉ាល់ហ្នឹងវាធំសឹងអីហ្នឹង?

នីៈ យកទៅអែប ហើយឡើង ។

ដានីៈ ហើយមនុស្សនៅក្នុងកប៉ាល់ហ្នឹងគ្នាច្រើនទេ?

នីៈ មនុស្សនៅក្នុងកប៉ាល់ហ្នឹងមានគ្នា៤០នាក់ ។

ដានីៈ អាហ្នឹងសុទ្ធតែជនស៊ីវិលមែន?

នីៈ ជនស៊ីវិល ។

ដានីៈ ៤០នាក់?

នីៈ បាទ!

ដានីៈ ហើយយើងភ្ជួង់ហើយយកមកដាក់នៅកន្លែងណាទៅ?

នីៈ យកមកបញ្ឈរនៅខាងមុខដៃ ។

ដានីៈ យកមកបញ្ឈរនៅខាងមុខកំពង់ផែ?

នីៈ បាទ! បោះយុទ្ធភ្ការនៅច្រង៉ាងហ្នឹង ហើយវាអត់ដឹងរឿងទេ ព្រោះទាហានវាដែលបានឆ្លងកាត់ ដល់ពេលអញ្ចឹងទៅអានាវរឹកនៅខាងក្នុងដើរមើលដើរអី ហៅចេញមកអស់ហើយ តែនៅអាអ្នកកាន់ទូរលេខនៅខាងលើអត់ដឹងទូរលេខ ដល់ពេលអញ្ចឹងទូរលេខវាធ្វើសារទៅគ្មានទេ ពួកអេសសិនអុងមកលេងឡើងល្វិតមុខ ទម្លាក់ឆេះរោងចក្រប្រេងកាតល្វិតពេញមេឃទាំងអស់ ។

ដានីៈ ពួកណាហ្នឹង?

នី៖ កប៉ាល់ហោះអាមេរិចការ៉ាំង ។

ដានី៖ វាមកពីខាងណាមក?

នី៖ មិនដឹងឡើងពីណា ដូចជាឡើងពីវៃមក ។

ដានី៖ ហើយកាលហ្នឹងពូនៅកន្លែងណា?

នី៖ ខ្ញុំនៅហ្នឹងដែ ។

ដានី៖ ចុះកាលហ្នឹងថាមានវៃនៅកោះតាន់?

នី៖ វាមកវៃវិញ បំណងរបស់វាវៃហ្នឹងគឺវៃ ។

ដានី៖ វៃយកកប៉ាល់វិញ?

នី៖ យករំដោះនាវិកវានោះណា៎ ហើយបាចគ្រាក់ទៀត បាចគ្រាក់ហើយប្រកាស វាដាក់មេក្រូ ប្រកាសទៀត ហើយវាដាក់អេសសិនអុងហ្នឹងទាប ហើយប្រកាសបាចគ្រាក់ ។

ដានី៖ អេសសិនអុងហ្នឹងលេខ១៦ហ្នឹង?

នី៖ បាទ! កាលហ្នឹងវលិចវកើត ដល់ពេលអាគ្រាក់ជូនដល់ដីមើលទៅគេថាសុំប្រកាសឲ្យរដ្ឋាភិបាលខ្មែរថ្មីដឹងខ្លួន នាវវារបស់គេមួយគ្រឿងដែលមានម៉ាកថា “ម៉ាយ៉ាកេស” នោះគឺគេមិនបានបំពានរំលោភអីដល់ដែនដីរបស់ខ្មែរទេ គឺគេរត់តាមផ្លូវអន្តរជាតិទេ ។

ដានី៖ កាលហ្នឹងគេទម្លាក់នៅណា?

នី៖ ទម្លាក់នៅកំពង់សោម ហើយគេថាបើសិនជាមិនរូតរះដោះលែងនាវវាគេហ្នឹងជាបន្ទាន់ទេ ហើយនឹងនាវិករបស់គេទាំងអស់ទេ ហើយហ៊ានតែធ្វើឲ្យប៉ះពាល់ណាមួយ គេនឹងមានការព្រមានឲ្យដឹងដៃម្តង ។

ដានី៖ អញ្ចឹង?

នី៖ ហ្នឹងអើយ ។

ដានី៖ ប៉ុន្តែកាលហ្នឹងកប៉ាល់យើងចាប់មកដល់កំពង់សោមហើយ ហើយកងទ័ពអាមេរិចម៉េចបានជាវាចូលមកវៃនៅកោះតាន?

នី៖ វាមកវៃហ្នឹងគឺគម្រោងការវៃយកអណ្តូងប្រេងទេ ។

ដានី៖ អញ្ចឹងគម្រោងការរបស់វាវៃយកអណ្តូងទេ?

នី៖ បាទ!

ដានី៖ កាលហ្នឹងមានបាញ់យន្តហោះបាញ់អីធ្លាក់ដែរ ដូចជាខត្តម្ភាគចក្រអីហ្នឹង?

នី៖ អាបំរុងវៃយកលើកក្រោយហ្នឹងគឺវៃយកអត់បានទេ ហើយបាញ់ធ្លាក់៤គ្រឿងហ្នឹងធ្លាក់តែបាញ់លើកទីមួយព្រោះកប៉ាល់ហោះវាមកជួយគាំទ្រ ។

ដានី: ដល់ពេលយើងចាប់អាម៉ាឃីកេសហ្នឹងវាទម្លាក់ដៃរអញ្ចឹង?

នី: ចាប់ម៉ាឃីកេសហ្នឹងហើយដែលបាញ់ផ្លេះប្រែងកាត ហើយបាញ់ផ្លេះឃ្លាំងនៅកំពង់ផែហ្នឹង ។

ដានី: ហើយយ៉ាងម៉េចទៅ យើងចាត់វិធានការយ៉ាងម៉េចដែរ?

នី: ចាត់វិធានការអី លែងគេវិញទៅ ឲ្យគេទៅវិញទៅ ។

ដានី: ឲ្យទៅវិញទាំងនាវិកទាំងអីអស់ទៅ?

នី: បាទ!

ដានី: ដល់ពេលទៅវិញវាឈប់វ៉ៃដែរ?

នី: យើងជូនគេ នាំគេទៅដល់ផ្លូវហ្នឹងវិញហើយក៏រួចគ្នាទៅ ។

ដានី: ដល់ហើយបានមានផែនការវ៉ៃកោះត្រល់?

នី: ហ្នឹងហើយ មានផែនការវ៉ៃកោះត្រល់ទៀតហើយ ផែនការវ៉ៃកោះត្រល់ហ្នឹងហើយជាផែនការយ៉ាប់អត់បាយអត់ទឹក ។

ដានី: អាហ្នឹងយ៉ាងម៉េច យើងបញ្ជាយ៉ាងម៉េច ខុសបច្ចេកទេសឬក៏យ៉ាងម៉េចអាហ្នឹង?

នី: គម្រោងការរបៀបគេថាឈ្នះពេកណាស់ ។

ដានី: អាហ្នឹងយើងគិតងាយពេក?

នី: បាទ! របៀបថាគម្រោងការគិតទៅវាឈ្នះងាយពេក ដល់ពេលឈ្នះពេកមិនដឹងថាផ្ទៃដីនៅកោះត្រល់ហ្នឹងមានប៉ុន្មានគីឡូ៤ជ្រុង បើអញ្ចឹងហើយយកកម្លាំង២-៣រយនាក់ទៅវ៉ៃយ៉ាងម៉េច ដូចទៅធ្វើចំនីគេអញ្ចឹង គេចាប់ទាំងអស់ រត់រួចប្រហែលជា៣០-៤០នាក់ ហើយមកហែលទឹក២យប់២ថ្ងៃបានគេដឹង គេដឹងថា ព្រោះវៀតណាមគេនៅកោះហ្នឹងវាឲ្យការមកថាចាប់បានកម្លាំងប៉ុណ្ណេះប៉ុណ្ណោះហ្នឹង ដល់ពេលថាចាប់ហើយ ហើយរាយការណ៍ថាអត់មានស្លាប់ទេ ដល់ពេលអញ្ចឹងអ្នកនៅផែរាមគេដឹងថា អញ្ចឹងកម្លាំងហ្នឹងអាចគេរួចខ្លះហើយ អញ្ចឹងរងចាំតែទទួល ។

ដានី: អញ្ចឹងពេលហ្នឹងពួហែលទឹកពីណាមកណា?

នី: ហែលទឹកពីកោះត្រល់មក ។

ដានី: ហែលចូលមកដល់កន្លែងណាទៅ?

នី: ទេ! មិនដឹងចំនុច ប៉ុន្តែហែលទឹកដឹងតែពីយប់ពីថ្ងៃ ។

ដានី: ហែលហ្នឹងអត់មាន?

នី៖ ហែលហ្នឹងយើងមានដូងទុំ ហើយធម្មតាយើងហែលទឹក ឧទាហរណ៍មុនដំបូងយើងហែលខ្លួនទទេ មុនដំបូងហែលមានពងខ្លួនទទេ ហើយយើងហែលកាន់ធូន់ របស់អីក៏ដោយឲ្យតែធូន់ឲ្យតែរបស់លិចទឹក ប៉ុន្តែដល់ពេលរួចយើងមានការ ឧទាហរណ៍ថាយើងត្រូវធ្លាក់ទឹកខ្លួនទទេ ហែលអត់កើតទេ ហែលទៅវាវិលតែអណ្តែត ធម្មតាឲ្យតែមានរបស់ធូន់យើងមិនមែនហែលផ្តេកណា យើងហែលឈរ ហែល២យប់២ថ្ងៃបានទូកគេទៅយក បាញ់គ្រាប់កាំភ្លើងឲ្យសញ្ញា១ម៉ោងបាញ់មួយគ្រាប់ៗ ឲ្យតែយប់ ។

ដានី៖ អញ្ចឹងកាលទៅកោះត្រល់ហ្នឹងអត់ទាន់បានវៃអីផង?

នី៖ អត់ទាន់ទេ គ្រាន់តែផ្ទុះកាំភ្លើងគេមួយតូង ។

ដានី៖ គេត្រៀមចាប់ហ្មង?

នី៖ បែកការ ។

ដានី៖ បែកការម៉េច?

នី៖ បែកការអាវៀងទៅ ទៅឡើងគោក ហើយកោះហ្នឹងយួនដើរត្បាតតាមឆ្នេរ ដល់ឡើងមិនមានស្លាកស្នាម ដល់ពេលមានស្លាកស្នាមគេតាមដានវាប្រកាស ។

ដានី៖ វាប្រកាសអាសន្នហ្មង?

នី៖ ប្រកាសពេញកោះហ្មង ។

ដានី៖ កោះហ្នឹងវាធំ?

នី៖ ១០គីឡូ៨ជ្រុង ព្រោះដីនោះកោះត្រល់ហ្នឹងវាខុសពី គេហៅដីលេងហ្នឹង ។

ដានី៖ តែពូបានឡើងទៅលើកោះហ្នឹងដែរអត់?

នី៖ អត់បានឡើងដល់លើទេ បានឡើងត្រឹមជើងក្រោមទេ ។

ដានី៖ ដល់ជើងក្រោមហ្នឹងវាម៉េច វាដេញ?

នី៖ ដល់ពេលវាដេញមក អាគេឡើងខិតលើហ្នឹងគេចាប់បានអស់ ហើយខ្ញុំនៅអាល័យតែពុះដូងពុះអីហូបខាងក្រោមនេះ ។

ដានី៖ យើងទៅបានប៉ុន្មានថ្ងៃហើយបានមានពុះដូងពុះអី?

នី៖ ៣យប់៣ថ្ងៃហើយ ។

ដានី៖ យើងនៅក្នុងទឹកឬក៏យ៉ាងម៉េច?

នី៖ នៅលើគោក ទៅដល់ហ្នឹងឡើងលើគោកបាន៣យប់៣ថ្ងៃហើយ ។

ដានី៖ ហើយមិនទាន់វៃទេ?

នី៖ វៃអី បើមិនដឹងទីតាំងត្រង់ណាអីត្រង់ណាខ្លះនោះ ។

ដានី៖ អញ្ចឹងមុនពេលដែលទៅវ៉ៃកោះនោះយើងអត់មានដឹងទីតាំងភូមិសាស្ត្រអីទេ?

នី៖ អត់ដឹងទេ យកកម្លាំងហ្នឹងឲ្យទៅស៊ើបសិន ។

ដានី៖ ដើរស៊ើបសិន?

នី៖ ដើរស៊ើបពីនេះទៅនេះមានទីតាំងប៉ុន្មាន ហើយមានកាំភ្លើងអី ដាក់កន្លែងណា កាំភ្លើងអីធន់អីនៅកន្លែងណាខ្លះអត់ដឹងទាំងអស់ ឲ្យទៅមានប្រយោជន៍អី ទៅប៉ុន្តែទៅធ្វើឈ្លើយសឹកហ្នឹងអស់ អញ្ចឹងហើយបានជាមានការដោះដូរគ្នា ដល់ពេលក្រោយមកហ្នឹងធ្វើឈ្លើយសឹក?

ដានី៖ គេដោះដូរយ៉ាងម៉េចទៅ?

នី៖ គេដោះដូរឈ្លើយសឹករវាងជនជាតិហើយនឹងជនជាតិ ហើយឲ្យទទួលស្គាល់រឿងព្រំដែនហើយនឹងព្រំដែនត្រូវមានការកំណត់ឲ្យបានច្បាស់លាស់ លែងឲ្យមានការទាក់ទិន ហើយលែងឲ្យមានការវិវាទតទៅមុខទៀត

ដានី៖ អញ្ចឹងបើតាមពូចាំ បន្ទាប់ពីខែណាឆ្នាំណាដែរ ដែលយើងឡើងទៅវ៉ៃកោះត្រល់ហ្នឹង?

នី៖ យើងឡើងទៅវ៉ៃកោះត្រល់ហ្នឹងក្នុងខែ៥ ។

ដានី៖ ខែ៥ ឆ្នាំ៧៥ហ្នឹង?

នី៖ បាទ!

ដានី៖ ប្រហែលជាថ្ងៃប៉ុន្មានទៅ?

នី៖ មិនបានចាំថ្ងៃទេ គ្រាន់តែដឹងថាក្នុងខែ៥ ។

ដានី៖ អញ្ចឹងកម្លាំងទៅប្រហែលជា៣០០នាក់ទេ?

នី៖ កម្លាំងមាន៣០០នាក់ ។

ដានី៖ កាលហ្នឹងពេលដែលយើងទៅថ្ងៃហ្នឹង យើងទៅដំបូងយើងទៅស៊ើប?

នី៖ ទៅដល់មួយយប់ ហើយមួយយប់ហ្នឹងឡើង ឆ្លងហែលឡើង ដល់ពេល២គីឡូហែលទឹកប្រហែលជា២ម៉ោងបានផុត ព្រោះគីឡូទឹកវាមានចំងាយរបស់វា មែនដូចគោកយើងណាគោកយើងកំណត់ថា១០០០ម៉ែត្រស្មើរហ្នឹងមួយគីឡូដី ប៉ុន្តែទន្លេទឹកស្មើរនឹង១៨០០ ។

ដានី៖ មួយគីឡូ?

នី៖ បាទ! បើអញ្ចឹងគេកំណត់ឲ្យមួយគីឡូធ្វើម៉េចហែលពីរម៉ោងឲ្យដល់ បើយើងហែលផុតហ្នឹងបានដល់គោកហើយ ដល់ច្រាំងឡើង ដល់ពេលមួយយប់ហ្នឹងអាល័យតែពពឹមពពើម ហើយសុទ្ធតែព្រៃ អាដើមខ្នាយដើមអីហ្នឹងវាដុះ ដើមខ្នាយធម្មតាបើវាអត់ទាន់ផាប់វាស្រួលយើង

ចូលបន្តិច ប៉ុន្តែបើវាស៊ប់វាទាក់ខោទាក់អាវ ពួកលិចពួកកើត អញ្ចឹងធ្វើដំណើរទៅវាមានការកាច់ការវែច ដល់ពេលព្រឹកឡើងពួកទាហានវៀតណាមវាដើរអាវិធំវាឃើញ ។

ដានី: ពេលឃើញអញ្ចឹងវាតាមដាន?

នី: ឃើញតាមដាន ហើយប្រកាសអាសន្នព្រឹប ហើយបែកការ ហើយប្រកាសឲ្យលើកដៃចាប់ហ្នឹង ។

ដានី: គេប្រកាសអញ្ចឹងហ្នឹង?

នី: បាទ!

ដានី: អញ្ចឹងអត់មានបានបាញ់គ្នាអីទេ?

នី: អត់ អត់មានបានបាញ់អីមួយប៉ុងទេ ។

ដានី: គេចាប់ខ្លួនស្រួលហ្នឹង?

នី: ស្រួលហ្នឹង ។

ដានី: កាលហ្នឹង បូ ហ្នឹងគាត់ទៅដែរ?

នី: គាត់ទៅ ព្រោះគាត់ជាអ្នកដឹកនាំ ។

ដានី: អ្នកដឹកនាំក្នុងចំណោមអ្នកទាំងអស់គ្នាហ្នឹង?

នី: បាទ!

ដានី: គ្នា៣០០នាក់ហ្នឹងគាត់ជាអ្នកដឹកនាំ?

នី: បាទ! មាន បូ ហ្នឹង ហើយមានខ្មោចបងផាន់នីនោះ ។

ដានី: ដល់ពេលគេចាប់គេអត់មានធ្វើអីយើងទេ?

នី: អត់ទេ គ្រាន់តែគេធ្វើរបងឲ្យយើងនៅអញ្ចឹងណា៎ ហើយរបងហ្នឹងគេដាក់ខ្សែភ្លើង ។

ដានី: អាហ្នឹងគេប្រាប់យើង?

នី: អ្នកដែលមកៗហ្នឹងគេនិយាយអញ្ចឹង ។

ដានី: កាលហ្នឹងពូហែលទឹកមកវិញ?

នី: ខ្ញុំហែលទឹកមកវិញ ខ្ញុំអត់មានបានទៅធ្វើឈ្លើយសឹកណា៎ ។

ដានី: ចុះឈ្លើយសឹកហ្នឹងជាប់ប៉ុន្មានថ្ងៃទៅ?

នី: ឈ្លើយសឹកហ្នឹង៨ខែ ។

ដានី: ជាប់៨ខែ?

នី: បាទ! ទម្រាំរដ្ឋាភិបាលចចារគ្នាត្រូវ ។

ដានី: ហើយពូតែ២ថ្ងៃទេ បានគេស្រង់មកវិញ?

នីៈ ខ្ញុំតែ២ថ្ងៃគេទៅទទួល ។

ដានីៈ ចុះមកវិញយើងអត់មានត្រូវគេស្តីបន្ទោសឲ្យទេ?

នីៈ អត់មានទេ ។

ដានីៈ អត់មានទេ?

នីៈ អត់ ។

ដានីៈ ហើយ តាមុត គាត់អត់មានថាអីទេ?

នីៈ អត់ ។

ដានីៈ ហើយអ្នកដែលបញ្ជាឲ្យទៅវ៉ៃកោះតានហ្នឹងគឺ តាមុត ជាអ្នកបញ្ជា?

នីៈ កោះតានហ្នឹងមិនទេ គ្រាន់តែរៀបចំផែនការ ។

ដានីៈ កោះត្រល់?

នីៈ កោះត្រល់ហ្នឹងគឺបញ្ជាពីមជ្ឈិមបក្សទៅ ។

ដានីៈ បញ្ជាពីមជ្ឈិមបក្សទៅទេ?

នីៈ បាទ! ព្រោះថាដីកោះត្រល់ហ្នឹង វាជាដីរបស់ខ្មែរ ដូចនេះយើងត្រូវទៅវ៉ៃយកកោះត្រល់វិញ ។

ដានីៈ មជ្ឈិមបក្សបញ្ជាមកអញ្ចឹង តែឲ្យកងពលជាអ្នករៀបចំ?

នីៈ ហ្នឹងហើយ ឲ្យកងពលជាអ្នករៀបចំគម្រោងការចាត់ចែង ។

ដានីៈ អញ្ចឹងអ្នករៀបចំគម្រោងការទៅវ៉ៃហ្នឹង តាមុត ហ្នឹងជាអ្នករៀបចំ?

នីៈ បាទ!

ដានីៈ ចុះរៀបចំយ៉ាងម៉េចបើយើងអត់ទីតាំង អត់ដឹងភូមិសាស្រ្តអីផង?

នីៈ រឿងមិនដឹងហ្នឹងហើយបានឲ្យកម្លាំងទៅស៊ើប ។

ដានីៈ ទៅស៊ើបសិន?

នីៈ បាទ! ចង់ដឹងថាវន្ធផ្ទៃកោះហ្នឹងវាមានប៉ុន្មាន វាមាន១០គីឡូដី៤ជ្រុងហ្នឹងតើមានទីតាំងប៉ុន្មាន មានទីតាំងតូបប៉ុន្មាន ទីទាំងស្មើរជើង ហើយទីតាំងកាំភ្លើង ហើយក្នុងទីតាំងមួយមានកាំភ្លើងអីខ្លះទៅក្នុងទីតាំងហ្នឹង អាហ្នឹងឲ្យដឹងអញ្ចឹង ដល់ពេលវ៉ៃគឺរៀបចំកម្លាំងត្រូវឧទាហរណ៍ថាខ្ញុំមានគ្នាមួយក្រុម ដឹកនាំមួយក្រុមទៅកាន់ទីតាំងនេះ ទីតាំងកាំភ្លើងអី ទីតាំងស្មើរជើងឬក៏ទីតាំងកាំភ្លើងធំ បើអញ្ចឹងហើយឲ្យច្បាស់លាស់អញ្ចឹងយើងចាត់ចែងកម្លាំងទៅវាត្រូវ ប្រើប្រាស់គ្រាប់អាវុធទៅត្រូវ បើមិនរៀបរាប់អញ្ចឹងវាមិនត្រូវទេ ។

ដានីៈ តែយើងទៅបាន៣ថ្ងៃហើយយើងអត់មានបានរាយការណ៍អីទេ?

នី៖ អត់មានបានរាយការណ៍ទេ ។

ដានី៖ អត់មានគេអូអីប្រើទេ?

នី៖ ប្រើទូរលេខ ។

ដានី៖ អញ្ចឹងខាងកំពង់សោមហ្នឹងអត់ទាន់ដឹងរឿងទេ ពេលដែលគេចាប់?

នី៖ គេចាប់ហ្នឹងដឹងដែរហ្នឹង ហើយផ្ញើសារពីនោះមក ។

ដានី៖ អញ្ចឹងអត់ទាន់បានវៃអីផង?

នី៖ បាទ!

ដានី៖ ហើយពេលដែលគេចចារហ្នឹង កាលហ្នឹងគេចចារយ៉ាងម៉េច?

នី៖ ដោះដូរហ្នឹងខ្ញុំមិនចាំ កាលហ្នឹងប៉ុល ពត ហ្នឹងផ្ញើសន្ទិបាទ ផ្ញើសន្ទិបាទនៅវិមានគីឡាស្តាត ហ្នឹង គាត់ប្រកាសដោះដូរអារឿងស្អីទេ ដល់ពេលដូរក៏គេយល់ព្រម ហើយក៏កំណត់គ្នាឲ្យទៅ ទទួលស្គាល់ព្រំដែន ។

ដានី៖ ទទួលស្គាល់ព្រំដែន បានន័យថាយើងទទួលស្គាល់ថាកោះត្រល់របស់គេ?

នី៖ ហ្នឹងហើយ ។

ដានី៖ ហើយយើងទទួលស្គាល់ទេកាលហ្នឹង?

នី៖ ទទួលស្គាល់ អត់មានការលូកដៃទេ ។

ដានី៖ អញ្ចឹងតាំងពីពេលហ្នឹងយើងអត់មានប៉ះពាល់ទៀតទេ?

នី៖ អត់រហូត អត់ដែលប៉ះទេ ។

ដានី៖ អញ្ចឹងកាលនោះយើងទទួលអញ្ចឹងហើយ យើងមានដោះដូរអីទៀតអត់ដើម្បីយកទាហាន យើងមកវិញ?

នី៖ កាលហ្នឹងដោះដូរកម្លាំងមនុស្សហើយនឹងមនុស្សហ្នឹង ប៉ុន្តែជនជាតិវៀតណាមហ្នឹងមិនដឹងជា សមាសភាពអីខ្លះដែលដោះដូរហ្នឹង ខ្ញុំមិនបានចាំ ។

ដានី៖ ជនជាតិវៀតណាមហ្នឹងបានន័យថាយើងយកទៅដោះដូរជាមួយទាហានយើងវិញ?

នី៖ បាទ!

ដានី៖ ហើយពូអត់ចាំទេ?

នី៖ អត់ចាំទេ ។

ដានី៖ ហើយចុះបន្ទាប់មកពីហ្នឹងមកទៀត ពេលពូត្រលប់មកពីកំពង់សោមមកហើយពូរៀបចំយ៉ាង ម៉េច?

នី៖ ចាត់ចែងមកកំពង់សោមមក ខ្ញុំក៏វិលមកកំពង់ផែវិញ ហើយគេទុកកម្លាំងនៅកំពង់ផែហ្នឹង អតីត៥៥០ហ្នឹង គេឲ្យនៅតែគ្នាមួយក្រុមហ្នឹងទេ។

ដានី៖ មួយក្រុមមានគ្នាប៉ុន្មាននាក់?

នី៖ មួយក្រុមមានគ្នា១៦នាក់ ឲ្យនៅហ្នឹង ហើយក្រោយពីនោះគេបន្ថែមឲ្យទៅរៀបកម្លាំងកងជើងទឹក ហាត់បើកបរនាវាវា ឲ្យទៅជាអង្គភាពនាវាចរណ៍ ក្នុងកងពលទី៣។

ដានី៖ ប៉ុន្តែគេមានដូរឈ្មោះកងពលទេ?

នី៖ គ្រាន់តែមិននេះទេ កម្លាំងហ្នឹងគឺកម្លាំងនៅក្នុងកងពលហ្នឹងដដែល ប៉ុន្តែគ្រាន់តែថានាវាវាមានប៉ុន្មានគ្រឿង នាវាឧទាហរណ៍មាន០០ ហើយអា០០ហ្នឹងមានប៉ុន្មានគ្រឿង មាន៣គ្រឿង ដល់ពេលមានអា០០ហ្នឹង៣គ្រឿង ឧទាហរណ៍ថាខ្ញុំនៅក្នុងអា០០ ហើយអា០១ហ្នឹងប៉ុន្មាន ដល់ពេលកំណត់ត្រូវឡើងមកប្រជុំ មកធ្វើការអីគឺបន្តកម្លាំងមកហើយ ឧទាហរណ៍ថាត្រូវយកមកម្តងប៉ុន្មាន អា០១យកកម្លាំងមកប៉ុន្មាននាក់ យក២ឬ៣នាក់យកមកប្រជុំ យកមករៀនសូត្រហើយទៅ ហើយទៅវិញដូរអ្នកផ្សេងឲ្យមកទៀត។

ដានី៖ ប៉ុន្តែកាលហ្នឹងដូចថាសមាសភាពកងពលជើងទឹក កាលហ្នឹងតែកងពលទី៣ចូលអត់មានបញ្ចូលមកពីភូមិភាគណាផ្សេងទៀតទេ?

នី៖ អត់ បញ្ចូលតែកម្លាំងកម្មករមកផែវិញ ឯចំពោះកម្លាំងប្រដាប់អាវុធមកគឺអត់ទេ អតីតកងពលទី៣ហ្នឹងទាំងអស់។

ដានី៖ កាលហ្នឹងយើងដូរលេខកងពលហើយ ដូចជា១៦៤?ៈ

នី៖ ក្រោយពេលដែលរៀបនាវាចរណ៍អីហើយហ្នឹង បានផ្លាស់លេខ។

ដានី៖ កាលហ្នឹងតាមុត គាត់ទទួលរួម?

នី៖ បាទ!

ដានី៖ ហើយចុះផ្សេងៗទៀតមានពីណាគេខ្លះ?

នី៖ ផ្សេងៗមកមានខាងសេដ្ឋកិច្ចមាន តាគ្រិន។

ដានី៖ តាគ្រិនហ្នឹងគាត់ខាងស៊ីវិលមែន?

នី៖ អាហ្នឹងគាត់ខាងភស្តុភា។

ដានី៖ តែខាងកងទ័ពដែរ?

នី៖ ហ្នឹងតាមការពិតវាក្នុងគណៈកម្មការ រឿងមេៗមួយជំនាន់ហ្នឹងវាពិបាក វាពិបាកចំណាំ វាមិនទាន់ ចង់និយាយថារបៀបថាមេណាមួយដែលមិនទុកចិត្តគឺស្រាប់តែបាត់ខ្លួនឈឹង។

ដានី៖ ពីណាគេដែលបាត់ខ្លួនហ្នឹង។

នី៖ បាត់ខ្លួនហ្នឹងមិនដឹងជាបាត់ពីណាគេខ្លះទេ ខ្លះមកមិនទាន់នឹងឃើញស្រួលបួលផងក៏បាត់ខ្លួនទៅ តែមិនដឹងអ្នកណាខ្លះទេ ។

ដានី៖ ចុះបើតាមខ្ញុំដឹងពេលដែលខ្ញុំជួបពូៗមុន គាត់ប្រាប់ថាដូចគេបញ្ជូលពួកខាងបូព៌ាមកជាមួយដែរ?

នី៖ មក តែមកហ្នឹងសម្រាប់កម្មករ ។

ដានី៖ ហើយមានដឹកនាំដោយដូចឈ្មោះ តាឌឹម មេមកដែរ?

នី៖ បាទ! តែមកមិនទាន់បានប៉ុន្មានផងក៏ត្រូវថាប៉ះពាល់ដល់សិលធម៌ មុនដំបូងយក តាឌឹម ហ្នឹងមកចង់មកឲ្យដឹកនាំនារវាចរណ៍ហ្នឹង ពីព្រោះខាងភូមិភាគនោះវាមានខាងភូមិសាស្ត្រទឹកស្រាប់ ដល់ពេលយកមកវាកើតបញ្ហាអារឿងសិលធម៌ ទៅជាចាប់ទៅជាដកហូតទៅបាត់ ។

ដានី៖ អញ្ចឹងខាងដែលមកកាន់នារវាចរណ៍ហ្នឹងពីណាគេ?

នី៖ ដល់ក្រោយមកក្រោមការគ្រប់គ្រងរបស់ តាមុត ទាំងអស់ ។

ដានី៖ តាមុត គ្រប់គ្រងទាំងអស់?

នី៖ បាទ! ទាំងលើគោក ទាំងក្នុងទឹក ។

ដានី៖ កាលនោះមានលើគោកផង មានក្នុងទឹកផង?

នី៖ បាទ!

ដានី៖ ចុះមន្ទីរកងពលនៅម្តុំណា?

នី៖ មន្ទីរកងពលនៅម្តុំផ្សារកំពង់សោម គេហៅផ្សារក្រុងព្រះសីហនុហ្នឹងហ្នង ។

ដានី៖ ផ្សារលើហ្នឹង?

នី៖ បាទ!

ដានី៖ ចុះកំពង់ផែ?

នី៖ កំពង់ផែចតនារវាចតនៅរាម ។

ដានី៖ ចតនៅរាម?

នី៖ បាទ! រាមឬក៏អូរគ្រែះ ។

ដានី៖ ចុះនៅអូរឈើទាលអត់មានទេ?

នី៖ អូរឈើទាល កសាងនារវា កន្លែងឡូកន្លែងអីហ្នឹងនៅហ្នឹង ។

ដានី៖ ចុះខាងស្ទឹងហាវ?

នី៖ ស្ទឹងហាវ អាហ្នឹងកន្លែងពួក បូ ហ្នឹងឯង គាត់នៅស្ទឹងហាវ ស្ទឹងហាវហ្នឹងវាអត់មាននារវាអីមកទេ មានមកដូចជា កប៉ាល់នេសាទ ឬក៏ច្មើដើងដែលមកនៅស្ទឹងហាវ ។

ដានី៖ មកនៅស្ទឹងហាវគីនេះទេ តែគេមានធ្វើដៃធ្វើអីដែរ?

នី៖ មាន ។

ដានី៖ គេធ្វើម៉េចទៅដៃនៅហ្នឹង?

នី៖ ដៃធម្មតារបៀបបានកាណូតតូចៗចូល ហើយដូចដៃកំពង់សោមអញ្ចឹង របៀបថានៅជិតដៃថ្មីខាងលិច ដៃនៅស្ទឹងហាវ ។

ដានី៖ គេអត់មានរៀបចំថ្មីទេ អត់មានកសាងធ្វើវាដែរអត់?

នី៖ ទេ កាលជំនាន់ខ្ញុំនៅហ្នឹងគឺអត់មានធ្វើថ្មីទេ ធ្វើតែដៃចំហៀងឯង ។

ដានី៖ អត់មានដឹងថាគេធ្វើអីទេណោ?

នី៖ អត់ដឹងទេ ។

ដានី៖ ចុះដូចថាពូមានប្រសាសន៍ម៉េញដូចថា កងទ័ពដែលមានបញ្ហាខាងខុសសិលធម៌ខុងអីហ្នឹង តើគេមានចាប់ដាក់គុកដាក់អីដែរ?

នី៖ ចាប់ដាក់គុក ដាក់ទ័ណ្ឌកម្មដោយយ៉ាងម៉េច ដោយកំណត់ឲ្យធ្វើការងារអញ្ចឹងណា៎ ត្រូវធ្វើការងារអី ត្រូវរែកដី ឬក៏ជីកដីធ្វើស្រះធ្វើអីណា គេកំណត់ឲ្យធ្វើអញ្ចឹងណា៎ រួចហើយកាត់បន្ថយការហូបចុក ហើយមនុស្សកំណត់ឲ្យធ្វើតែកាត់បន្ថយការហូបចុក ហើយអញ្ចឹងបានកម្លាំងពីណាធ្វើ ។

ដានី៖ ចុះកងទ័ពអត់មានគុកកងពលទេ?

នី៖ កាលជំនាន់ហ្នឹងខ្ញុំមិនដូចមិនដែលឃើញគុក ។

ដានី៖ ចុះខាងវគ្គលើវគ្គក្រោម?

នី៖ វគ្គលើវគ្គក្រោមគឺខាងវគ្គឥត្តញ្ញាណ វគ្គហ្នឹងគឺអ្នកទិន្នាការ អ្នកមានទិន្នការហ្នឹងគឺយកមកដាក់នៅវគ្គឥត្តញ្ញាណ ។

ដានី៖ អ្នកទិន្នាការយ៉ាងម៉េចទៅ?

នី៖ ទិន្នការដូចថាទាក់ទិន ឧទាហរណ៍ថាដូចខ្ញុំអញ្ចឹងជាប់ខ្សែចាត់តាំងពីគណៈស្រុកគណៈតំបន់មកអញ្ចឹង រួចគេស្រាវជ្រាវតាមប្រវត្តិអញ្ចឹងទៅដឹងហេតុផលអញ្ចឹងទៅ គេដកចេញពីអង្គភាពឲ្យមកនៅហ្នឹងទៅ ហើយប្រើប្រាស់ដោយច្រវ៉ាក់ប្រវែងនេះទាក់ជាប់ហ្នឹងកជើងហ្នឹង ហើយឲ្យទៅធ្វើការប្រចាំថ្ងៃ ស្ការព្រៃ កាប់ដីដាំដំឡូងមីអីហ្នឹង ។

ដានី៖ អញ្ចឹងពួកកងទ័ពពូមានទិន្នាការគេចាប់មកនៅហ្នឹងដែរ?

នី៖ មាន ។

ដានី៖ ហ្នឹងសុទ្ធតែពួកកងទ័ពទេ?

នី៖ សុទ្ធតែពួកកងទ័ព ។

ដានី៖ កងទ័ពនៅកងទ័ពជើងទឹកហ្នឹងដែរ អ្នកដែលជាប់ទិន្នាការដែលគេចាប់មកជាប់ច្រវ៉ាក់ជាប់អីហ្នឹង?

នី៖ ហ្នឹងហើយ ។

ដានី៖ នៅវត្តឥត្តញ្ញាណហ្នឹង?

នី៖ អ្នកខូចសិលធម៌ខូចអីហ្នឹងគេយកមកដាក់នៅវត្តឥត្តញ្ញាណហ្នឹង ។

ដានី៖ អញ្ជឹង គាឌីម ហ្នឹងគេយកមកដាក់នៅហ្នឹងដែរ?

នី៖ អត់ទេ គេដាក់តែមហាជនទេ ។

ដានី៖ អញ្ជឹងហ្នឹងគេដាក់តែមហាជនទេ?

នី៖ បាទ! ជាមហាជនធម្មតាណាំ បើអ្នកមានតួនាទីឋាណន់ឋារៈសក្តិហ្នឹងគឺអត់ទេ ។

ដានី៖ អញ្ជឹងដាក់តែកូនទាហានធម្មតាទេ?

នី៖ បាទ!

ដានី៖ ពូធ្លាប់ឃើញវត្តឥត្តញ្ញាណហ្នឹងដែរ?

នី៖ រឿងអីមិនឃើញ បើដើរឡើងពេញហ្នឹង ។

ដានី៖ ប៉ុន្តែពូធ្លាប់ឃើញអ្នកដាក់ច្រវ៉ាក់អីដែរ?

នី៖ ឃើញ ព្រោះខ្ញុំទៅធ្វើចំការនៅជិតហ្នឹងមួយកន្លែង នៅខាងជើងវត្តហ្នឹង ខ្ញុំធ្វើចំការដាំដំឡូងដាំអីនៅជិតហ្នឹង ដល់ពេលសម្រាកពួកហ្នឹងវាចេញមក ហើយធម្មតាគ្នាអ្នកទោសគេឲ្យហូបចុកមិនគ្រប់គ្រាន់ ឯសម្រាប់ពួកខ្ញុំគឺបបូរ ដល់ពេលបបូរអញ្ជឹង គ្នាមករកបាយរកអីហូបអញ្ជឹងចេះតែឲ្យទៅ ចុះស្គាល់គ្នាហើយបើមិនអញ្ជឹងទេ ឲ្យដកដំឡូងដកអីដុតទៅ តែហូបហើយលាងមាត់លាងដៃចេញឲ្យស្អាតចាំទៅតិចគេឃើញ ។

ដានី៖ អញ្ជឹង?

នី៖ បាទ!

ដានី៖ ប៉ុន្តែពូស្គាល់គ្នាដែរ?

នី៖ ស្គាល់គ្នា ព្រោះមនុស្សសុទ្ធតែធ្លាប់ឆ្លងកាត់ក្នុងសមរភូមិដូចគ្នា ។

ដានី៖ សុទ្ធតែធ្លាប់នៅកងពលទី៣ជាមួយគ្នា?

នី៖ បាទ!

ដានី៖ ប៉ុន្តែពូដឹងថាពួកគាត់ដែលជាប់ហ្នឹង សុទ្ធតែពួកជាប់ទិន្នាការ?

នី៖ ដាប់ទិន្នាការនយោបាយទាក់ទិនហ្នឹងអ្នកចាត់តាំង ឬទិន្នាការខាងសិលធម៌អីហ្នឹង ហើយសិលធម៌ហ្នឹងវាមានកម្រិតទៀត បើអ្នក ឧទាហរណ៍ថាខុសទាំងសងខាង ឧទាហរណ៍ថាខាងស្រីក៏ស្រលាញ់ខ្ញុំ ហើយខ្ញុំក៏ស្រលាញ់ខាងស្រី មិនអញ្ចឹង! ដោយមានការប្រាស្រ័យទាក់ទងគ្នា បើអញ្ចឹងអាហ្នឹងហើយគេឲ្យទៅកន្លែងផ្សេង ឧទាហរណ៍ថាគេឲ្យទៅកន្លែងធ្វើស្រែឲ្យទៅធ្វើស្រែណា៎ ប៉ុន្តែម្យ៉ាងទៀត អ្នកដែលមានបញ្ហាដូចជា ខាងស្រីគេមិនស្រលាញ់យើង ហើយយើងស្រលាញ់គេម្ខាង អាហ្នឹងគេហៅទៅជាលក្ខណៈបំពាន បើអញ្ចឹងគេយកទៅដាក់ទៅវត្តឥត្តញ្ញាណ ឧទាហរណ៍មានបញ្ហាដូចជាហូបមិនគ្រប់គ្រាន់អញ្ចឹង ធ្វើការលើសលប់ ដល់ពេលអញ្ចឹងមានការប៉ះពាល់ ឧទាហរណ៍មិនអីធំដំទេ ឧទាហរណ៍ថាបេះដូងបេះអីហូបធម្មតាម្តងម្កាលហ្នឹង ដល់ក្រោយពេលរបៀបគេថាមេដឹកនាំខាងក្រោមគេរបៀបដូចថាមុខមាត់អញ្ចឹងទៅ ចេះរាយការណ៍បំភ្លើសអញ្ចឹងទៅក៏ចូលវត្តឥត្តញ្ញាណដែរ?

ដានី៖ វត្តឥត្តញ្ញាណកាលជំនាន់ហ្នឹងគេហៅអី?

នី៖ ហៅវត្តឥត្តញ្ញាណដែរ ។

ដានី៖ ប៉ុន្តែរបៀបថាគេហៅមន្ទីរអីទៅ?

នី៖ អត់មានហៅមន្ទីរអីទេ អត់មានដាក់ថាមន្ទីរអីទេ ។

ដានី៖ អាហ្នឹងមិនមែនគុកទេ?

នី៖ មិនមែនទេ ។

ដានី៖ ទីលុតដំ?

នី៖ អាចអញ្ចឹង ។

ដានី៖ តែក្នុងវត្តហ្នឹងហ្នង ។

នី៖ ក្នុងវត្តហ្នឹង ។

ដានី៖ កាលហ្នឹងពូឃើញវត្តឃើញអីដែរ?

នី៖ ឃើញ ។

ដានី៖ ចុះកន្លែងគេដាក់ប្រវ៉ាក់ដាក់អីហ្នឹង នៅកន្លែងណាទៅ?

នី៖ វត្តហ្នឹងនៅកន្លែងវិហារ នៅកន្លែងកុដហ្នឹង តែឥលូវប្រហែលជាគេកសាងច្រើនហើយ កាលពីមុនអត់មានប៉ុន្មាន អត់មានទេ មានតែសាលាឆាន់ ។

ដានី៖ ពូអាសារឃើញដែរអញ្ចឹង?

នី៖ ខ្ញុំធ្វើចំការនៅហ្នឹង ។

ដានី៖ អ្នកដែលដាប់ទិន្នាការនៅហ្នឹងច្រើនទេ?

នី៖ ច្រើន ខ្ញុំសួរអាមួយដែលជួបខ្ញុំ ហើយខ្ញុំឲ្យបាយឲ្យអីហ្នឹងវា៧០-៨០នាក់ហ្នឹង ។

ដានី៖ ៧០-៨០នាក់?

នី៖ បាទ! ច្រើនដែរ ។

ដានី៖ កន្លែងហ្នឹងមានតាំងពីឆ្នាំណាមក?

នី៖ មាននៅក្នុងឆ្នាំ ចុងឆ្នាំ៧៦ ។

ដានី៖ ចុងឆ្នាំ៧៦?

នី៖ បាទ!

ដានី៖ ហើយរហូតដល់ពេលណា?

នី៖ រហូតដល់ទល់គ្នាឆ្នាំ៧៩ហ្នឹងហ្នង ។

ដានី៖ អញ្ចឹងពីណាគេប្រធានគ្រប់គ្រងនៅហ្នឹង?

នី៖ អ្នកដែលគ្រប់គ្រងមើលការខុសត្រូវព្រឹកល្ងាចហ្នឹង តាឡូញ ។

ដានី៖ តាឡូញ?

នី៖ បាទ! តាឡូញ ប្រធាននេសាទ អារឿងកាលពីគណៈដឹកនាំដែលក្រោយពីចាប់លោក ឌឹម ទៅនោះគឺអ្នកដឹកនាំគ្រប់គ្រងក្នុងបរិវេណក្នុងកំពង់សោមទាំងមូលហ្នឹង គឺមាន៣រូប មាន មាសមុត មាន តាឡូញ ហើយនឹង ជា គ្រិន ។

ដានី៖ អញ្ចឹងអ្នកដែលមើលការខុសត្រូវនៅវត្តឥត្តញ្ញាណគឺ តាឡូញ?

នី៖ បាទ! ព្រោះ តាឡូញ នៅជិតផ្ទះគាត់ ។

ដានី៖ តាឡូញ នៅជិតផ្ទះគាត់?

នី៖ បាទ! តាឡូញ នៅជិតហ្នឹងបន្តិច ។

ដានី៖ តាឡូញ គាត់នៅណាឥឡូវ?

នី៖ មិនដឹងនៅណាទេ បើបាត់ឈ្មោះឈឹង មិនដឹងទៅណាទៅណីទេ ។

ដានី៖ តាឡូញ អ្នកស្រុកកំណើតនៅណា?

នី៖ មិនដឹងនៅណាទេ ។

ដានី៖ កាលជំនាន់កងពលយើងវៃចូលភ្នំពេញ គាត់នៅក្នុងកងពលទី៣ដែរឬក៏អត់ទេ?

នី៖ អត់ទេ គាត់នៅខាងបច្ចឹមហ្នឹង ។

ដានី៖ តែជិតផ្ទះគាត់ទេ?

នី៖ បាទ!

ដានី: ចុះកន្លែងដែលជាប់នៅវត្តឥត្តញ្ញាណហ្នឹង គេគ្រាន់តែដាក់ច្រវ៉ាក់ដាក់អីអញ្ចឹង ឬក៏គេមានដូចថាត្រូវសម្លាប់អីគេមានសម្លាប់ដែរ?

នី: ទេ ខ្ញុំស្តាប់មិនបានទេរឿងសម្លាប់ ប៉ុន្តែតាមនេះទៅ វាមិនដឹងមូលហេតុ ប៉ុន្តែគ្រាន់តែដឹងថាអ្នកដែលមានបញ្ហានាំខ្លួនចូលដំបូង យប់គឺដាក់ខ្នោះជើង អាខ្នោះឈើយើងណា៎ ដល់ពេលថ្ងៃឡើង ខ្នោះជើងគេកំណត់ដាក់៣យប់៣ថ្ងៃ រួចហើយបើមិនមានបញ្ហាអីទេគេលែង ប៉ុន្តែយប់នៅដាក់ ហើយថ្ងៃគេលែង ហើយថ្ងៃលែងហ្នឹងគឺជាប់ច្រវ៉ាក់ជើង ហើយឲ្យទៅធ្វើការ ។

ដានី: អញ្ចឹងពូថា តាឡូញ ហ្នឹងគេឲ្យទៅមើលការខុសត្រូវនៅហ្នឹង?

នី: បាទ! តាឡូញ អន្តភាពគាត់ជាអន្តភាពនេសាទ ។

ដានី: តែនៅក្នុងហ្នឹងសុទ្ធតែជាកងទ័ពដូចជាពូទេដែលជាប់នៅហ្នឹង អត់មានប្រជាជនទេ?

នី: អត់មានប្រជាជនទេ ។

ដានី: តែជំនាន់ហ្នឹងគេហៅថាវត្តឥត្តញ្ញាណ?

នី: បាទ!

ដានី: អញ្ចឹងកាលជំនាន់នោះមានដែលលេងសើចជាមួយគ្នា ដូចថាពូលេងសើចជាមួយមិត្តភ័ក្រ្តរបស់ពូទេ ហើយធ្វើខុសអីគេចាប់យកទៅដាក់វត្តឥត្តញ្ញាណអី មានដែលនិយាយអញ្ចឹងទៅ?

នី: និយាយ ។

ដានី: ពូធ្លាប់និយាយអញ្ចឹងដែរ?

នី: បាទ!

ដានី: ធ្លាប់ដឹងអញ្ចឹងដែរ?

នី: ដឹង ។

ដានី: ថាកន្លែងហ្នឹងគេ?

នី: កន្លែងគេសម្លាប់ សុទ្ធតែកន្លែងគេលុតដំ ។

ដានី: ហើយមានវត្តឥត្តញ្ញាណហ្នឹងមួយទេ អត់មានកន្លែងណាទៀតទេ?

នី: ខ្ញុំដឹងតែនៅក្នុងវង្វង់កំពង់សោមហ្នឹងមានកន្លែងហ្នឹងមួយ ហើយក្រៅពីហ្នឹងដូចជាអត់មានទេ ។

ដានី: តាមុត មានដែលទៅកន្លែងហ្នឹងដែរទេ?

នី: គាត់ចេញចូលហ្នឹងដែរ ។

ដានី: ផ្ទះគាត់នៅក្បែរហ្នឹងដែរអត់ទេ?

នី: មុត ផ្ទះនៅនេះហ្នឹង ។

ដានី: នៅណា?

នី: ផ្ទះប្រពន្ធគាត់ខ្មោច ខំ ហ្នឹងនៅជិតផ្សារលើ ហើយខ្មោច ខំ នៅជិតផ្សារទំប័ង ហើយ មុត ផ្ទះគាត់នៅអូរឈើទាល នៅជិតកន្លែងធ្វើឡធ្វើទូកធ្វើអីហ្នឹង ។

ដានី: ប៉ុន្តែគាត់ចេញចូលទៅវត្តឥត្តញ្ញាណហ្នឹងដែរ?

នី: ចេញចូលម្តងម្កាល ហើយមេៗជំនាន់នោះរបៀបថាយើងអ្នកមានទិន្នាការអីផ្សេងៗអញ្ចឹង គេមិនទោយល់ទុកធុរៈយើងណាំ ហើយក្នុងឋានៈយើងជាអ្នកខុសណាំ ។

ដានី: អញ្ចឹងកន្លែងហ្នឹងទាល់តែអ្នកមានទិន្នាការបានគេយកយើងទៅកន្លែងហ្នឹង?

នី: បាទ!

ដានី: បើយើងល្អជាត្រឹមត្រូវអត់មានជាប់អីគេអត់មានយកទៅទេ?

នី: អត់ទេ ។

ដានី: ចុះតាឡូញមនុស្សគាត់យ៉ាងម៉េចដែរ?

នី: មនុស្សគាត់ធម្មតា មិនល្បីល្បាញ សមាសភាព ហើយកម្លាំងមេៗ តាឡូញ ហើយនឹង គ្រិន ហ្នឹងប្រភេទប្រហាក់ប្រហែលគ្នា ប៉ុន្តែគ្រាន់តែ គ្រិន ហ្នឹងគាត់មានប្រជាប្រិយភាព ជាង ៦ មាស មុត នោះភ្នែកសម្លឹងហើយគឺផ្ទុះដើងមេឃ ហើយឈ្មោះ មុត នោះគឺត្រូវ មុត ហ្នឹងហ្មង សម្លឹងអាក្រក់ណាស់ ។

ដានី: សម្លឹងម៉េចទៅ?

នី: សម្លឹងមិនព្រិចហ្មង ខ្ញុំមិនអីទេ ហើយខ្ញុំទៅកាត់សក់ ហើយគាត់ធ្វើកន្លែងផ្ទះទទួលភ្ញៀវនៅ ជិតផ្ទះប្រពន្ធគាត់ខ្មោច ខំ ហ្នឹង ដល់ពេលជាងខ្ញុំមិនដឹងថាភិនភាគយ៉ាងម៉េចទេ ដល់ពេល ឃើញធ្វើឃើញប្រក់អីហើយខុស ខុសបំណងចិត្តគាត់ ដល់ពេលខុសបំណងចិត្តគាត់លែង ហៅជាងឲ្យចុះមកពីលើដំបូលផ្ទះដីលែងកាប់ក្បាលត្រឹមហ្នឹង ទាញកូនប្រថៅពីដៃជាងហ្នឹងមក ទក្បាលត្រឹមហ្នឹងដោះដួលស្រុច ។

ដានី: ស្លាប់ដែរ?

នី: ស្លាប់ ។

ដានី: ខុសម៉េចទៅ?

នី: ខុសរបៀបគេថាអាវែហោជាងផ្ទះ គ្នាវែខុស គាត់ឲ្យវែឈើអញ្ចឹងមកហើយបត់មកធ្វើ ស្លាបអញ្ចឹងណា ដល់ពេលគ្នាបត់មកកើតព្រោះឈើវាបាក់ ព្រោះតែបត់វាបាក់ហើយឈើ

ឃើញណាដែលបត់៩៥ បានគឺខុសដំណើរហើយ ទាល់តែដែកឬក៏ឫស្សី ហើយឫស្សីហ្នឹងក៏ក្រិច ដែរ ដល់ពេលធ្វើអាហ្នឹងវាមិនកើតទាល់តែគ្នាកាត់ ដល់ពេលកាត់អញ្ចឹងគ្នាមកក៏ឃើញ អាហ្នឹងខុសត្រង់ហ្នឹង ហើយហៅគ្នាឲ្យចុះដី ហើយកាប់ដោះ ។

ដានី: ពូឃើញផ្ទាល់នឹងភ្នែក?

នី: ឃើញផ្ទាល់ភ្នែក ។

ដានី: នៅឆ្នាំណាហ្នឹង?

នី: ឆ្នាំនៅក្នុងរង្វង់ដើមឆ្នាំ៧៧ ។

ដានី: គាត់ធ្វើផ្ទះនៅកន្លែងណា?

នី: ធ្វើនៅខាងកើតផ្សារកំពង់សោម?

ដានី: ផ្សារមួយណា?

នី: ផ្សារដែរ អានៅស្របផ្លូវទៅអូរឈើទាលហ្នឹងហ្នង អាផ្លូវទៅពីកំពង់ផែទៅ មែនផ្លូវលើទេ ។

ដានី: ដែលជាងធ្វើផ្ទះគាត់ជាកូនទាហាននៅហ្នឹងឬក៏មិនមែនទេ?

នី: កូនទាហាន មិនមែនជាងមកពីណាទេ សុទ្ធតែកូនទាហាន កម្លាំងនៅជាមួយគាត់ហ្នឹងហ្នង ។

ដានី: កម្លាំងនៅមន្ទីរហ្នឹង?

នី: បាទ!

ដានី: ឃើញគាត់មុននឹងកាប់ហ្នឹង គាត់មានស្រែក ស្តីឲ្យ ជេរអីដែរអត់ ឬក៏អត់មាត់ទេ?

នី: គាត់ឃើញធ្វើអញ្ចឹង គាត់ក៏ហៅចុះមក ដល់ពេលជាងចុះមកដល់ ជាងគាត់សួរថាម៉េចបង ហើយគាត់ថាសួរស្អីក៏ចេះៗ ដល់ពេលមកធ្វើៗខុស ថាឲ្យកំហកៗអញ្ចឹងក៏ឆក់កូនពូថៅពីដៃ ជាងហ្នឹងទក្បាលជាងដោះ អុកគូទស្រុប ។

ដានី: កាលហ្នឹងពូនៅចម្ងាយប៉ុន្មានពីកន្លែងហ្នឹង?

នី: ខ្ញុំនៅចម្ងាយប្រហែលពីដើមស្វាយមកហ្នឹង ខ្ញុំនៅកន្លែងហ្នឹង ហើយកន្លែងហ្នឹងជាកន្លែងជាង កាត់សក់ ខ្ញុំទៅកាត់សក់ ។

ដានី: ហើយជាងកាត់សក់ហ្នឹងជាងមកពីណាមក?

នី: ជាងហ្នឹងជាងនៅក្នុងកងពលហ្នឹង ហើយគាត់ហ្នឹងជាអ្នករៀបរយ តាមុត ហ្នឹងគាត់អ្នករៀប រយថាឲ្យម្នាក់ហ្នឹងជាជាងកាត់សក់ ឯខ្ញុំហ្នឹងគឺខ្ញុំកម្លាំងនៅកំពង់ផែទេ តែផ្ទះខ្ញុំនៅជិតហ្នឹង ផ្ទះ ខ្ញុំនៅជិតផ្សារហ្នឹងដែរ ដល់ហើយកាត់សក់កាត់អីហ្នឹងក៏ទៅហ្នឹង ព្រោះជាងហ្នឹងក៏វាស្គាល់គ្នា ព្រោះនៅសង្គ្រាមនៅកងជាមួយគ្នា រៃជាមួយគ្នា ហើយបាយទឹកជាមួយគ្នា ។

ដានី: ជាងហ្នឹងឈ្មោះអី?

នី៖ ឈ្មោះ រិ ។

ដានី៖ អ្នកស្រុកណាដែរ?

នី៖ អ្នកស្រុកកំពង់ស្ពឺ តែកំពង់ស្ពឺមកយើងម៉ាជំនៀខាងកើតទំនប់ស្រះចាន់បន្តិច ខាងលិចរោងចក្រ ។

ដានី៖ គាត់នៅរស់ដែរ?

នី៖ មិនដឹងជាយ៉ាងម៉េចទេ ។

ដានី៖ អត់ដែលឃើញទេ?

នី៖ អត់ដែលឃើញទេ ព្រោះកាលពីជំនាន់ហ្នឹងក្រោយពេលពីខ្ញុំនៅកម្មករហ្នឹងហើយដឹងថាក្រោយមកគេដកពីជាងកាត់សក់ ហើយនៅនឹងជាងកាត់សក់ហ្នឹងខ្ញុំអញ្ចឹង ថ្ងៃ១០-២០ កន្ទេនខ្ញុំហ្នឹងវាមានកម្មវិធី ។

ដានី៖ កម្មវិធីអីគេ?

នី៖ មានកម្មវិធីហូបចុកដូចជាប៊ីយា ហើយមានម្ហូបចំណីទំគ្រប់ប្រភេទ ជាលក្ខណៈទំប៉ុងជាអីហ្នឹង ក្នុងមួយខែមាន៣ដង ១០ថ្ងៃម្តង ដល់ពេលអញ្ចឹងកាត់សក់កាត់អីខ្ញុំក៏ប្រាប់ថា មិត្តឯងឈានចូលទៅផ្ទះខ្ញុំបន្តិច ថ្ងៃ១០ថ្ងៃ២០ចូលទៅ ហើយបារីក៏មិនខ្វះដក់ដែរ ថ្ងៃ១០ថ្ងៃ២០ហ្នឹង ហើយវាមានបៀមានអីផឹក ដល់ពេលអញ្ចឹងគ្នាក៏មក ហើយមកមិនទាន់នឹងបានផឹកស៊ីផង ហើយមកហ្នឹងក៏អត់ហ៊ានអង្គុយយូទៀត គ្នាមកប្រហែលជា១០នាទី ហើយខ្ញុំក៏ឲ្យបារីទៅ២សុង ខ្ញុំថាឯងយកបារី២សុងទៅ បារីអញជក់មិនអស់ទេនៅសល់ពេញៗទូ ។

ដានី៖ បារីម៉ាកអីគេ?

នី៖ បារីសេក ។

ដានី៖ បារីសេក?

នី៖ បាទ! កាលជំនាន់ហ្នឹងមានបារីសេក ហើយនឹងបារីស្លឹកមាស ។

ដានី៖ អាហ្នឹងសល់ពីមុនមកឬមួយក៏គេធ្វើ?

នី៖ ធ្វើ ។

ដានី៖ ធ្វើកាលពីជំនាន់ហ្នឹងដែរ?

នី៖ បាទ! បារីហ្នឹងធ្វើនៅរោងចក្រ«ប៨» ។

ដានី៖ ប«៨»នៅណា?

នី៖ នៅភ្នំពេញ ។

ដានី៖ អញ្ចឹងយ៉ាងម៉េចពេលទៅហ្នឹង?

នីៈ ដល់រួចហើយយកបារីហ្នឹងទៅ របៀបថាមនុស្សវាគ្រង់ហ្នឹងគ្នា យកបារីហ្នឹងទៅយកទៅដាក់ នៅហ្នឹងកន្លែងសម្រាកហ្នឹងក៏អ្នកនៅជាមួយគ្នាហ្នឹងក៏ឲ្យអ្នកចេះដក់ហ្នឹងឲ្យគេទៅណា៎ ហើយ តាមខ្ញុំប្រាប់ថាចេះតែចែកគ្នាដក់ទៅ ហើយបើអស់មកយកទៀតទៅ ព្រោះខ្ញុំអត់បានចេញ ចូលញឹកទេ ព្រោះការងារក្នុង២៤ម៉ោងត្រូវធ្វើ៨ម៉ោង ព្រោះអាជីពកម្មករ ហើយ២៤ ម៉ោងត្រូវធ្វើ៨ម៉ោង បើអញ្ចឹងពេលទំនេរវាតិច បើអញ្ចឹងការងារឯងជិតឯងមកយកទៅ ។

ដានីៈ ដាងកាត់សក់ហ្នឹង?

នីៈ បាទ! ដល់ពេលហើយបែកការអារឿងមកយកបារីពីខ្ញុំ យកបារីពីកន្លែងខ្ញុំយកទៅដក់ហ្នឹង ដឹង គេក៏ដកគ្នាឲ្យទៅធ្វើស្មៅនៅអូរគ្រេះ ។

ដានីៈ អញ្ចឹងមិនមែនយកទៅវត្តឥត្តញ្ញាណទេ?

នីៈ អត់ទេ ដោយគេដឹងពីប្រវត្តសកម្មភាពពីដើមមកណា ដល់ពេលអញ្ចឹងគេដកឲ្យទៅធ្វើស្មៅ ។

ដានីៈ ពីណាគេជាអ្នកដក?

នីៈ មុត ហ្នឹង ។

ដានីៈ អញ្ចឹង?

នីៈ បាទ!

ដានីៈ គាត់ដឹងគាត់ដកហ្មង?

នីៈ បាទ!

ដានីៈ អញ្ចឹងមុនពេលដែលគាត់កាប់ក្បាលដាងហ្នឹង ក្រោយហ្នឹងទៀត?

នីៈ ក្រោយ ។

ដានីៈ ចុះកាលឃើញ តាមុត គាត់កាប់ក្បាលដាងហ្នឹងកាលហ្នឹងឃើញតែពូហើយនឹងដាងកាត់សក់ ហ្នឹងទេ?

នីៈ បាទ!

ដានីៈ អត់មានពីណាឃើញទៀតទេ?

នីៈ មានអ្នកផ្សេងទៀត មាននារីៗដែលនៅចេញចូលនៅកន្លែងឡូនំប៉័ង គេឃើញដែរ ។

ដានីៈ ប៉ុន្តែពេលពូឃើញអញ្ចឹងមានអារម្មណ៍យ៉ាងម៉េចដែរ ពេលឃើញគេកាប់ស្រស់ៗអញ្ចឹង?

នីៈ មានអារម្មណ៍ថា បើសិនជាខ្លួនឯងខុសវិញមិនដឹងជាយ៉ាងម៉េចទេ ព្រោះសមាសភាពកម្លាំង នៅមន្ទីរសុទ្ធតែកម្លាំងនៅក្នុងស្រុកក្នុងភូមិរបស់គាត់ ហើយគាត់ធ្វើដល់ថ្នាក់នេះ ហើយចុះ ទម្រាំឯងអ្នកដទៃ បើកើតបញ្ហាបែប ប៉ុន្តែខ្ញុំក្រោយពីហ្នឹងមកដកខ្លួនចេញពីកោះត្រល់មក ខ្ញុំរៀបកម្លាំងដាច់ដោយឡែក កម្លាំងខាងខ្ញុំនេះគឺត្រូវការគ្រប់គ្រងឲ្យជា គ្រិន ។

ដានី៖	ជាកម្មករវិញ?

នី៖	បាទ!

ដានី៖	អញ្ចឹងលែងជាកងទ័ពហើយ?

នី៖	លែងហើយ មកជា គ្រិន វិញ ឯផ្នែកខាងកងទ័ពនោះគឺខាង មាស មុត ហើយខាងនេសាទគឺតាឡូញ ។

ដានី៖	ចុះម៉េចបានជាអ្នកដែលជាប់នៅវត្តឥតគ្រូញាណគឺ តាឡូញ ជាអ្នកគ្រប់គ្រងទៅវិញ បើតាឡូញ អ្នកនេសាទ?

នី៖	តាឡូញ អ្នកគ្រប់គ្រង តាឡូញ គាត់ខាងនេសាទគាត់អ្នកផ្គត់ផ្គង់ណា ហើយម្យ៉ាងនៅជិតហ្នឹងគាត់ហ្នឹង ក៏ មុត ហ្នឹងឲ្យ តាឡូញ អ្នកគ្រប់គ្រង ឯចំពោះសួរចម្លើយកំណត់ហេតុអីនោះ តាឡូញ អត់ទេ ។

ដានី៖	ពីណាគេវិញអញ្ចឹង?

នី៖	មាស មុត ដដែលហ្នឹង តាឡូញ គាត់គ្រាន់តែមានការផ្គត់ផ្គង់ប៉ុណ្ណឹងឯង ។

ដានី៖	គាត់ផ្គត់ផ្គង់ជាស្បៀង?

នី៖	បាទ!

ដានី៖	ប៉ុន្តែអ្នកសួរចម្លើយអីហ្នឹងបញ្ជូនបញ្ចេញអីគឺ តាមុត?

នី៖	ហ្នឹងហើយ មាស មុត ទេជាអ្នកបញ្ជូនបញ្ចេញ ។

ដានី៖	កាលហ្នឹងពូដឹងអញ្ចឹង?

នី៖	បាទ!

ដានី៖	ឃើញ តាមុត គាត់អាសារចេញចូលនៅហ្នឹងដែរ?

នី៖	បាទ!

ដានី៖	ចុះដូចជាងដែលគាត់កាប់ហ្នឹង ពេលដែលដួលអញ្ចឹងទៅយ៉ាងម៉េច គេមានយកទៅពេទ្យទេ?

នី៖	អត់ឲ្យយកទៅពេទ្យទេ ។

ដានី៖	អត់ឲ្យយកទៅពេទ្យទេ?

នី៖	បាទ!

ដានី៖	គាត់ប្រាប់អញ្ចឹងហ្នង?

នី៖	គាត់ថាអាណាយកទៅពេទ្យ អាហ្នឹងត្រូវទៀត ។

ដានី៖	គាត់ថាអញ្ចឹងហ្នង?

នី៖ បាទ!

ដានី៖ គាត់ថាពីណាគេ?

នី៖ ថាឲ្យអ្នកដែលឃើញ អ្នកដែលឮហ្នឹង ដល់ពេលអញ្ចឹងមានអ្នកណាហ៊ានទៅទៀត អត់មានទេ

ដានី៖ ហើយយ៉ាងម៉េចទៅម្នាក់ហ្នឹង?

នី៖ ម្នាក់ហ្នឹងយកដៃខ្ទប់ហើយដើរចូលក្នុងផ្ទះខ្លួនឯងទៅ ហើយរួចហើយ មុត ហ្នឹងក៏ជិះឡានទៅបាត់ទៅ ប៉ុន្តែអ្នកជួយគឺជួយហើយ ដល់ពេលឡានគាត់ចេញទៅផុត ។

ដានី៖ តែម្នាក់ហ្នឹងនៅរស់ទេ?

នី៖ អត់អីទេ តែរួចមកឆ្នាំ៧៩នេះមិនដឹងជាទៅណាទៅណីទេ ។

ដានី៖ ឈ្មោះអីអ្នកដែលគេកាប់ហ្នឹង?

នី៖ ខ្ញុំឮសួរជាងហ្នឹងហៅដូចជា ហាក់ ដូចជាបើមិនឈ្មោះ ហាក់ ឈ្មោះ លន ។

ដានី៖ អញ្ចឹងកាលហ្នឹងគេភ័យគ្រប់គ្នា?

នី៖ អ្នកដែលឃើញៗហ្នឹងសុទ្ធតែព្រឺព្រួចគ្រប់តែគ្នាហ្នឹង ។

ដានី៖ តែមើលទៅរបួសហ្នឹងធ្ងន់ទេ?

នី៖ របួសហ្នឹងអាចគួរសមដែរ កាប់ចំជ្រុងចញ្ចើម ។

ដានី៖ អញ្ចឹងគាត់កាចសាហាវដែរ?

នី៖ កាចណាស់ ។

ដានី៖ ចុះកូនទាហានយ៉ាងម៉េចដែរ បើខុសគាត់ដាក់ទណ្ឌកម្មយ៉ាងម៉េចដែរ គាត់ធ្វើអីយ៉ាងម៉េចខ្លះទៅ?

នី៖ កូនទាហាន ដែលរឿងទាហានច្បាំងហ្នុងអត់សួរអីទៅវិញ ល្អមដែរទេ ប៉ុន្តែគ្រាន់ថាបញ្ហាឲ្យធ្វើអីត្រង់ណាត្រូវតែសម្រេចត្រង់ហ្នឹង ។

ដានី៖ អញ្ចឹង?

នី៖ បាទ! បើបញ្ហាថាយប់នេះត្រូវទៅផ្ដាច់ស្ពានកន្លែងនេះ ឲ្យសម្រេច តែបើសិនជាមិនសម្រេចវិញឲ្យមានមូលហេតុច្បាស់លាស់ ។

ដានី៖ បើអត់មានមូលហេតុយ៉ាងម៉េចវិញ?

នី៖ បើអត់មានមូលហេតុកំណត់ថាយើងមិនមានមូលហេតុត្រឹមត្រូវចំពោះភារកិច្ច ដល់ពេលអញ្ចឹងឋិតក្នុងសភាពតាមដានទៀតហើយ ។

ដានី៖ អញ្ចឹងនៅក្នុងកងទ័ពយើងមាន អាអញ្ចឹងយើងដឹងហ្នុង?

នីៈ បាទ! ដឹង តាមដានខ្លួនឯងឲ្យច្បាស់ តាមដានសកម្មភាពខ្លួនឯងហ្នឹងដែលយើងជាម្ចាស់ខ្លួនហ្នឹង ឧទាហរណ៍ថាយើងប្រគល់ភារកិច្ចឲ្យធ្វើអីមួយ ត្រូវធ្វើឲ្យសម្រេច បើមិនសម្រេចត្រូវធ្វើឲ្យមានមូលហេតុគួរឲ្យទុកចិត្តបាន ប៉ុន្តែបើរបៀបថាឆ្លើយនិយាយមិនច្បាស់ មិនលះអាហ្នឹងស្ថិតក្នុងសភាពតាមដានហើយ ។

ដានីៈ អាហ្នឹងយើងត្រូវដឹងអញ្ចឹងហើយ?

នីៈ បាទ! យើងកំណត់ដូចថាឆ្លងកាត់សភាពការណ៍សង្គមមួយៗ យើងដឹងថាសង្គមណាក៏ដោយ អ្នកដឹកនាំលំដាប់ជំនាន់ណាក៏ដោយ ហើយក៏អត់ខុសពាក្យស្លោកដែរ ពាក្យស្លោកថា "អ្នកដែលធ្វើវៀច ច្រើនតែអ្នកតាតម្រង់ ប៉ុន្តែដល់ពេលអ្នកធ្វើត្រង់ ទីបំផុតច្រើនតែអ្នកតាកាច់" អាហ្នឹងមូលហេតុអី មូលហេតុមកពីយើងវាត្រង់ពេក អត់ហ៊ានអារឿងព្រលើស អារឿងអោបដៃអោបជើងណា យើងវាមិនចេះណា ចង់យើងធ្វើម៉េចយើងឆ្លើយអញ្ចឹង ដល់ពេលអញ្ចឹងហើយរឿងអ្នកតាកាច់ ។

ដានីៈ ច្រើនតែត្រូវមេ?

នីៈ ហ្នឹងហើយ ហើយមេរបៀបដូចថាមើលទៅឲ្យតែយើងចេះអោបដៃអោបជើងអីបន្តិចទៅ អាបុណ្យឡើងតាមជើងខោហ្នឹងចេះតែឡើងហើយ បើមនុស្សមិនចេះអោបដៃអោបជើងគេហ្នឹងចប់ហើយ ដូចខ្ញុំមិនអញ្ចឹង តែមិនចេះអោបដៃអោបជើងគេទេដ្បិបមិននៅទេ ។

ដានីៈ ចុះពូ កន្លែងដែលពូឲ្យបារីគេ គេរករឿងតែជាងកាត់សក់ដែលយកបារីពីពូ ហើយពូគេអត់រករឿងពូទេ?

នីៈ នៅអង្គភាពផ្សេងគ្នា ។

ដានីៈ អង្គភាពផ្សេងគ្នា?

នីៈ បាទ!

ដានីៈ អញ្ចឹងបើសិនជាពូនៅកងទ័ពជាមួយគ្នាដែរយ៉ាងម៉េចទៅ?

នីៈ បើសិនជានៅកងទ័ពជាមួយគ្នា វាអត់មានរបបលើស ។

ដានីៈ អត់មានរបបលើស?

នីៈ បាទ! ដោយឡែកអង្គភាពខុសអញ្ចឹងបានមានរបបលើស ព្រោះរបបអង្គភាពខ្ញុំវាមានរបបលើស យ៉ាងម៉េច មកពីធ្វើការជាមួយភ្ញៀវចិន ។

ដានីៈ ជាមួយ តាគ្រិន ហ្នឹង?

នីៈ បាទ! ដល់ពេលអញ្ចឹងទៅអ្នកមុខមាត់នយោបាយជាមួយបរទេស ត្រូវការផ្គត់ផ្គង់តាំងពីសម្លៀកបំពាក់ ហូបចុកគ្រប់គ្រាន់បរិបូរ ដើម្បីរក្សាសាច់ឈាមកម្លាំងពលកម្ម ។

ដានី៖	អញ្ចឹងពូដែលខានទៅជាកម្មករជាមួយ តាគ្រិន ហ្នឹងតាំងឆ្នាំ៧៩ ពេលដែលពូមកពី?

នី៖	ត្រលប់ពីកោះត្រល់មកវិញ ។

ដានី៖	អញ្ចឹងតាំងពីឆ្នាំ៧៩មកធ្វើកម្មករវិញ?

នី៖	ធ្វើកម្មករ ។

ដានី៖	ចុះពូកាលហ្នឹងជាស្អីគេ ជា?

នី៖	កម្មករហ្នឹង ខ្ញុំមកជាប្រធានអនុសេនាតូច ។

ដានី៖	ប្រធានហ្នឹងអីគេ អ្នកយាមមែន?

នី៖	ជាកម្មករលើកដាក់ក្នុងកប៉ាល់ហ្នឹង ។

ដានី៖	លើកដាក់ឥវ៉ាន់ហ្នឹង?

នី៖	បាទ!

ដានី៖	ប៉ុន្តែកាលហ្នឹងយើងមានតួនាទីជាកងទ័ពដដែល?

នី៖	មានតួនាទីជាកម្មករផង ការពារកំពង់ផែហ្នឹងផង ។

ដានី៖	ហើយមានកាំភ្លើងដែរ?

នី៖	កាំភ្លើងមាន ។

ដានី៖	គេហៅប្រធានអនុសេនាតូច?

នី៖	បាទ!

ដានី៖	អញ្ចឹងយើងលើកដាក់ផង យើងមានតួនាទីការពារផង?

នី៖	បាទ!

ដានី៖	តែនៅក្រោម តាគ្រិន ទេ?

នី៖	តាគ្រិន គាត់ប្រធានមួយកំពង់សោមហ្នឹងហ្នឹង ។

ដានី៖	ចុះដូចថាអ្នកដែលខុសនៅកំពង់ផែអញ្ចឹង បើគេមានទិន្នាការដូចទាហានហ្នឹងដែរអត់ទេ?

នី៖	ទាល់តែខ្លាំង ក្តាប់កម្លាំងដែលនៅជាមួយ ជា គ្រិន ហ្នឹង បើខុសលើកទីមួយមានការណែនាំអប់រំ លើកទីពីរមានការណែនាំអប់រំ ហើយលើកទីបីកែប្រែអាហ្នឹងរុញបញ្ចូលទៅហ្នឹងដែរ ។

ដានី៖	ទៅវត្តឥត្តញ្ញាណហ្នឹងដែរ?

នី៖	បាទ! ហើយបើម្តងមិនប៉ះដៃយក ប៉ះជើងយកជើងទេ អាហ្នឹងចំពោះ ជា គ្រិន ណាំ របៀបថាមនុស្សគាត់វាស្ថិតក្នុងសភាពការណ៍ដឹកនាំហ្នឹង ហៅថាមានព្រំវិហាធម៌ត្រឹមត្រូវដែរ ។

ដានី៖ ចុះ តាមុត?

នី៖ មុត អត់ទេ អត់បាច់មានលើកទី២លើកទី៣អីទេ ។

ដានី៖ តែខុស?

នី៖ តែខុសដឹងហើយ ។

ដានី៖ ប៉ុន្តែដល់ពេលនៅវត្តឥត្តញ្ញាណមិនមែន តាគ្រិន ទៅគ្រប់គ្រងទេ?

នី៖ អត់ទេ ។

ដានី៖ ទៅតែ តាមុត ម្នាក់ទេ?

នី៖ បាទ! មានតែ មុត ម្នាក់ទេដែលចាត់ចែង អ្នកសម្រេច ហើយការផ្គត់ផ្គង់ពី តាឡូញ ទេ ។

ដានី៖ ពូដឹងហ្នឹងអាហ្នឹង ម៉េចបានពូដឹងថាមានតែ តាមុត តែម្នាក់ឯង?

នី៖ ចុះបើគាត់ផ្តាច់មុខអស់ហើយ ដោយឡែកតែក្នុងជើងគណៈកម្មាហ្នឹងបានវានៅជាប់ជាគណៈកម្មា ឧទាហរណ៍ថាមាន មាស មុត មាន ជា គ្រិន នឹងមាន តាឡូញ មាន៣នាក់ហ្នឹង ហើយ៣នាក់ហ្នឹងជាជើងគណៈកម្មាសម្រាប់មួយកំពង់សោមហ្នឹង ប៉ុន្តែគ្រាន់តែផ្នែកគ្រប់គ្រង ផ្នែកដឹកនាំអង្គភាពដាច់ៗពីគ្នា ជា គ្រិន ហ្នឹងគាត់ខាងជីវកសហគ្រាសទៅ ឯខាង មាស មុត ខាងយោធា ហើយ តាឡូញ នោះគាត់ខាងនេសាទផ្គត់ផ្គង់សម្រាប់អង្គភាពរដ្ឋទៅ អាហ្នឹងវាមានផ្នែកខុសគ្នាអញ្ចឹងទៅ តែបើមានដែនការណ៍អីគឺក្នុងជើងគណៈកម្មារបស់គាត់ត្រូវតែមានការពិគ្រោះគ្នា ។

ដានី៖ អញ្ចឹងយោធាជាអ្នកគ្រប់គ្រងកន្លែងឥត្តញ្ញាណហ្នឹង?

នី៖ បាទ! យោធាជាអ្នកគ្រប់គ្រង ។

ដានី៖ ចុះពូនៅកន្លែងកំពង់ផែ ហើយនៅការពារកំពង់ផែហ្នឹងរហូតដល់ពេលណាដែរ?

នី៖ រហូតដល់ថ្ងៃទីប៉ុន្មានទេ ហើយខ្ញុំនៅធ្វើកម្មករនៅកំពង់ផែហ្នឹងបាន១ឆ្នាំកន្លះ នៅលើកដាក់ឥវ៉ាន់ហ្នឹង រួចក៏គេដកចេញពីហ្នឹងឲ្យមករៀនបច្ចេកទេសជាមួយចិនដីគោក ខាងធ្វើដៃប្រេង

ដានី៖ ដៃប្រេង?

នី៖ បាទ!

ដានី៖ ទៅរៀននៅណា?

នី៖ រៀននៅរោងចក្រហ្នឹងហ្នង ។

ដានី៖ នៅកំពង់សោមហ្នឹង?

នី៖ បាទ!

ដានី៖ ហើយឆ្នាំណាបានពូចេញពីកំពង់ដៃហ្នឹងមករៀនបច្ចេកទេស?

នី៖ មិនដឹងថ្ងៃណាខែណាទេ តែដឹងតែនៅអន្តភាពលើកដាក់ហ្នឹងនៅបាន១ឆ្នាំកន្លះ ប៉ុន្តែចេញពីហ្នឹងមករៀនបច្ចេកទេសបាន១ឆ្នាំកន្លះទៀត បាន១ឆ្នាំកន្លះហើយរៀបនឹងដល់ដំណាក់កាលរត់នេះ គេហៅឲ្យឡើងឡានទៅវៃនៅព្រៃវែង ។

ដានី៖ មកខាងព្រំដែនខាងកើតវិញ?

នី៖ បាទ!

ដានី៖ ឆ្នាំណាហ្នឹង?

នី៖ ចូល៧៩ហើយ ។

ដានី៖ យ៉ាងម៉េចទៅ បានទៅវៃនៅព្រៃវែងបានយ៉ាងម៉េខ្លះ?

នី៖ វៃនៅព្រៃវែង ហើយអត់បាយក្រហាយទឹក ។

ដានី៖ នៅកន្លែងណា?

នី៖ មិនដឹងនៅត្រង់ចំនុចកន្លែងណាទេ ខ្ញុំមិនស្គាល់ច្បាស់ទេ តែចូលទៅតាមច្រកពារាំង ។

ដានី៖ ចូលតាមពារាំង?

នី៖ បាទ! ចូលសំដៅទៅអូរាំងឪ ។

ដានី៖ ចាក់ទៅតាមកំពង់ចាមវិញ?

នី៖ បាទ! ទៅនាខាងជើងបន្តិច ។

ដានី៖ ពីស្វាយខ្ទុរទៅអូរាំងឪ ហើយអញ្ចឹងចូលទៅកំពង់ចាមហើយ?

នី៖ បាទ!

ដានី៖ ហើយពូទៅហ្នឹង ពូចូលទៅក្នុងកងពលណាវិញទៅ?

នី៖ នៅហ្នឹងគេបញ្ចូលទៅក្នុងកងពល១៦៤ ។

ដានី៖ ១៦៤ដដែលហ្នឹង?

នី៖ បាទ!

ដានី៖ អញ្ចឹងកងពល តាមុត ហ្នឹងឡើងទៅវៃនៅព្រំដែនខាងកើតដែរអញ្ចឹង?

នី៖ កងកម្លាំង៣០ភាគរយ ។

ដានី៖ ដក៣០ភាគរយ?

នី៖ បាទ! ដោយឡែកតែពួកជើងទឹកទេ ពួកនាវាចរណ៍នៅទាំងអស់ អត់មានការដកហូតទេ ។

ដានី៖ តាមុត គាត់ទៅដែរ?

នី៖ អត់ទេ គាត់នៅ ។

ដានី៖ វេបានរយៈពេលប៉ុន្មានទៅបានយួនចូលឆ្នាំ៧៩ហ្នឹង ។

នី៖ វៀតណាមវេចូលហ្នឹងវេពីរសារ វេមួយសារមុនដំបូងឆ្នាំ៧៨តែមិនដឹងខែប៉ុន្មានទេខ្ញុំមិនចាំទេ រួចហើយក៏វៀតណាមដកវិញមួយសារ ហើយមិនចាំទេអារឿងថ្ងៃខែវេលើកទី២ ដល់ពេលវេលើកទី២ហ្នឹងហើយបានប្រមែលប្រមូលពួកខ្ញុំពីកំពង់សោមពីអីមក ហើយទៅវេនៅហ្នឹង ចូលវេនៅផ្លូវហ្នឹង ហើយនៅជិនារណាទេ ប៉ុន្តែដឹងតែពួកខ្ញុំហ្នឹងទៅវេមួយជិនារ ជាយម៉ាផ្លូវខ្សែស្របកំពង់ចាមហើយនឹងព្រៃវែង ។

ដានី៖ បានរយៈពេលប៉ុន្មានដែរ បើគិតជាខែគិតជាថ្ងៃ?

នី៖ ទៅមួយភ្លែតហ្នឹង មិនដឹងប៉ុន្មានថ្ងៃទេ ដូចជាមិនដល់មួយខែទេ ។

ដានី៖ អាហ្នឹងយ៉ាងម៉េច យើងទប់លែងបានមែន?

នី៖ មកពីកម្លាំង កម្លាំងកន្លែងខ្ញុំហ្នឹងគឺ បើសិនជាសភាពការណ៍មិនប្រថុចញុចគេអត់ដកទេ ព្រោះកម្លាំងចាំបាច់កន្លែងបច្ចេកទេសហ្នឹង ទាល់តែចាំបាច់អញ្ចឹងបានដក ដល់ពេលដកទៅគ្រាន់តែពួកខ្ញុំទៅដល់អូរាំងឳមិននឹងទាន់បានវៃផង កម្លាំងហ្នឹងបាក់ពីនោះមកបាត់ហើយ ហើយមកព្រោងព្រាត ។

ដានី៖ ខាងខ្មែរយើងហ្នឹង?

នី៖ បាទ! ដល់ពេលមកព្រោងព្រាត គេផ្ញើសារមកកន្លែងទីចាត់ការអគ្គសេនាធិការ ។

ដានី៖ កាលហ្នឹងពីណាគេអគ្គសេនាធិការ?

នី៖ អត់ស្គាល់?

ដានី៖ អត់ស្គាល់ទេ?

នី៖ បាទ! ខ្មោច តាវ៉ែន ហ្នឹងបញ្ជាឲ្យគេផ្ញើសារមក ដល់ពេលផ្ញើសារមកស្រាប់តែមានពុស្ទូរភាសាខ្មែរតបសារណា សុទ្ធតែវៀតណាមញ៉ាវញ៉ាវៗពេញហ្នឹង ដល់ពេលអញ្ចឹងនាំគ្នាថាអុញ! អស់អាលីងហើយ ដល់ពេលអស់អាលីងហើយនាំគ្នាទាក់ទងមកផ្លូវលេខ៧ តែផ្លូវលេខ៧ជាប់ ទាក់ទងមកផ្លូវលេខ៦ជាប់ អុញជាប់អស់ហើយទៅណាអញ្ចេះ អញ្ចឹងក៏ប្រមូលនាំគ្នាឈប់សម្រាកនៅហ្នឹងស្ពាយពុល នៅហ្នឹងកន្លែងសាលាស្រុកពារាំងហ្នឹងហ្នង ដល់ពេលអញ្ចឹងនៅឈប់ចាំគ្នាហ្នឹង ប្រមូលគ្នា ដល់ពេលប្រមូលគ្នាប្រមូលកងទ័ពប្រមូលអីទាំងអស់ ប្រមូលហើយរៀបចំកម្លាំងវេបើកផ្លូវឈាមឆ្លងកាត់ផ្លូវលេខ៧ ។

ដានី៖ បកថយក្រោយវិញហើយអាហ្នឹង?

នី៖ អត់ទេ វេមកមុខ វេកាត់មុខផ្លូវលេខ៦ វេឆ្លងហ្នឹងបានមកផ្លូវលេខ៦ ហើយវេផ្លូវលេខ៦ទៀត វេឆ្លងផ្លូវលេខ៦ហើយបានវេមកឆ្លងទន្លេ ហើយបានវេឆ្លងផ្លូវលេខ៥ទៀត ។

ដានី៖ វៃថយមកវិញ?

នី៖ បាទ!

ដានី៖ វៃជាមួយពីណាគេ?

នី៖ វៃជាមួយវៀតណាម ។

ដានី៖ ចុះកាលហ្នឹងទៅហ្នឹង តាវ៉ែន ជាអ្នកដឹកនាំ?

នី៖ បាទ! តាវ៉ែន គាត់គណៈសមរភូមិ ។

ដានី៖ គណៈសមរភូមិនៅណា?

នី៖ នៅម៉ាជួរមកពីព្រៃវែងហ្នឹងមករហូត និយាយទៅមួយមុខសញ្ញាស្រុកចន្ទ្រាទាំងអស់ហ្នឹងលើ តាវ៉ែន ទាំងអស់ហ្នឹង ។ ។

ដានី៖ គាត់គណៈសមរភូមិធំជាងគណៈកងពលទៀត?

នី៖ គណៈសមរភូមិធំជាងកងពល ហើយកងពលតូចនៅក្រោមឱវាទចាត់ចែងរបស់គាត់ទាំងអស់ ហើយខាងតាកែវនៅក្រោមការចាត់ចែងរបស់ តាម៉ុក ទាំងអស់ តាម៉ុក អ្នកបញ្ជាអ្នកចាត់ចែង ។

ដានី៖ ហើយតាវ៉ែន គាត់ទៅផ្ទាល់នៅសមរភូមិដែរ?

នី៖ ទៅផ្ទាល់ ។

ដានី៖ ហើយយ៉ាងម៉េចទៅពេលដែលយើងបកមក?

នី៖ បកមកវិញមកវៃឆ្លងផ្លូវលេខ៥ ហើយអស់ក៏ត្រលប់ក្រោយបែរវៃផ្លូវជាតិលេខ៥ហ្នឹងរហូត វៃផ្លូវជាតិលេខ៥ហ្នឹងហើយបានខ្លះមិនបានខ្លះក៏នៅទំនេរលើផ្លូវជាតិលេខ១០ ដកកម្លាំងពួកខ្ញុំ យករថក្រោះចេញត្រពាំងជោមករថក្រោះ៤គ្រឿងមកវៃផ្លូវជាតិលេខ១០ហ្នឹងទៀត វៃផ្លូវជាតិលេខ១០បានប៉ុន្មានខែទេ ក៏វៃចូលទៅដល់ភូមិស្វាយតាចៀវទៅ ហើយវៃទៅដល់ភ្នំសំពៅហើយក៏នៅត្រឹងត្រឹមហ្នឹង ដល់ពេលនៅត្រឹងត្រឹមហ្នឹងវៀតណាមមកពីផ្លូវកំពីងពួយមកចាក់ព័ទ្ធ ហើយចេញមកស្តៅនេះក៏ថយក្រោយមកវិញអស់មក ចាប់ផ្តើមចូលព្រៃហ្នឹងហ្មង ។

ដានី៖ ចូលព្រៃណា?

នី៖ ចូលព្រៃយើងស្រុកសំឡូត ។

ដានី៖ ហើយនៅសំឡូតរហូតទៅ?

នី៖ ចូលនៅសំឡូតហ្នឹងមិនមែននៅមួយកន្លែងទេ ដើរ ចុះបើដាច់រយៈអស់ហើយហ្នឹង មិនដឹងមេណាកើយណាទេមួយផ្នែកៗអស់ហើយ ដល់ពេលអញ្ចឹងដើរផ្ញើសារទូរលេខទាក់ទង

តាម៉ុក ហើយ តាម៉ុក គាត់ថាគាត់នៅហ្នឹងម៉ុងគិរីក្បាលគោយើងហ្នឹងស្រុកក្រវាំញនេះណា ហើយនាំគ្នាដើរពីសំឡូតមកជិតសាលាស្រុកឈ្មួនហ្នឹងមក ទៅដល់ម៉ុងគិរីក្បាលគោហ្នឹង ទៅដល់ហ្នឹងដើររក តាម៉ុក មិនឃើញក៏ផ្ញើសារម្ដងទៀត ហើយ តាម៉ុក តបមកវិញថាគាត់មកដល់ព្រំដែនថៃហើយ ។

ដានី៖ សារម៉េចទៅ?

នី៖ សារទូរលេខហ្នឹង ។

ដានី៖ ហើយគាត់ថាមកដល់ព្រំដែនថៃហើយ?

នី៖ បាទ! គាត់មកដល់ទល់ដែនថៃហើយ ហើយបានដាទៅដល់ហ្នឹងហើយ ដើរប្រមែលប្រមូលកម្លាំងដែលដាច់ដោចសេសសល់ហ្នឹងឲ្យមកព្រំដែនថៃឲ្យអស់មក ដល់ដំណាក់កាលហ្នឹងគឺជាដំណាក់កាលដែលលែងមានបាយហូបហើយ គល់ដំឡូងណាដែលហូបកើតគឺដីកទៅ ហូបជាដំឡូងហូបជាអីទៅ ចេះតែហូបបណ្ដើរដើរបណ្ដើរទៅ ។

ដានី៖ ហើយពេលណាបានមកដល់ទល់ដែន?

នី៖ ដើរទៅកម្លាំងប្រមូលបានច្រើនអញ្ចឹង ចុះធម្មតាកម្លាំងដែលច្រើនទៅនៅណាចេះស្ងាត់ ហើយកម្លាំងមិនមែនមានតែកម្លាំងកងទ័ពណា គាត់ឲ្យប្រមូលទាំងអស់ ទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេង ប្រមូលមកកុំឲ្យនៅក្នុងព្រៃ នៅក្នុងព្រៃរកអីហូបមិនបានទេ ដាច់ពោះស្លាប់ បើអញ្ចឹងត្រូវប្រមូលយកមកដាក់នៅក្នុងព្រំដែនថៃមក វាស្រួលផ្គត់ផ្គង់ អញ្ចឹងប្រមូលកម្លាំងបានច្រើនហើយបែកការណ៍វៀតណាមនាំកម្លាំងមកវ៉ៃកាត់ហើយបែកអស់ រួចអញ្ចឹងក៏គេចមួយសារទៀតបានលែងគិតរឿងប្រមូលកម្លាំង ហើយចាប់ផ្ដើមដើរហើយលែងប្រមូលហើយ ដើរសំដៅព្រំដែនថៃ ។

ដានី៖ នៅណាព្រំដែនថៃ?

នី៖ កន្លែងព្រំដែនថ្មដារហ្នឹង ។

ដានី៖ ព្រំដែនថ្មដារ?

នី៖ បាទ! ដើរពីនោះមក ចុះអត់មានកម្លាំង អត់មានបាយ ហូបតែដំឡូង ហូបតែក្ដួច ហើយមនុស្សដល់ខ្សោយអញ្ចឹងហូបមិនបានទេ ។

ដានី៖ ពុលមែន?

នី៖ ពុល ហើយមានអំបិលមានអីមកពីណាអត់មានទេ របៀបថាយើងចិតសំបក ឧទាហរណ៍ថាយើងដើរថ្ងៃអញ្ចឹងជួបក្ដួចជីកក្ដួច ហើយដើរបណ្ដើរចិតបណ្ដើរ ចិតជាសំបកវាឲ្យហើយទៅណា ដល់ពេលថ្ងៃល្ងាចប្រុងនឹងសម្រាកបានចាប់ផ្ដើមចិតវាចំណិតដាក់ឆ្នាំងស្ងោរ ស្ងោរ

វាពាទឹកអី ស្មោរមួយពុះចាក់ចោលៗ ហើយនៅតែហូបពុលដែរ អាហ្នឹងមកពីយើងខ្សោយ តែបើគេអ្នកនៅកម្លាំងខ្លាំងគេហូបមិនពុល ប៉ុន្តែគ្រាន់តែពុលក្អួចមួយម៉ោងពីរម៉ោងអញ្ចឹង ទៅងើបអង្គុយដើរគេគាស់ ទ្រឹកទ្រឹកបាន ពុលក្អួចអញ្ចឹង ។

ដានី៖ ហើយពេលណាទៅបានមកដល់?

នី៖ រយៈពេលដើរពីមុនគិរីមកព្រំដែនថៃនេះ១៨ថ្ងៃដល់ព្រំដែនថៃ ដល់ពេលដល់ព្រំដែនថៃចុះនៅលើដីថៃហ្នឹង ហើយពេលចុះទៅជួបប្រជាជនថៃ ហើយគេទៅរាយការណ៍ឲ្យតម្រួតគេ តម្រួតគេក៏មកសួរ មកសួរយើងពីដើមមុនវៀតណាមចូលស្រុកនៅឯណា ហើយបើឆ្លើយថានៅកោះកុងអត់បានទេ ទាល់តែឆ្លើយថានៅភ្នំពេញ នៅតាកែវ នៅព្រៃវែង នៅស្វាយរៀង នៅកំពង់ចាម នៅកំពង់ធំបានរួចខ្លួន ។

ដានី៖ ម៉េចបាននៅកោះកុងអត់បាន?

នី៖ ចុះបើនៅកោះកុង នៅកំពង់សោម សុទ្ធតែទាហានជើងទឹកធ្វើបាបថៃ ចាប់បាញ់កប៉ាល់នេសាទថៃ ហើយប្រជាជនថៃអីពាសទឹកពាសដី ដល់ពេលអញ្ចឹងទៅវាស្អប់ វាគុំ ឲ្យតែអ្នកនៅកំពង់សោមហើយនឹងកោះកុង ពួសួរហ្នឹងអត់បានទេយកទៅដាក់ទ្រុងកាកែវហើយ ។

ដានី៖ ដល់ហើយយ៉ាងម៉េចទៀត?

នី៖ ដល់ពេលរួចពីតម្រួតថៃមកសម្ភាសន៍ ហើយយើងប្រាប់វាតាមដំណើរទំនងទៅ វាក៏នាំយើងឲ្យទៅនៅក្នុងប៉ុស្តិ៍វា ហើយវាហៅឡានថៃមកដឹកយើងយកទៅដាក់ជំរុំ ហើយចុះទៅនៅជំរុំថៃបានរយៈពេល៨យប់៨ថ្ងៃ ដល់ពេលបានរយៈពេល៨យប់៨ថ្ងៃហើយខ្ញុំក៏សុំមកនៅដីខ្មែរវិញ ។

ដានី៖ ជំរុំណាហ្នឹង?

នី៖ ជំរុំខាវឡាន ឡើងឡានថៃពីជំរុំខាវឡានទៅខ្លែមខាងជើង ។

ដានី៖ ខ្លែមខាងកំរៀងមែន?

នី៖ បាទ! ទៅចុះនៅហ្នឹង ដល់ពេលទៅចុះនៅហ្នឹងក៏ធ្វើទ័ពវិញទៀតហើយ ធ្វើទ័ពហ្នឹងបានរយៈពេលមួយឆ្នាំ ធ្វើបានមួយឆ្នាំ២ខែ រួចក៏ធ្លាក់ខ្លួនឈឺ ដល់ពេលធ្លាក់ខ្លួនឈឺក៏ប្រធានកងពលនោះលោក ថែ ។

ដានី៖ ឈ្មោះ ថែ?

នី៖ បាទ!

ដានី៖ ប្រធានកងពលនៅណា?

នីៈ ប្រធានកងពលនៅស៊ីសុផុន ស៊ីសុផុនខាងត្បូង គាត់ថាបើទៅណាមកណាមិនរួចអញ្ចឹងហើយ ទាហានវៀតណាមកំពុងតែបើកទ្រង់ទ្រាយវាតត្បាតបោសសម្អាតតាមខ្សែស្របព្រំដែន ដល់ពេលអញ្ចឹងមិនហ៊ានទុកនៅហ្នឹងអន្តរភាពទេ ក៏បញ្ជូនខ្ញុំមកប្រគល់ឲ្យកាកបទក្រហម កាកបទក្រហមក៏បញ្ជូនខ្ញុំឲ្យមកនៅជំរុំកំពុត ហើយមានពេទ្យកាកបទហ្នឹងនៅមើលការខុសត្រូវនៅហ្នឹង នៅមើលថែទាំអ្នកជម្ងឺគ្រប់សព្វ និយាយទៅកាកបទក្រហមហ្នឹងមកមើលថៃ ខ្មែរវាស្មើរបងប្អូនបង្កើតក៏មិនដល់ដែរ ស្មើរនឹងឪពុកម្តាយ ខ្មែរឈឺធ្លាក់ខ្លួនរាគ ដើរមិនរួច អាពួកកាកបទក្រហមជនជាតិអូស្រ្តាលី ជនជាតិអង់គ្លេស វាធាំទាហានថៃទៅដើរប្រមូលអ្នកដែលឈឺ ដែលដើរមិនរួច ហើយសែងយកមកដាក់នៅកន្លែង គេប្រើឲ្យទាហានស្រីថៃហ្នឹង ចុះថៃគេធ្វើការស៊ីប្រាក់ខែ ប្រើឲ្យបុគ្គលិកថៃហ្នឹងងូតទឹក ជូតខ្លួន ផ្លាស់សម្លៀកបំពាក់គ្រប់មុខឲ្យហើយ វាថតតាំងពីទឹកនោម តាំងពីលាមក ថតយកទៅពិនិត្យអីហើយបានវាព្យាបាល ជាទាំងអស់ ហើយដើររួចវិញទាំងអស់អ្នកដែលឈឺដើរមិនរួច ។

ដានីៈ បើអត់មើលដឹងតែស្លាប់ហើយ?

នីៈ បាទ!

ដានីៈ កាលហ្នឹងពូឈឺអីគេ?

នីៈ ខ្ញុំកាលហ្នឹងគ្រុនចាញ់ ។

ដានីៈ ធ្ងន់ទេ?

នីៈ ធ្ងន់ដែរ ប៉ុន្តែគ្រាន់តែបើពេលណាវាធ្វើទុកវាក្តៅញាក់អាហ្នឹងឈប់ រួចហើយបានក្តៅហើយស្វាង ហើយដើរទៅទៀត រួចហើយក្រោយពេលពីហ្នឹងខ្ញុំនៅជំរុំហ្នឹង៤សារ ហើយលួចរត់មកខ្មែរវិញ ដល់ពេលមកជិតដល់ព្រំដែនទាហានថៃចាប់បានដឹកយកទៅវិញ ហើយមកមួយសារទៀតពួកទាហានខ្មៅចាប់បាន ទាហានព្រៃហ្នឹងចាប់យកទៅវិញ ។

ដានីៈ ម៉េចអញ្ចឹង?

នីៈ វាចាប់អត់ឲ្យមក វាបញ្ជូនទៅឲ្យនៅជំរុំវិញ ។

ដានីៈ ពូអត់ចង់នៅជំរុំទេ ចង់តែមកនៅដីខ្មែរ?

នីៈ បើមិនចង់មកដីខ្មែរខ្លួនឯងវាអតីត ខ្ញុំនៅនោះប្រធានវរៈសេនាតូច ។

ដានីៈ ប្រធានវរៈសេនាតូច,

នីៈ បាទ! ដល់ពេលអញ្ចឹងឯងធ្លាក់ខ្លួនឈឺអញ្ចឹង ហើយកម្លាំងមហាជនគ្នានៅនឹងដី នៅច្បាំងនៅដើរ ហើយខ្លួនឯងជាហើយមិនរួតរះមកកាន់ការងារវិញ ។

ដានីៈ ហើយយើងអត់សុំគេថាយើងមកវិញទេ?

នីៈ គេឲ្យមកតើ ! ប៉ុន្តែអាពួកយួអិនត្រូហ្នឹងវាមិនឲ្យមកទេ ។

ដានីៈ ហេតុអីបានគេអត់ឲ្យមក?

នីៈ វាថាបើចង់មកកុំតែបានមកទេ ប៉ុន្តែក្រោយពេលស្រុកទេសអ្នកឯងសាន្តត្រាណសិន បើអ្នកឯងបង្ខំខ្លួនមកក្នុងស្រុកកំពង់តែច្បាំងគ្នាអញ្ចឹង អ្នកឯងត្រូវប្រឈមមុខនឹងលំបាកទៀត បើអ្នកឯងនៅហ្នឹងមានលំបាកអីទៀត ទឹកដឹកស្រាប់ ខសដុតស្រាប់ ហើយម្ហូបអង្ករអីគ្រប់មុខសុទ្ធតែរបស់ផ្គត់ផ្គង់ស្រាប់ទាំងអស់ តើអ្នកឯងនៅលំបាកត្រង់ណាប្រាប់ខ្ញុំមកមើល ។

ដានីៈ ហើយពូប្រាប់គេថាម៉េច?

នីៈ អត់ប្រាប់កើតទេ ប្រាប់ថាខ្ញុំចិត្តមិនដាច់ពីស្រុកទេស រួចគេសួរថាអ្នកឯងទាហានមែន ខ្ញុំថាខ្ញុំទាហាន អ៎! ពិតមែនហើយ រឿងទាហានគឺត្រូវតែមានទឹកចិត្តស្នេហាជាតិ បើអញ្ចឹងកុំអាលអី បើអ្នកឯងមិនទៅច្បាំងម្នាក់ក៏មានជនជាតិដូចគ្នា សាច់ឈាមដូចគ្នាគេច្បាំងដែរ អ្នកឯងកាត់ចិត្តទៅ មើលថែទាំខ្លួនប្រាណទៅមិនអីទេ រួចពីបីសារហើយចេញចូលៗយូៗទៅរហូតដល់ទៅមានមិត្តភ័ក្រ្តពួកម៉ាកស័ក្កា៣ថៃ ក្រោយពេលដែលមានពួកម៉ាកស័ក្កា៣ថៃហ្នឹងក៏ឈប់ដើរទៅណាទៅ ហើយចុះឡើងៗមិនកើតទេ មិនដឹងដើរទៅណាទេ ទៅណាមិនរួច ទៅគេបេះតែយកមកវិញ ហើយយកមករុញចូលឲ្យពួកយួអិនដដែលអញ្ចឹង បើអញ្ចឹងឈប់ហើយទៅណាមកណាទេកុំគិត ហើយគិតរឿងកសាងគ្រួសារម្តង ព្រោះបើមិនកសាងគ្រួសារជីវិតទទេសេរី សង្គមរបស់គេ យើងបិតជាជនអន្តោប្រវេសន៍ផង ជាខ្មែរអុកប្រយុគផង បើអញ្ចឹងវាឌុប បើអត់មានប្រពន្ធវាលំបាកណាស់ ពួកអាមនុស្សអត់ប្រពន្ធធម្មតាចិត្តមិនគិតអីច្រើនទេ ត្រូវទៅណាទៅហ្នឹងបាត់ហើយ បើគេដឹកនាំឲ្យទៅខូចអាហ្នឹងខូចនឹងគេដែរហើយ បើអញ្ចឹងហើយទាល់តែសម្រេចចិត្តថាយកគ្រួសារ ។

ដានីៈ អញ្ចឹងពូរៀបការនៅហ្នឹង?

នីៈ បាទ! នៅដីថៃហ្នឹង ។

ដានីៈ នៅជំរុំ?

នីៈ ជំរុំកំពុត ។

ដានីៈ ឆ្នាំណា?

នីៈ ខែ១២ ឆ្នាំ៨០ ។

ដានីៈ ហើយកាលហ្នឹងមីងគាត់ធ្វើអី?

នីៈ នៅនឹងមុខហ្នឹងដូចគ្នាដែរ គេជាអង្គភាពនារីដឹកជញ្ជូន ។

ដានីៈ ចេញពីដីខ្មែរ?

នីៈ បាទ! អ្នកមានធុរៈឈឺដូចគ្នា ។

ដានីៈ ឈឺដែរ?

នីៈ បាទ!

ដានីៈ គាត់ឈឺអីកាលហ្នឹង?

នីៈ ឈឺគ្រុនចាញ់ដូចគ្នា ។

ដានីៈ អញ្ចឹងរៀបការយ៉ាងម៉េច ឧបមាថាពូទៅ យើងត្រូវគ្នា យើងសួរនាំចិត្តគ្នាទាំងសងខាង ហើយយើងរៀបការហ្នឹង ឬក៏មានគេនាំឲ្យរៀបការ?

នីៈ យើងសួរនាំចិត្តឲ្យច្បាស់លាស់ ហើយបានយើងប្រាប់ចាស់ទុំ ។

ដានីៈ មានចាស់ទុំដែរ?

នីៈ មាន! ហើយប្រាប់ចាស់ទុំឲ្យគាត់គិតគូរៀបចំ របៀបថាសែនហ្នឹងណា៎ របៀបដូចខ្មែរដើម យើងអញ្ចឹងណា រៀបចំជាពិធីហ្នឹង រៀបចំជាទម្លាប់ខ្មែរដើម អញ្ចឹងដល់ពេលរួចពីហ្នឹងទៅ រៀបគ្រួសារហើយបានរយៈពេល១០ខែ ដល់ពេលបាន១០ខែហើយទទួលមានកម្លាំងខាង នេះទៅ ពីអតីតកងពលទី៣ចាស់នេះ ១៦៤ហ្នឹង ទៅយកដល់ជំរុំ ក៏សម្រេចចិត្តមកតែម្តង

ដានីៈ មកទាំងគ្រួសារ?

នីៈ បាទ! មកទាំងអស់គ្នា ។

ដានីៈ មកណា?

នីៈ មកនៅខាងឃុំថ្មដារយើងបច្ចុប្បន្ននេះ ឡើងនៅហ្នឹងនៅមួយជួរហ្នឹងរហូត ឯចំពោះគ្រួសារ ហ្នឹងពេលសភាពការណ៍ធូរអញ្ចឹងទៅក៏គេបញ្ជូននាំឲ្យមកនៅលើដីយើងលើនេះ បើសភាព ការណ៍តឹងតែងទៅគេទិញដីថៃកន្លែងណាមួយយកទៅដាក់នៅឲ្យឆ្ងាយគីឡូពីព្រំដែនអញ្ចឹងទៅ ឯចំពោះប្តីដែលនៅខាងមុខហ្នឹងក៏ថៃហ្នឹងគេប្រគល់សិទ្ធឲ្យចេញចូលគានការកំណត់របស់គេ ។

ដានីៈ អញ្ចឹងកាលហ្នឹងពេលដែលពូមកវិញ ឆ្នាំណាដែលគេទៅយកមកនៅតាមព្រំដែនថ្មដារវិញ?

នីៈ មកក្នុងឆ្នាំ៨០ហ្នឹងដែរ ចុងឆ្នាំ៨០ជិតដាច់ បើគិតក្នុងថ្ងៃខែសកលវាចូលក្នុងឆ្នាំ៨១ ។

ដានីៈ ចុះពេលហ្នឹងយើងនៅក្នុងកងពលណាទៅ?

នីៈ ដល់ពេលចូលមកគឺនៅក្នុងពល៦៣វិញ ហើយ១៦៤គេលុបចោលដាក់កងពលទី៣ចាស់ ហ្នឹងវិញ ហើយកងពលទី២ចាស់ហ្នឹងក៏នៅជាប់កងពលទី៣ចាស់ នៅចំហៀងខាងត្បូងធ្វើកា រយៈធ្វើការពីកោះកុងមក ចេញចូលខាងហ្នឹង ឯកងពលទី២រយៈធ្វើការគឺចេញចូលតាម ប្រកពោធិ៍សាត់នឹងសមរភូមិពាយ័ព្យភ្នំពេញ ។

ដានីៈ អញ្ចឹងកងពលទី៣តាមព្រំដែនពីកោះកុងមក?

នី៖ និយាយគឺថាម៉ាខ្សែស្របយើងហ្នឹង តាំងពីកំពតមក ។

ដានី៖ ពីកំពតមកដល់ណា?

នី៖ មកដល់ឃុំថ្មដាបេចុប្បន្ន ។

ដានី៖ ប៉ុន្តែពូចូលក្នុងកងពលទី៣ចាស់?

នី៖ ខ្ញុំចូលក្នុងកងពលទី៣ចាស់បានប៉ុន្មានថ្ងៃ ក្រោយពេលហ្នឹងអតីតមេខ្ញុំចាស់ ។

ដានី៖ ពីណាគេ?

នី៖ មេខ្ញុំចាស់ឈ្មោះ សេ តែគាត់ស្លាប់បាត់ហើយ គាត់ហៅទៅនៅវិញ ដល់ពេលទៅនៅបានតែប៉ុន្មានថ្ងៃខ្លួនគាត់ហ្នឹងទាក់មីនស្លាប់បាត់ទៅ ដល់ពេលទាក់មីនស្លាប់ទៅ ខ្ញុំខាងប្រធានភស្តុភាកងពលទី២ បោសសម្អាតនោះគាត់ហៅឲ្យមកនៅជាមួយគាត់ហ្នឹង ក៏មកនៅជាមួយគាត់វិញ ។

ដានី៖ ចេញពីកងពលទី៣?

នី៖ បាទ!

ដានី៖ កងពលទី៣ តាមុត គាត់ប្រធានកងពល?

នី៖ កាលពីជំនាន់យើង៧៩មក មាស មុត គាត់មកមួយភ្លែតពេលខ្លីទេ ក្រោយពេលពីប្រមូលកម្លាំងនេះហើយ កម្លាំងខាងច្រកជួរភ្នំដងរែកខុះខាត អតីតមេនោះ ដូចជាលោក រិនដែលត្រូវជាកូនប្រសាររបស់ តាម៉ុក នោះជាប្រធានកងពលធំត្រូវការបែកឆ្វេងចូលទៅខាងអតីតប៉ារ៉ា ក៏ តាម៉ុក ហ្នឹងឲ្យកងការពារបាញ់សម្លាប់ចោលទៅ រួចហើយក៏ខុះមេធំនៅហ្នឹង ហើយក៏បញ្ជូន មាស មុត នេះឲ្យទៅដឹកនាំកម្លាំងដែលអតីតខ្មោច តារិន ហ្នឹងតំណាងដដែល ។

ដានី៖ ហើយខាងនេះពីណាគេ?

នី៖ ខាងនេះនៅខាងលើពីរនាក់បងប្អូន ខ្មោចរ៉ែន ហើយខ្មោចសេង ហ្នឹង ខ្មោចសេង គាត់គ្រប់គ្រងខាងកងពលទី៣ ហើយខ្មោចរ៉ែន ហ្នឹងគាត់គ្រប់គ្រងខាងកងពលទី២ ព្រោះកងពលទី២ហ្នឹងឥទ្ធិពលរបស់ រ៉ែន ហ្នឹងគាត់គ្រប់គ្រងតាំងពីប្រជាជាតិមករហូត ហើយមនុស្សស្លាប់ចង់អស់ហើយ គេបញ្ចូលតែអ្នកថ្មី ។

ដានី៖ ដល់ពេលពូមកនៅកងពលទី២?

នី៖ បាទ! ខ្ញុំមកនៅកងពលទី២ ដល់ពេលមកនៅកងពលទី២ក៏គេផ្អាក ហើយខ្ញុំនេះគេផ្អាកឲ្យមកច្បាំងខាងមុខហើយព្រោះខ្មោចបោសសម្អាតហ្នឹង តែគាត់ស្លាប់ហើយ គាត់ថាខ្ញុំមានគ្រួសារមានកូនតូចមានអីអញ្ចឹង ហើយបើមានហេតុការណ៍កើតឡើងទៅវាគ្មានអ្នកណាជួយអ្នកណា

ទេ អញ្ជឹងហើយក៏គាត់ហ្នឹងឲ្យខ្ញុំនៅមន្ទីរភស្តុភាជាមួយគាត់ ហើយក៏នៅជាមួយគាត់ទៅព្រោះជិត ។

ដានី: ហើយពូនៅរហូតដល់ពេលណាទៅ?

នី: នៅរហូតទាល់តែយើងឆ្នាំប៉ុន្មានទេ ឆ្នាំកាលពីជំនាន់យើងមុនសម្តេចចូលស្រុកបន្តិច ក្រោយសន្ធិសិទ្ធប៉ារីស ឆ្នាំ៨០ជាងប្តុក៏៩០?

ដានី: ឆ្នាំ៩១ ។

នី: បាទ! នៅក្នុងអំឡុងឆ្នាំ៩០ហ្នឹង ដល់ពេលអញ្ជឹងទៅគេក៏ឲ្យខ្ញុំទៅដឹកនាំកម្លាំងមួយវរៈសេនាតូចហ្នឹងទៅជួយគេក្នុងសមរភូមិមូល កម្លាំងដែលធ្វើសកម្មភាពផ្លូវដែក ផ្លូវលេខ៥ រួចទៅហ្នឹងធ្វើការនៅហ្នឹងបាន២ឆ្នាំ ដល់ពេលធ្វើបាន២ឆ្នាំក៏មេការធំៗរបស់ខ្មែរក្រហមចាប់ផ្តើមបើកព្រៃគុបជាមួយបរស័ទ្ធថៃ ។

ដានី: បរស័ទ្ធថៃហ្នឹងអីគេ?

នី: បរស័ទ្ធហ្នឹងតាមការពិតវាជាក្រុមហ៊ុនណាំ ជាក្រុមហ៊ុនធំ ។

ដានី: ហើយកាលហ្នឹងតាវ៉ែន ហើយតាសេង គាត់ស្លាប់នូវ?

នី: ស្លាប់អស់ហើយ បើតាសេង គាត់នៅទេ តែតាវ៉ែន គាត់ស្លាប់ហើយ ។

ដានី: ហើយតាវ៉ែន ហ្នឹងម៉េចបានជាគាត់ស្លាប់អញ្ជឹង?

នី: តាមការពិតមនុស្សគាត់ហ្នឹងខូចពេល ក្រោយពេលចាប់ពីយើងក្រោយឆ្នាំ៨០ ៨១រហូតមក រំលោភបំពានខាងសិលធម៌ ។

ដានី: ចុះប្រពន្ធគាត់ទៅណា?

នី: ប្រពន្ធគាត់នៅ ប្រពន្ធគាត់គ្រូ ។

ដានី: គ្រូ?

នី: គ្រូមួយដែលដែលមាត់ កូនតាម៉ុក ហ្នឹង ។

ដានី: ឈ្មោះ គ្រូ?

នី: បាទ!

ដានី: ហើយប្រពន្ធនៅទេ ហេតុអីគាត់ហ៊ានខិលខូច?

នី: មនុស្សហ្នឹងមិនដឹងជាម៉េច ដល់ពេលអញ្ជឹងទៅជាល្មោភលោភខាងតណ្ហា ។ កាលពីនៅប្រចាំការនៅសមរភូមិនេះ គ្រាន់តែមានការខិលខូចជាមួយនារីទេ ប៉ុន្តែដល់ពេលរួចហើយគេរាយការណ៍ទៅឲ្យតាម៉ុក ដល់ពេលតាម៉ុក ដឹងហេតុភេទមិនស្រួលគាត់ក៏មិនទុកចិត្តអ្នកដែលរាយការណ៍ដែរ ព្រោះជាកូនប្រសាររបស់គាត់ហើយគាត់ម៉េចហ្នឹងទុកចិត្ត ខ្លាចគេបង្កាច់

បន្ទុចកូនគាត់ បើអញ្ចឹងគាត់ចាត់តាំងកម្លាំងជំនិតរបស់គាត់មកតាមដានមួយឆ្នាំ ហើយចាប់ផ្ដើមដក តារ៉ែន ហ្នឹងទៅដើង ដល់ពេលដក តារ៉ែន ទៅដើងហើយគាត់ទៅតាមដានខ្លួនគាត់ទៀត ព្រោះឲ្យជិតគាត់បន្តិច ដល់ពេលតាមដានខ្លួនគាត់អញ្ចឹង ដល់ពេលនេះទៅចាប់រំលោភប្រពន្ធគេ ដែលប្ដីគេទៅមុខនោះ ដល់ពេលរំលោភអញ្ចឹងប្ដីគេមានតួនាទីជាវរៈសេនាធំ ដល់ពេលអញ្ចឹងមើលទៅហេតុការណ៍ហ្នឹងវាមិនស្អាត ដល់ហេតុការណ៍មិនស្អាត តាម៉ុក ហ្នឹងគាត់មិនដឹងធ្វើម៉េច ព្រោះធ្វើលែងបែកហើយ ដល់ពេលធ្វើលែងបែកមិនដឹងធ្វើម៉េច ដល់ហើយមិនដឹងចែងឡូអីទេ គាត់ហ្នឹងទៅបាញ់ពស់ ហើយពស់ហ្នឹងនៅធ្វើសំបុកពងនៅចុងរាំង ។

ដានី: តារ៉ែន ហ្នឹង?

នី: បាទ! រួចគាត់ឲ្យនារសាបើកឡានដល់ខាងក្រោមអញ្ចឹងគាត់បាញ់ បាញ់ពស់មេធ្លាក់មកហើយ ឲ្យនារសារឡើងទៅយកពង ហើយគាត់ត្រូវហើយអាហ្នឹងស្ងោរទាំងមេស្ងោរទាំងពងអាហ្នឹងពស់វែករនាម ដល់ពេលហូបចំណីពស់ហ្នឹងហើយចាប់ផ្ដើមឈឺ ឈឺហ្នឹងចាប់ផ្ដើមខ្វិនស្ពាប់ដៃស្ពាប់ជើង ដល់ពេលស្ពាប់ដៃស្ពាប់ជើងអញ្ចឹងយូដែរ ដល់ពេលហើយ តាម៉ុក មើលទៅមិនកើតឲ្យពេទ្យយកថ្នាំទៅចាក់បញ្ចប់ជីវិតហ្នុងទៅ ។

ដានី: ឆ្នាំណាហ្នឹង?

នី: ឆ្នាំ៨៩ជិត៩០ហើយ មុននឹងអ៊ុន គាត់ចូលមកហើយ មុននឹងយើងត្រូវគ្នាហ្នឹង ។

ដានី: អញ្ចឹងមុនដំបូងដោយសារតែគាត់ទៅស្ងោរពស់ហ្នឹងហូបពស់ហ្នឹងទេដែលធ្វើឲ្យគាត់មានជម្ងឺហ្នឹង?

នី: បាទ!

ដានី: អាហ្នឹងមកពីមូលហេតុអី មកពីពស់ហ្នឹងមានពិសមែន?

នី: មិនដឹងដែរ បើតាមអបិយជំនឿគេថាពស់មានគេថែគេទាំអញ្ចឹង ។

ដានី: កាលហ្នឹងនៅណា?

នី: នៅអន្លង់វែង ។

ដានី: ទាំងប្រពន្ធទាំងកូននៅហ្នឹងទាំងអស់?

នី: នៅហ្នឹងទាំងអស់ ។

ដានី: ហើយស្លាប់ហ្នឹង តាម៉ុក ឲ្យពេទ្យចាក់ថ្នាំសម្លាប់ទេ?

នី: ចុះបើខ្វិនដៃខ្វិនជើងហើយ នៅនាំតែពិបាកទេ ដល់ពេលពិបាកពេកមើលទៅទុកវាមិនកើតក៏តាម៉ុក ហ្នឹងបញ្ជាឲ្យពេទ្យចាក់ថ្នាំសម្លាប់ចោលទៅ អាហ្នឹងពត៌មាននេះខ្ញុំមិនបាននៅជិត

ហើយឃើញច្បាស់ហ្នឹងភ្នែកទេ អាហ្នឹងក្មួយបង្កើតរបស់ មាស មុត មកនិយាយប្រាប់ខ្ញុំ ព្រោះស្គាល់គ្នាតាំងកាលនៅនេះ កាលមិនទាន់ទៅខាងជើងនៅឡើយ ។

ដានី: បើតាមខ្ញុំពួតត៏មានអ្នកខ្លះគេថា តាម៉ុក បាញ់ចោល ។

នី: អត់ទេ អត់មានបាញ់ទេ ។

ដានី: អញ្ចឹងចាក់ថ្នាំទេ?

នី: បាទ! ដល់ពេលពិបាកពេកទេបានឲ្យពេទ្យចាក់ថ្នាំសម្លាប់បញ្ចប់ទៅ ។

ដានី: ហើយកាលគាត់ធ្វើខុសសិលធម៌ រំលោភប្រពន្ធគេហ្នឹង កាលហ្នឹង តាម៉ុក អត់ទាន់មានធ្វើអីទេ?

នី: ធ្វើអីមិនកើត ។

ដានី: ម៉េចអញ្ចឹង?

នី: ព្រោះកាលហ្នឹងសុទ្ធតែមានអង្គរក្សការពាររាងខ្លួន កម្លាំងកងទ័ពហ្នឹងគឺមានអ្នកស្មោះត្រង់រៀងៗខ្លួនដូចគ្នា បើអញ្ចឹងអារឿងធ្វើកើតហ្នឹងវាចេះតែកើតហើយ ខ្មោច តាវិន កូនប្រសារគាត់ហ្នឹងគាត់មិនបញ្ជាឲ្យអ្នកកាន់ទូរលេខបាញ់ ហើយអារឿងខ្មោច តាវិន ហ្នឹងហើយមិនតាម៉ុកបញ្ជាឲ្យបាញ់ ឲ្យអ្នកកាន់ទូរលេខហ្នឹងបាញ់កាំភ្លើងបេ៤០ ។

ដានី: បាញ់កាំភ្លើងបេ៤០?

នី: បាទ! ហើយអានោះវាបាញ់ វាថាបើបាញ់អាភ្លើងយើងធម្មតាខ្លាចបាញ់វាមិនឆេះហើយបែកការណ៍ បើបែកការណ៍វាអត់រស់ អញ្ចឹងយកកាំភ្លើងធំបាញ់ហ្មង ។

ដានី: ចុះដល់ពេល តាវ៉ែន ដកទៅកងពលទី២ពីណាកាន់បន្តទៀត?

នី: កងពលទី២ក្រោយពេលដែល តាវ៉ែន ដកទៅគឺរៀបបញ្ចូលគ្នាវិញហ្នឹង ។

ដានី: រៀបបញ្ចូលគ្នា?

នី: បាទ! រៀបបញ្ចូលគ្នាគឺកងពលទី៤ហើយនឹងកងពលទី៣រៀបបញ្ចូលគ្នាបានដាក់ឈ្មោះថាកងពលទី៥ ។

ដានី: ប៉ុន្តែពួនៅហ្នឹងដែរ?

នី: បាទ!

ដានី: ហើយ តាសេង គាត់ប្រធាននៅហ្នឹង,

នី: បាទ!

ដានី: ចុះគាត់ស្លាប់នៅឆ្នាំណា តាសេង ហ្នឹង?

នី៖ ប្រធាននៅហ្នឹង ហើយប្រធានរួមនៅហ្នឹង សេង រួចហើយប្រធានគ្រប់គ្រងកងពលទី២ហ្នឹង ឈ្មោះស្អី ឈាន ទេ តាម៉ុក គាត់បញ្ជូនពីមន្ទីរដងវែកមក ។

ដានី៖ មិនមែន អ៊ី ឈាន ទេ?

នី៖ មិនមែនទេ អ៊ី ឈាន នៅប៉ៃលិន ហើយគាត់ហ្នឹងឈ្មោះ ឈាន ដែរតែមិនដឹងស្អី ឈាន ទេខ្ញុំបានចាំទេ ភ្លេចត្រកូលគាត់បាត់ហើយ បន្ទាប់មកមួយទៀតរង អ៊ី ឈាន ហ្នឹងគឺឈ្មោះ ចុន ហើយ ចុន ហ្នឹងអតីតដើមកំណើតនៅព្រែកប្បាសតាកែវយើងនេះដែរ ។

ដានី៖ អញ្ចឹងមួយជួរហ្នឹង តាសេង គាត់គ្រប់គ្រងរួម តែកងពលតូចមាន ឈាន មាន ចុន?

នី៖ បាទ!

ដានី៖ ហើយមានពីណាទៀត?

នី៖ បើ សេង ហ្នឹងមានខ្មោច សេង ហ្នឹងទៅហើយមានលោក ឈឿន ខាងភ្នែកមួយខាង ដែលនៅស្រុកសំឡូត ។

ដានី៖ ឈ្មោះ ឈឿន ហ្នឹង?

នី៖ បាទ!

ដានី៖ ចុះដូចពូប្រធានក្រុមប្រឹក្សាយើងរាល់ថ្ងៃ គេឈ្មោះ?

នី៖ អួន យ៉ន់?

ដានី៖ បាទ! គាត់ធ្វើអីដែរ?

នី៖ គាត់ហ្នឹងប្រធានកងពលតូច ។

ដានី៖ ប្រធានកងពលតូចនៅណាទៅ?

នី៖ កងពលតូចហ្នឹងមិនចូលក្នុងកងពលផ្សេងៗទេ មានមុខព្រួញសមរភូមិចូលទៅជ្រៅ ដូចជាកងពលតូចរបស់កែវ ពង់ អញ្ចឹងណា៎ មិនមានទាក់ទិននឹងកងពលណាទេ គឺកងពលឯករាជ្យនៅក្រោមការចាត់ចែងរបស់ ដូចថាអ្នកណាមេធំហ្នឹង តាៗមានណា មាននួន ជា ឬក៏ប៉ុល ពត គឺទទួលការណែនាំអប់រំពីហ្នឹងមកហ្នុង ។ អួន យ៉ន់ ត្រូវចេញពីសមរភូមិហៅមកធ្វើការបំណាច់ខែឬបំណាច់ឆ្នាំ មកត្រង់ភ្លឹងសំដៅទៅកន្លែងធ្វើការរបស់ប៉ុល ពត ហ្នុង ។

ដានី៖ ទៅកន្លែង ប៉ុល ពត ហ្នុង?

នី៖ បាទ! មិនមានទាក់ទងនឹងកងពលណាទៀតទេ ។

ដានី៖ ហើយកងពលតូចនៅហ្នឹងឈ្មោះ អួន យ៉ន់?

នី៖ ចា៎!

ដានី៖ ចុះមានកងពលណាផ្សេងៗទៀតទេ?

នី៖ កងពលឯករាជ្យ ។

ដានី៖ កងពលឯករាជ្យ?

នី៖ នៅតាមព្រំដែនអត់មានកងពលឯករាជ្យទេ មានតែរួមគ្នាដូចជាកងពលទី៥ ហើយនៅមួយផ្នែកទៀតដូចជាកងពល១០៥ កងពល១០៥ហ្នឹងគឺកងពលរបស់លោក ប៊ូរ ហ្នឹង លោក ប៊ូរ នៅកំពង់សោមហ្នឹង កងពល១០៥នឹងកងពល១០៧កងពលឯករាជ្យដូចគ្នា ។

ដានី៖ កងពល តាប៊ូរ គាត់នៅណាទៅ?

នី៖ កងពល១០៥គឺក្រោយមក សម ប៊ិត ទទួលភារៈគ្រប់គ្រងកងពលឯករាជ្យហ្នឹងវិញហើយ ទៅប្រចាំសមរភូមិនារតីខាងច្រកយើងម៉ាដួរព្រៃមៀល អាហ្នឹងគ្រប់គ្រងកងពល១០៥ហ្នឹង មាន សម ប៊ិត មាន នួន ប៉ែត ហើយមានអី គល់ មួយទៀតទេ បីរូបហ្នឹងហើយ រួចបានកងពល១០៧ដែលមានលោក ប៊ូ ហ្នឹង ហើយលោក អឹម អាហ្នឹងសមរភូមិខ្សែស្របសមុទ្រ ។

ដានី៖ ខាងស្រែអំបិល?

នី៖ បាទ!

ដានី៖ ចុះខាងកោះកុងខាងអីវិញ?

នី៖ ហ្នឹងអើយ មួយខ្សែកងពល១០៧ហ្នឹងហើយ ។

ដានី៖ អាហ្នឹងសុទ្ធតែក្រោមពីខាងតាៗហ្នុង?

នី៖ បាទ! កងពលហ្នឹងសុទ្ធតែឯករាជ្យដូចគ្នា ទទួលការគ្រប់គ្រងអីនោះគឺសព្វបែបយ៉ាងពីតានោះ ។

ដានី៖ ចេញមកពី ប៉ុល ពត ហ្នុង?

នី៖ បាទ!

ដានី៖ ហើយចុះកែវ ពង់?

នី៖ កែវ ពង់ ហ្នឹងក៏អញ្ចឹង ។

ដានី៖ កែវ ពង់ គាត់នៅទិសខាងឪរ៉ាល់អីហ្នឹង?

នី៖ បាទ! ខាងកំពង់ស្ពឺ ។

ដានី៖ ហើយ តាសាន ។

នី៖ បងសាន ហ្នឹងកងពលប៉ុន្មានទេ ហើយបងសាន ហ្នឹងក៏ឯករាជ្យដែរ ឲ្យតែអគ្គភាពធ្វើការដាច់ៗ អ្នកក្នុងៗឧទាហរណ៍ថា កែវ ពង់ ប្រធានកងពលឯករាជ្យ ហើយអួន យ៉ង់ក៏ប្រធានកងពលឯករាជ្យ ហើយ បងសាន ហ្នឹងក៏ប្រធានកងពលឯករាជ្យដែរ ។

ដានី៖ គាត់ប្រធានកងពលដែរ?

នី៖ បាទ! ដល់ពេលអញ្ចឹងទៅ ដល់ពេលទៅនោះ ទៅធ្វើការ ទៅទទួលដែនការណ៍អីៗក៏ទៅមេទាំងអស់គ្នាអញ្ចឹងទៅ រួចដល់ពេលចុះទៅវិញទៅធ្វើការសម្រាប់កងពលឯករាជ្យ ក្នុងហ្នឹងគេត្រូវមានបង្កើតគណៈកម្មការ ប្រធានកងពលមួយហ្នឹង ឧទាហរណ៍ថា បងសាន ហ្នឹងគាត់មានវ័យចំណាស់ជាងគេ គេរៀបចំឲ្យគាត់ធ្វើប្រធាន ដល់ពេលធ្វើប្រធានគេប្រឹក្សាគ្នា ដូចថាត្រូវទៅវ៉ៃនៅកន្លែងណាមួយ ទីចាត់ការឃុំ ទីចាត់ការស្រុក ឬក៏ទៅវ៉ៃនៅទីប្រជុំជនណាមួយហ្នឹងគេពិភាក្សាគ្នាហើយ ឧទហរណ៍ថារបស់កែវ ពង់ ហើយនឹងកម្លាំងរបស់អ្នូន យ៉ង់ ហើយនឹងកម្លាំងរបស់ តាសាន ។

ដានី៖ តាសាន គាត់នៅម្តុំណា?

នី៖ គាត់នៅខាងកំពង់ស្ពឺជាមួយខាងកែវ ពង់ ហ្នឹងដែរ ។

ដានី៖ ដល់ពេលនេះក្រោយហ្នឹង ពូដែលជួបគាត់ដែរ?

នី៖ អ្នកណាគេ?

ដានី៖ កែវ ពង់, តាសាន, តាបូរ ហើយសម ប៊ិតអី?

នី៖ តាបូរ ខ្ញុំបានជួបយូហើយ ប៉ុន្តែ តាបូ ជួបយូហើយតាំងពីថ្ងៃ៥ថ្ងៃ៦នៅហ្នឹងភូមិហ្នឹង ។

ដានី៖ ថ្ងៃ៥-៦កាលគេមានផ្ទះនៅភ្នំពេញហ្នឹង?

នី៖ បាទ! ផ្ទះនៅភ្នំពេញកាលជំនាន់ញឹក ប៊ុនឆៃ ហ្នឹង ជំនាន់បន្ទាយតាក្រសាំង រួចអញ្ចឹងគាត់មកសម្រាកនេះ ហើយគាត់កាលហ្នឹងគាត់រត់ទៅកោះកុងទៅ ហើយដូចជា តាសាន គាត់នៅប្រម៉ោយទេ ហើយកែវ ពង់ គាត់ទើបតែមកនេះប៉ុន្មានថ្ងៃមុនដែរ ។

ដានី៖ ហើយកាលម៉ាជំនាន់យើងជួបគ្នា យើងមានស្គាល់គ្នាដែរ?

នី៖ ស្គាល់ ។

ដានី៖ កាលហ្នឹងពូមានឋានៈ?

នី៖ ខ្ញុំឋានៈវរៈសេនាតូច ។

ដានី៖ វរៈសេនាតូច?

នី៖ បាទ!

ដានី៖ ប៉ុន្តែពេលដែលឡើងវ៉ៃ ពេលដែលទៅជួបប្រជុំជាមួយគាៗអីយើងទៅជួបគ្នាស្គាល់គ្នាដែរ?

នី: ជួបតាមផ្នែក ដូចថាផ្នែកយើងនៅតាមខ្សែស្របព្រំដែននេះជួបវគ្គផ្សេងទៅ ទទួលដែនការផ្សេងទៅ ឯគេខាងសមរភូមិក្នុងនោះគេរៀបចំសម្រាប់គម្រោងគេទៅ គេធ្វើតាមទិសតាមដែនការគេទៅ ។

ដានី: ចុះ តាសាន កាលជំនាន់ពន្លាំគាត់នៅណាដែរ?

នី: គាត់នៅខាងភូមិភាគបច្ចឹម គាត់ដឹកនាំកងទ័ពខាងបច្ចឹម ។

ដានី: ខាងបច្ចឹម?

នី: បាទ! តាសាន ហ្នឹងខ្ញុំទើបតែស្គាល់កាលជំនាន់៧៩នេះទេ កាលខ្ញុំមកពីព្រំដែនខាងកើតមកមកវៃផ្លូវជាតិលេខ៥ហ្នឹង ឃើញគាត់ចំណាំគាត់ហ្នឹង ។

ដានី: កាល៧៩គាត់ធ្វើអី?

នី: គាត់ដឹកនាំកងទ័ព តាមពិតគាត់ហ្នឹងគឺកងពលយូណាស់ហើយ ។

ដានី: ប៉ុន្តែគាត់អត់មានបានឡើងអីទេ?

នី: អត់បានឡើងដោយសារមានការទាក់ទិនជាមួយប្រធានភូមិភាគឈ្មោះអី?

ដានី: ជូ ចេត?

នី: ហ្នឹងហើយ ។

ដានី: ដល់ពេលអញ្ចឹងទៅគាត់អត់បានឡើងធំហ្នឹងគេ?

នី: បាទ!

ដានី: បើតាមអ្នកស្របានឹងគាត់ឋានៈគាត់ប្រហែលជា?

នី: មិនស្រួលរដ្ឋមន្ត្រី ។

ដានី: ឋានៈគាត់ដូច មាស មុត, ជូ ម៉េតអញ្ចឹង?

នី: ហ្នឹងអើយ ។

ដានី: ដល់ពេលក្រោយមកគាត់អត់មានបានតួនាទីអីទេ?

នី: អត់ទេ ។

ដានី: ដូច អួន យ៉ន់ គាត់ធ្វើគណៈស្រុក ហើយប្រធានក្រុមប្រឹក្សាអី ហើយដល់ពេល តាសាន ហ្នឹងគាត់អត់មានតួនាទីអីទេ?

នី: អត់មាន ។

ដានី: តាំងពីសាមារណេកម្មហើយគាត់ដូចប្រជាជនធម្មតា?

នី: គាត់ឈប់ហ្នង គាត់ថាដូចជាមិនទៅមុខទៅក្រោយអីទេ ។

ដានី: គាត់ចាស់ហើយ ។

នី៖ បាទ! គាត់ថាគាត់ចាស់ណាស់ហើយ ៧០ជាងជិតចូល៨០ហើយ ។

ដានី៖ គាត់ឈប់ខ្លួនគាត់?

នី៖ បាទ! ហើយគាត់ឥលូវគាត់ដឹងខ្លួនគាត់ដែរហ្នឹង គាត់រាងភាំង ហើយមើលខ្ញុំអីហ្នឹងទាល់តែហៅគាត់មុន គាត់ថាមើលគេលែងស្គាល់អស់ហើយ បើហៅមុនគ្រាន់ចំណាំសម្លេងបាន តែបើមិនហៅមុនទេកុំថាគាត់ចាស់ថ្មើងកន្ទ្រើងអី ។

ដានី៖ ខ្ញុំជួបគាត់ដែរតើ ហើយខ្ញុំសួរនាំគាត់ៗច្រើនតែភ្លេច?

នី៖ ហ្នឹងហើយគាត់ច្រើនតែភ្លេច ។

ដានី៖ ហើយកន្លែងដែលគាត់នៅគាត់លែងចាំហើយ ចាំខ្លះអីខ្លះ?

នី៖ ហ្នឹងហើយ ។

ដានី៖ អញ្ចឹងពូនៅហ្នឹងរហូតដល់សាមារណកម្មហ្មង?

នី៖ បាទ! ទាល់តែសាមារណកម្មហើយ ក្រោយពេលសាមារណកម្ម ក្រោយពេលដែលអ៊ុនគាត់ចូលមកហ្នឹង មេៗខ្មែរក្រហមតុកឡុងគ្នាជាមួយបរស័ទ្ធថៃព្រៃគោក រួចហើយគេដកកម្លាំងខ្ញុំពីជំនួយសមរភូមិមួងមកឲ្យមកឈរជើងនៅវាស់ឈើវាស់អីហ្នឹងជាមួយបរស័ទ្ធថៃហ្នឹង នៅរហូតទៅ ហើយចំពោះប្រពន្ធកូនពីដើមខ្ញុំមកធ្វើការនៅនេះគេនៅនោះទេ នៅស្រុកសំឡូតទេ នៅឃុំកំពង់ល្ពៅ ដល់ពេលវាពិបាកធ្វើដំណើរទៅមក ហើយធ្វើការនៅនេះដល់ពេលអញ្ចឹង ដល់ហើយ គាន្ធូន ជា ហ្នឹងក៏គាត់សម្រេចថាឲ្យយកប្រពន្ធកូនមកនៅនេះមក ជ្រើសរើសដីនៅទៅ ដីកន្លែងណាដែលដាំដំណាំល្អ ពីព្រោះយើងទៅមុខទៀតទៅយើងត្រូវការដាំដំណាំដោះស្រាយជីវិត ពីព្រោះឥលូវមានការផ្គត់ផ្គង់នេះដោយសារតែមានសង្គ្រាមទេ តែចប់សង្គ្រាមអត់មានអ្នកណាផ្គត់ផ្គង់ទេ ។

ដានី៖ គាត់ថាអញ្ចឹង?

នី៖ បាទ! ដូចនេះពួកមិត្តទៅនៅត្រូវជ្រើសរើសដីឲ្យហើយ តែដីមិនល្អចិញ្ចឹមជីវិតមករស់ទេ ។

ដានី៖ គាត់ប្រាប់អញ្ចឹង?

នី៖ ហ្នឹងហើយ ។

ដានី៖ អញ្ចឹងគាត់ប្រាប់ឲ្យមកនៅទាំងអស់គ្នា?

នី៖ ហ្នឹងហើយ គាត់ថាកាលពីរៀនអំពីសេដ្ឋកិច្ចជីវភាពហិរញ្ញវត្ថុនាំគ្នាម្នាក់ៗស្រលាញ់តែវីឡា ស្រលាញ់តែមាសពេជ្រ ប៉ុន្តែបើមិនស្រលាញ់ដីជាមុន មាសពេជ្រមិនអាចកើតមានបានទេ ពួករបស់អស់ហ្នឹងមិនអាចកើតមុនដីបានទេ មានតែដីទេដែលកើតមុន ត្រូវចេះស្រលាញ់ដីជាមុន ។

ដានី៖ បើតាមខ្ញុំជួបអ៊ំពូមីងពីម្សិលមិញហ្នឹង គាត់ថាខ្លះមកពីសំឡូតមករៀបចំគ្រួសារជាកងពលថ្មីមួយទៀតមកអញ្ចឹងមែនអាហ្នឹង?

នី៖ អាហ្នឹងអ្នកខ្លះឆ្លើយដោយមានការច្របូកច្របល់ យល់អំពីការរៀបរយហើយ អំពីរការផ្លាស់ប្តូរលំនៅ ខុទារហាណ៍ដូចថាខ្ញុំមកនៅអញ្ចឹង តាមការពិតគេរៀបជាកម្លាំងតែពីក្រុមទេមកឲ្យប្រចាំការនៅហ្នឹង ប៉ុន្តែអង្គភាពអីៗគឺនៅក្នុងកងពលទី៥ដដែលទេ ប៉ុន្តែគ្រាន់តែមកកាន់ការងារនៅកន្លែងនេះ អញ្ចឹងដល់មានការលំបាកនេះ ចង់និយាយថាការផ្លាស់កន្លែងផ្លាស់ប្តូរលំនៅឋាន មិនដឹងថាផ្លាស់ប្តូរនេះវាទៅតាមទិសគម្រោងការងារដែលចាំបាច់ទេ ដឹងតែមកដល់គេបង្កើតកងនេះនោះអញ្ចឹង មិនដឹងបង្កើតជាក្រុម ហើយក៏មិនដឹងថាបង្កើតកងដោយប្រភេទណា លំដាប់ថ្នាក់ណា ជាកងតូចឬកងធំអីទេ ហើយក៏មិនដឹងថាការៀបរយនេះជាប់ជាមួយអង្គភាពណាក៏អត់ដឹងដែរ ម្លោះហើយគ្នាឆ្លើយទៅឮសូរតែគេថាកងពលនេះកងពលនោះចេះតែឆ្លើយតាពាសក៏មានៗ

ដានី៖ កាលហ្នឹងដកមកពីសំឡូតដូចជា២០០គ្រួសារឬមួយក៏១០០គ្រួសារជាងហ្នឹង មកជាមួយតាពៅ ហើយតាពៅ ដូចថាគាត់មកបង្កើតកងពលមួយផ្សេង?

នី៖ តាមការពិតគឹម ពៅ ពីនោះមកគាត់ជាសាខារបស់ តាម៉េត ហ្នឹង ដោយការរៀបរយ គឹម ពៅ ត្រូវទៅប្រចាំការធ្វើការនៅខាងមាត់ព្រែកវាលបីវាលបួន ដោយច្រកហ្នឹងវាដាច់ចន្លោះ ចុះកម្លាំងតាំងពីយើងឆាយដាច់អូររន្ទរហូតទៅដល់មាត់ព្រែកយើងចុះទៅដល់មាត់ប៉ោះនោះ វាឆ្ងាយណាស់ បើអញ្ចឹងវាអត់ដឹងរឿងសមាសភាពកម្លាំងសត្រូវហ្នឹងវាត្រូវការចេញចូលពេលណា ស្មើរណា ឬស្នាក់នៅកន្លែងណាទេ យើងនាំកម្លាំងទៅធំ អញ្ចឹងហើយវានាំឲ្យប៉ះពាល់កម្លាំងយើង បើអញ្ចឹងបានដកហូត គឹម ពៅ ហ្នឹងមក គឹម ពៅ ដកមកមានកម្លាំងមួយវរៈសេនាធំ គឹម ពៅ គឺប្រធានវរៈសេនាធំមកហ្នឹង ប៉ុន្តែវរៈសេនាធំហ្នឹងមិនទាន់ដាច់ពី ម៉េត នោះទេ មិនទាន់ដាច់ពី០៥ទេ អត់ទាន់ដាច់ទេ ប៉ុន្តែក្រោយមកនេះព្រោះរឿងហ្នឹង រឿងវរៈសេនាធំឯករាជ្យ កងពលតូចឯករាជ្យ រឿងហ្នឹងហើយដែលនាំឲ្យមានកម្លាំងផ្ទុះផ្សាគ្នានោះ ពីព្រោះដល់ពេលប្រកាសផ្លាស់ប្តូររបប របបប្រជាធិបតេយ្យដល់ពេលអញ្ចឹងវា ដូចថាមនុស្សវាមិនខុសពីការច្បាំងរវាងខ្មែរយើងនេះសង្គ្រាមផ្ទៃក្នុងរវាងបុណ្យស័ក្ត បើអញ្ចឹងច្បាំងហ្នឹងវារឿងបុណ្យស័ក្តមែន ហើយរឿងទំនាស់គ្នានាំឲ្យមាន កែវពង់ មានគឹម ពៅ ទៅចចារដើម្បីរកការផ្សះផ្សាឲ្យត្រូវគ្នា ឲ្យមានតុល្យភាព ដូច អ៊ី ឈានជាមួយតា អៀង សារីនោះ ជាមួយសុខ ភាព នោះ ធ្វើអញ្ចឹងដើម្បីព្រោះក្នុងគណៈបក្សប្រជាធិបតេយ្យរបស់ខ្មែរក្រហមនេះ វាទៅជាចាត់តាំងអ្នកផ្សេងទៅហើយ បើអញ្ចឹងដូចជា

គឺម ពៅ កនពលក៏មិនប្រកាស ស្អីក៏មិនប្រកាស វាទៅជាសូន្យឈឹង បើអញ្ចឹងយើងមើល កោះមើលត្រើយមិនឃើញ ចំពោះកែវ ពង់ ក៏អញ្ចឹងដូចគ្នា ដល់ហើយគិតៗទៅវាតូចចិត្ត គ្នាអារឿងផលប្រយោជន៍ហ្នឹងបានតែវារង្គោះរង្គើអញ្ចឹងទៅ កុំអីហ្នឹងវាមិនងាយចប់សព្វគ្រប់ទេ ។

ដានី៖ ដោយសារយើងបែកបាក់ផ្ទៃក្នុង?

នី៖ បាទ!

ដានី៖ អញ្ចឹងពូមកនៅនេះតាំងពីគេឲ្យមករាស់ឈើធ្វើការជាមួយបរស័ទថៃអីហ្នឹង?

នី៖ ប្រពន្ធកូននាំមក ហើយខ្ញុំមកធ្វើការនៅនេះពីឆ្នាំ៩២ ហើយ៩៤បានយកប្រពន្ធមក ។

ដានី៖ មកនៅផ្ទះហ្នឹងហ្នង?

នី៖ អត់ទេ ផ្ទះនេះខ្ញុំទើបតែលើកទេ ពីមុនខ្ញុំនៅនោះ ។

ដានី៖ នៅណា?

នី៖ នៅខាងក្នុង នេះពីអូរនេះទៅ ។

ដានី៖ ភូមិហ្នឹងដែរ?

នី៖ បាទ!

ដានី៖ ហើយបានមកលើកផ្ទះនៅនេះ?

នី៖ បាទ! រួចហើយក្រោយពេលពីរួចថ្ងៃ៥-៦ ឡើងពីជំរុំលើកក្រោយនេះមកវិញក៏លោកអួន យ៉ង់ ហ្នឹងថាគេធ្វើក្រដាសស្នាមប្រកាន់ដៃអីហើយ ដូចនេះជ្រើសរើសដីទៅ ប៉ុន្តែរើសដីកុំរើសដីល្អយ៉ាងម៉េចក៏ដោយកុំឲ្យអត់ផ្លូវ ។

ដានី៖ គាត់ថាអញ្ចឹង?

នី៖ ហ្នឹងហើយ គាត់ថាធ្វើម៉េចឲ្យមានផ្លូវ បើថាអត់ផ្លូវអត់ន័យហើយ ។

ដានី៖ គាត់គណៈស្រុកមែនកាលហ្នឹង?

នី៖ បាទ! គាត់ថាគាត់ប្រាប់ហ្នឹងតែអ្នកស្គាល់រាប់អានគ្នាទេ បើអ្នកមិនរាប់អានអត់ប្រាប់ទេ ។

ដានី៖ ហើយស្គាល់គាត់ច្បាស់ទេ?

នី៖ មិនច្បាស់ម៉េច បើខ្ញុំទៅពោធិ៍សាត់ទៅស្នាក់តែផ្ទះគាត់ហ្នឹង ល្ងាចៗឡើងឡានគាត់ហ្នឹងបបួលគាត់ដើរលេង ខ្ញុំដើរលេងយប់ណាយប់ណីបានចូលផ្ទះ ជិះឡានមកវិញមក ។

ដានី៖ ចុះពូនៅមានក្របខ័ណ្ឌអីជាមន្ត្រីរាជការ?

នី៖ ខ្ញុំអាត្រែតហើយ ។

ដានី៖ កាលមុនពូខាងអី?

នីៈ ខាងសាធារណៈការ ។

ដានីៈ ខាងសាធារណៈការស្រុក?

នីៈ បាទ!

ដានីៈ អញ្ចឹងហ្នឹងយ៉ាងម៉េច ប្រធានការិយាល័យសាធារណៈការ?

នីៈ បាទ!

ដានីៈ ចុះពូធ្វើពីឆ្នាំណាដល់ឆ្នាំណា?

នីៈ ពីឆ្នាំប៉ុន្មានទេ?

ដានីៈ យើងសាមារណកម្មហើយពីឆ្នាំ៩០ដាង?

នីៈ តាំងពី៩៦ហ្នឹងមក ដើរសិក្សាផ្លូវអស់ហ្នឹង ហើយដើរវាស់វែង ហើយដើរកាត់តែព្រៃហ្នឹង ។

ដានីៈ ពី៩៦ដល់ឆ្នាំណាបានអាត្រែត?

នីៈ អាត្រែត២ឆ្នាំហើយ ។

ដានីៈ ពូអាយុមិនទាន់៦០ផង ម៉េចបានជាអាត្រែត?

នីៈ មិនដឹងម៉េចឃើញសេចក្តីប្រកាសមក ។

ដានីៈ ឃើញសេចក្តីប្រកាសថាអាត្រែត?

នីៈ បាទ! ហើយគេឲ្យ ក្នុងច្បាប់របស់ក្រសួងតែ៥៥ ។

ដានីៈ តែ៥៥ទេ?

នីៈ បាទ!

ដានីៈ ចុះដូចប្រធានក្រុមប្រឹក្សាស្រុក គាត់អាយុច្រើនជាង?

នីៈ ដូចជា ធួក អីហ្នឹងគាត់អាត្រែតដែរហើយ ។

ដានីៈ គាត់អាត្រែតដែរ?

នីៈ បាទ! និវត្តន៍អស់ហើយ គ្រាន់តែវាជាទីប្រឹក្សារបស់ស្រុកហ្នឹង ពេលប្រជុំពេលអីហ្នឹងក៏នៅជាប់ជាសមាជិកទីប្រឹក្សា អាហ្នឹងពេលត្រូវចូលប្រជុំពេលអី រួចហើយប័ណ្ណលិខិតជំរឿនមន្ត្រីរាជការ លោក អួន យ៉ន់ ហ្នឹងគាត់ឲ្យយកមកឲ្យខ្ញុំដែរតែខ្ញុំប្រកែក ខ្ញុំថាឈប់ធ្វើឈប់អីហើយ ។

ដានីៈ ពូលែងចង់ធ្វើហើយ?

នីៈ បាទ! ឈប់ហើយ មើលទៅដូចមិនកើតទេ បានផ្លូវបានអីគ្រប់គ្រាន់ហើយ ។

ដានីៈ ហើយផ្លូវនេះស្អាដែពូរៀបចំធ្វើខ្លួនឯងទេ?

នី៖ បាទ!

ដានី៖ តែពូនៅមានប្រាក់ខែដែរ?

នី៖ មាន ។

ដានី៖ ទោះយើងនិវត្តន៍ក៏យើងនៅមានប្រាក់ខែដែរ?

នី៖ បាទ!

ដានី៖ អញ្ចឹងពូខ្ញុំដូចជាជិតអស់សំនួរសួរពូហើយ នៅសល់សំនួរចុងក្រោយដែលទាក់ទងហ្នឹងតុលាការ មកដល់សព្វថ្ងៃនេះពូមានដែលស្តាប់រឿងគេជំនុំជំរះទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ជនដែលទទួលការខុសត្រូវខ្ពស់បំផុតហ្នឹង ដូចជាករណី០០១ ហើយករណី០០២ ពូធ្លាប់តាមដានទេ?

នី៖ ទេ តាមការពិតហ្នឹងមិនដែលបានតាមដានយូហើយ វិទ្យុ ម៉ាញ៉េអីហ្នឹងកូនយកទៅលក់បាត់អស់ហើយ ហើយទូរទស្សន៍វាអត់មាន ទូរទស្សន៍វាមើលមិនឃើញ អញ្ចឹងអត់មានអីតាមដានទេ ។

ដានី៖ តែពូដឹងដែរដែលគេកាត់ទោសកាត់អីហ្នឹង?

នី៖ ដឹង ។

ដានី៖ ហើយពូយល់ឃើញយ៉ាងម៉េចដែរ ចិត្តរបស់យើងផ្ទាល់ ដូចកាលដែលពូធ្លាប់បានឆ្លងកាត់ធ្លាប់បានរស់នៅជាមួយគាត់ដូចជាខាងករណី០០២នេះមានដូចជា នួន ជា អៀង សារី ហើយប្រពន្ធរបស់គាត់ ហើយនឹងខៀវ សំផន អីហ្នឹងដែលពូធ្លាប់ស្គាល់ ធ្លាប់រស់នៅជាមួយ ដូចដែលពូមានប្រសាសន៍ម៉េញថាតា នួន ជា គាត់ធ្លាប់ប្រកាសឲ្យចាប់គេចាប់អីអញ្ចឹង ហើយអ្នកដូចជាធ្លាប់ស្គាល់ដឹងគាត់ច្បាស់លាស់អញ្ចឹងដែរ ហើយបើតាមពូវិញពូយល់ឃើញយ៉ាងម៉េចដែរចំពោះតុលាការដែលរាជរដ្ឋាភិបាលហើយនឹងអង្គការសហប្រជាជាតិគេបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹង តើពូយល់ឃើញយ៉ាងម៉េចដែរ?

នី៖ រឿងចិត្តខ្ញុំ ហើយនឹងការយល់ការវិភាគរបស់ខ្ញុំ ព្រោះអីការកាត់ទោសនេះគឺវាជាវគ្គទីមួយ វគ្គទីមួយហ្នឹងគឺមានន័យយ៉ាងម៉េច គឺថាវគ្គពីជំនាន់នោះគឺថាគាត់នៅគ្រប់គ្រងប្រទេស គាត់ដឹកនាំប្រជាជនទូទាំងប្រទេស ការធ្វើរបស់គាត់គឺវាស្តាំសម្រាប់សង្គមហ្នឹងវាជ្រុលពេក ៦ សម្រាប់ការពន្យល់ណែនាំបង្ហាត់បង្រៀនពួកខ្ញុំដែលមកនៅហ្នឹងព្រំដែនថៃនេះ គឺដោយផ្លាស់ប្តូររបបហើយទេ ដូចនេះការកាត់ទោសរបស់សកលលោកនេះគឺកាត់ទោសតាមបែបបទ

របស់គាត់ដែលដឹកនាំសង្គមពីដំនាន់នោះ ដូចនេះការធ្វើនេះខ្ញុំកំណត់ថាមិនខុសទេគឺត្រឹមត្រូវ ។

ដានី: ត្រឹមត្រូវ?

នី: បាទ!

ដានី: ព្រោះការកាត់ទោសនេះគេមានដែនកំណត់របស់គេ ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ អញ្ចឹងកាលហ្នឹងគាត់គ្រប់គ្រងដូចថាវាស្តាំជ្រុល?

នី: បាទ! ស្តាំជ្រុល ។

ដានី: ពីព្រោះកាលហ្នឹងបើតាមការស្រាវជ្រាវនេះ គឺធ្វើឲ្យប្រជាជនចន្លោះពី១លាន៧សែនទៅ២លាននាក់បានស្លាប់ក្នុងពី៧៥ដល់៧៩ហ្នឹង អញ្ចឹងពូគិតថាត្រឹមត្រូវ?

នី: បាទ! ការធ្វើមិនខុស ខ្ញុំដឹងហើយ ខ្ញុំដឹងថាមុននឹងគេបង្កើតតុលាការគេកាត់ជាពីកំណាត់ហើយ ព្រោះគេបានលើកហើយពី៧៥មកឆ្នាំ៧៩តើ ឯទទួលការគ្រប់គ្រងទទួលឥទ្ធិពលដែលខ្ញុំបាននិយាយនេះគឺខ្ញុំនិយាយសម្រាប់ក្រោយឆ្នាំ៧៩ ។

ដានី: ប៉ុន្តែដូចថាយើងធ្លាប់នៅជាមួយគាត់ យើងធ្លាប់គស្ហ៊ូ យើងមានដូចថាយើងស្គាល់គាត់យើងមានមនោសញ្ចេតនាជាមួយគាត់ ក្នុងនាមយើងជា?

នី: ដែលគេហៅថាជាសមាជិកមួយរូបក្នុងគណៈបក្សហ្នឹង ។

ដានី: ពូយល់ឃើញយ៉ាងម៉េចដែរ?

នី: ខ្ញុំនិយាយទៅចំពោះអតីតមេៗហ្នឹង តាៗហ្នឹង បើសម្លេងសម្រាប់ជួរក្នុងការគាំទ្រវិញចំពោះតា នួន ជា បានកម្លាំងគាំទ្រតែ២០ភាគរយទេពីកម្លាំងជួរគណៈបក្ស ឯលោកខៀវ សំផន កម្លាំងគាំទ្រពី៧៥ទៅ៨០ភាគរយ ។

ដានី: បានន័យថាគាត់មានប្រជាប្រិយភាព?

នី: បាទ!

ដានី: ចុះអៀង សារី?

នី: អៀង សារី ទោះគាត់មិនមានប្រជាប្រិយភាព ប៉ុន្តែបើនិយាយទៅតួនាទីគាត់វាផ្សេងណាគាត់ខាងក្រសួងការបរទេស ប៉ុន្តែបើទៅកម្លាំងគាំទ្រអាចត្រឹម៦០ភាគរយ អាហ្នឹងចំពោះតាអៀង សារី ។

ដានី: ចុះពួកតាម៉ុក ហើយប៉ុល ពត?

នីៈ បើទូទៅកម្លាំងចំពោះ តាម៉ុក ទទួលស្គាល់ហើយនឹងគាំទ្រតាមផ្នែក តាមផ្នែកមិនមានជាទូទៅទេ ចំពោះគាត់នេះបើនិយាយទៅរបៀបថាដុតភ្លើងរោលហើយបានយកទឹកទៅស្រោចហើយស្រោចណាបើស្ទីកវាស្ទោកអស់ហើយហ្នឹង ។

ដានីៈ អាហ្នឹង តាម៉ុក?

នីៈ បាទ!

ដានីៈ ហើយបើតាមពូវិញ?

នីៈ បាទ! បើអញ្ចឹងវាពិបាកណាស់ បើកម្លាំងហ្នឹងពេលណា ឧទាហរណ៍ថាមានប្តីមានប្រពន្ធ ហើយខ្ញុំមានប្រពន្ធអញ្ចឹង មានកូនអញ្ចឹង ត្រូវការឲ្យខ្ញុំទៅមុខរយៈពេលពី១ឆ្នាំទៅ២ឆ្នាំបះក៏៣ឆ្នាំបានមានបទបញ្ញាត្រូវមកវិញបាន១ មកបាន បើមិនអញ្ចឹងអត់មានត្រូវការវិលមកជួបប្រពន្ធកូនវិញបានទេ បើអញ្ចឹងហើយឧទាហរណ៍ថា ត្រូវមានការទាក់ទិនអីខ្វះ ទាក់ទិនធុរៈអីមួយអញ្ចឹង រឿងប្រពន្ធកូនអញ្ចឹង អាហ្នឹងគាត់អ្នកផ្តត់ផ្តង់ទេណា៎ ផ្តត់ផ្តង់របៀបចំកម្លាំងមកជួយថែទាំអញ្ចឹងទៅ អាហ្នឹងសម្រាប់តាម៉ុកគឺអញ្ចឹង រឿងចំណាយគាត់មិនខ្វាចចំណាយ ធ្វើម៉េចឲ្យតែយើងបានទៅ ឯចំពោះតា ប៉ុល ពត និយាយទៅគេហៅថា បើអាវុធវិញគឺស្ទើរនឹងដាវអាញ៉ាសឹក តែគាត់ចេញបទបញ្ញាអីមួយមិនមានអ្នកណាហ៊ានតវ៉ាបានទេ អាហ្នឹងខ្ញុំនិយាយពីក្រោយ៧៩នេះទេ ក្រោយពេលទទួលផែនការអ្នកចុះទៅអនុវត្តន៍ ត្រូវទៅអនុវត្តន៍សិន កើតឬមិនកើតបានគាត់ហៅឲ្យមកជួបសួរពីហេតុផល អត់មានប្រកែកទេពេលដែលដាក់ផែនការ អត់មានប្រកែកបានទេ ឲ្យយកទៅធ្វើសិន អាហ្នឹងក្រោយពេល៧៩ ។

ដានីៈ អាហ្នឹងដូចថាគាត់ដាក់ផែនការយើងអត់មានតវ៉ាដូចថាធ្វើមិនធ្វើអី ត្រូវតែធ្វើតាម?

នីៈ បាទ! ត្រូវតែធ្វើ ដើរតួសវ៉ាសជាលាយល័ក្ខហើយនោះគឺត្រូវតែធ្វើ ប៉ុន្តែរឿងធ្វើកើតមិនកើតនោះទៅជាយ៉ាងម៉េចអីយ៉ាងម៉េចនោះបានហៅមកជួបទៀត ។

ដានីៈ សួរហើយបើយើងធ្វើមិនកើតយ៉ាងម៉េច?

នីៈ ជូនពិសោធន៍ ។

ដានីៈ ពិសោធ៍?

នីៈ លែងយកទៅឲ្យអូសច្រវ៉ាក់អីហ្នឹង ។

ដានីៈ កាលពីជំនាន់៣ឆ្នាំអាហ្នឹងប្រហែលជាមានទោសហើយ?

នីៈ ច្បាស់ហើយ ។

ដានីៈ ហើយចុះមេខាងកងពលខាងអីវិញម៉េច ដែលពូធ្លាប់រស់នៅជាមួយដូចជា តាមុត ជុំ ម៉េត ហើយមេផ្សេងៗទៀត ចរិកគាត់យ៉ាងម៉េចដែរ ដូច តាមុតអី?

នី៖ ការដឹកនាំកាត់បន្ថយអារបៀបផ្ដាច់ការហ្នឹង បើនិយាយថាជាមួយទាហានហ្នឹងយើងវាពិបាកនឹងនិយាយណាស់ ពិបាកនិយាយយ៉ាងម៉េច ព្រោះធម្មតាក្នុងនាមជាអគ្គបញ្ជាការបើចិត្តមិនដាច់គឺដឹកនាំគេមិនបាន ម្លោះហើយទាល់តែចិត្តដាច់ ប៉ុន្តែតាមការតាមដានរបស់ខ្ញុំទៅខ្ញុំឃើញថាមានការកែប្រែតាមរបៀបរបបដែរ មានការអនុគ្រោះ មានការណែនាំ មានការពិសោធ៍ ប៉ះដៃយកដៃហើយប៉ះជើងយកជើង ។

ដានី៖ ហើយដូចតាមុត កាលពីសម័យសមុទ្រនៅកំពង់ កាលហ្នឹងបានន័យថាយកដៃប៉ះដៃ យកជើងប៉ះជើង?

នី៖ មិនបានទេ ។

ដានី៖ តែដល់ពេលក្រោយមក គាត់អត់ទេ គាត់កែប្រែហើយ?

នី៖ បាទ! គាត់កែប្រែ ។

ដានី៖ អញ្ចឹងអស់សំនួរអីត្រូវសួរនាំពូទៀតហើយ ហើយសួរនាំពូវាវាងយូដែរ ចង់៣ម៉ោងហើយ ហើយពូមានអីចង់បញ្ជាក់បន្ថែមនៅអ្វីដែលខ្ញុំមិនទាន់បានសួរពូទេ?

នី៖ ខ្ញុំមិនមានអ្វីបញ្ជាក់ច្រើនទេ ហើយតាមការពិតទៅមនុស្សដែលរស់នៅមួយជំនាន់ៗខ្ញុំនេះ អាពាក្យសម្រួលហ្នឹងការឆ្លើយនេះ វាមិនខុសគ្នាប៉ុន្មានទេ ឲ្យតែសម្រាប់មនុស្សដែលហៅថាមានការយល់ដឹងគ្រាន់បើនោះណា៎ ។

ដានី៖ អញ្ចឹងពូអត់មានអីត្រូវសួរនាំខ្ញុំទេ?

នី៖ អត់មានអីសួរនាំទេ ព្រោះខ្ញុំសួរនាំមុនមួយឃ្លាហើយ សួរឲ្យអស់ចិត្តឲ្យមុនហ្នឹងឆ្លើយ កុំឲ្យឆ្លើយហើយបានសួរក្រោយវាឆ្លើយជ្រុល ។

ដានី៖ អញ្ចឹងខ្ញុំអរគុណលោកពូច្រើនដែលបានចំណាយពេលផ្ដល់បទសម្ភាសន៍ជិត៣ម៉ោងហើយ អញ្ចឹងខ្ញុំសូមអរគុណពូច្រើន ។

នី៖ បាទ!